ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 19-Nov-2012, 12:54
CMS/CFO: Uch Arun

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

---

**អង្គជំនុំជម្រះសាលាដំបូង**

Trial Chamber
Chambre de Premiere instance

# <u>កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី</u>

# <u>ជំនុំជម្រះក្តីនៅដំណាក់កាលដំបូង</u>

## <u>សាធារណៈ</u>

សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/អជសដ

**ថ្ងៃទី០២ ខែតុលា ឆ្នាំ២០១២**

**ម៉ោង ០៩:០២ នាទី**

**សវនាការលើកទី១១៥**

**ចៅក្រមសាលាដំបូង៖**

ចៅក្រម និល ណុន ជាប្រធាន

ចៅក្រម ស៊ីលវៀ ខាតរ៉ាយថ៍ *(Judge Silvia CARTWRIGHT)*

ចៅក្រម យ៉ា សុខន

ចៅក្រម ហ្សង់ម៉ាក ឡាវែរ៍ *(Judge Jean-Marc LAVERGNE)*

ចៅក្រម យូរ ឧត្តរា

ចៅក្រម ធូ មណី (បម្រុង)

ចៅក្រម ក្លូឌា ហ្វេនស៍ (បម្រុង) *(Judge Claudia FENZ)*

**ក្រឡាបញ្ជីសាលាដំបូង៖**

លោកស្រី សែ កុលវុឌ្ឍី

លោក ដាវ អានសាន

លោក រ៉ូជឺ ហ្វីលីព *(Mr.Roger PHILLIP)*

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោក វីល្លៀម ស្មីត *(Mr. William Smith)*

កញ្ញា សុង ឆវន្ត

លោក វេង ហ៊ត់

លោក ឌេល លីសាក់ *(Mr. Dale Lysak)*

**ជនជាប់ចោទ៖**

លោក នួន ជា

លោក ខៀវ សំផន

**មេធាវីការពារជនជាប់ចោទ នួន ជា៖**

លោក សុន អរុណ

លោក ហ្សាស្ពើ ប៉ៅ*(Mr Jasper PAUW)*

**មេធាវីការពារជនជាប់ចោទ ខៀវ សំផន៖**

លោក គង់ សំអុន

កញ្ញា អង់តា ហ្គីសសេ

*(Ms. Anta GUISSÉ)*

**មេធាវីការពារជនជាប់ចោទ អៀង សារី៖**

លោក អាង ឧត្តម

លោក ម៉ៃខល កាណាវាស

*(Mr.Michael KARNAVAS)*

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

លោក ពេជ អង្គ

លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត

*(Ms. Elisabeth SIMONNEAU-FORT)*

លោក ឡៅ ជុនធី

លោក វ៉េន ពៅ

លោកស្រី បេនី យេ *(Ms. Beini YE)*

លោកស្រី ស៊ីន សុវ៉ន

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក អ៊ុំ អរុណ

លោកស្រី សួ សុទ្ធាវី

**បញ្ជីឈ្មោះអ្នកនិយាយ៖**

ភាសាដែលបានប្រើ លើកលែងតែមានការបញ្ជាក់ផ្សេងទៀតនៅក្នុងប្រតិចារឹក

| អ្នកនិយាយ | ភាសា |
|---|---|
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំ) | ខ្មែរ |
| ចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍ | អង់គ្លេស |
| ចៅក្រម ហ្សង់ម៉ាក ឡាវែន៍ | បារាំង |
| លោក ឌេល លីសាក់ | អង់គ្លេស |
| លោក សុន អរុណ | ខ្មែរ |
| លោក ហ្សាស្ព័រ ប៉ៅ | អង់គ្លេស |
| លោក ម៉ៃខល កាណាវាស | អង់គ្លេស |
| កញ្ញា អង់តា ហ្គីសសេ | បារាំង |
| លោក វីល្លៀម ស្មីត | អង់គ្លេស |
| លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត | បារាំង |
| លោក ខៀវ អេន (TCW-320) | ខ្មែរ |

# ឧបសម្ព័ន្ធ

**ការសួរសំណួរទៅសាក្សី÷ លោក ខៀវ អេន** (TCW-320)

សួរបន្តដោយ លោក សុន អរុណ ផ្ដើមពី៖.................................................................. ទំព័រ ២
សួរដោយលោក ហ្សាស្ដេី ប៉ៅ ផ្ដើមពី៖ ...................................................................... ទំព័រ ៩

# កិច្ចដំណើរការនីតិវិធី

*(ចៅក្រមចូលក្នុងបន្ទប់សវនាការ)*

[០៩:០២:០៩]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ ហើយជាដំបូងនេះ សូមលោកស្រី សែ កុលវុឌ្ឍី ឡើងរាយការណ៍អំពីស្ថានភាពវត្តមាន អវត្តមានភាគី និងបុគ្គលដែលអង្គជំនុំជម្រះអញ្ជើញឲ្យចូលរួមនៅក្នុងកិច្ចដំណើរសវនាការនេះ។

**ក្រឡាបញ្ជី៖**

សូមគោរពលោកប្រធាន គ្រប់ភាគីទាំងអស់នៅក្នុងរឿងក្ដីនេះមានវត្តមាន លើកលែងតែជនជាប់ចោទ អៀង សារី អវត្តមានដោយមូលហេតុសុខភាព។ ប៉ុន្តែជនជាប់ចោទបានស្នើសុំលះបង់សិទ្ធិមានវត្តមាននៅក្នុងដំណើរការសវនាការនៃការស្ដាប់សក្ខីកម្មសាក្សីTCW-320 និងសាក្សី TCW-428។ ដោយឡែក សាក្សី TCW-428 ដែលអង្គជំនុំជម្រះកោះហៅមកផ្ដល់សក្ខីកម្ម បន្ទាប់ពីបញ្ចប់ការស្ដាប់សក្ខីកម្មសាក្សី ខៀវ អេន មានវត្តមាននៅបន្ទប់រង់ចាំ រង់ចាំការកោះហៅពីអង្គជំនុំជម្រះ។ សាក្សីរូបនេះបានបញ្ជាក់ថា តាមសមត្ថភាពដែលគាត់អាចដឹង គឺគាត់មិនមានជាប់ទំនាក់ទំនងញាតិលោហិត ឬញាតិពន្ធជាមួយនឹងជនជាប់ចោទទាំងបីរូប គឺ នួន ជា, អៀង សារី និងខៀវ សំផន ឬភាគីដើមបណ្ដឹងរដ្ឋប្បវេណីណាមួយ ដែលត្រូវបានទទួលស្គាល់នៅក្នុងរឿងក្ដីនេះទេ។ សាក្សីនឹងធ្វើសម្បថនៅចំពោះមុខអង្គជំនុំជម្រះ។

[០៩:០៣:៥០]

**ប្រធានអង្គជំនុំ៖**

អរគុណ។ បាទ ជាកិច្ចបន្តអង្គជំនុំជម្រះសូមផ្ដល់វេទិកាជូនទៅក្រុមមេធាវីការពារក្ដីលោក នួន ជា ដើម្បីមានឱកាសសួរដេញដោលសាក្សីរូបនេះ។

សូមអញ្ជើញ!

**លោក សុន អរុណ៖**

សូមគោរពអង្គសវនាការ! សូមគោរពលោកប្រធាន!

**សួរបន្តដោយលោក សុន អរុណ៖**

**ស៖** សូមជម្រាបសួរលោកសាក្សី។ ខ្ញុំពីម្សិលមិញ ខ្ញុំមេធាវីលោក នួន ជា ខ្ញុំបានសួរលោក -- សំណួរលោកមួយចំនួនទៅហើយ។ ឥឡូវខ្ញុំមានសល់សំណួរតិចតួច ប្រហែលបីសំណួរប៉ុណ្ណឹងទៀតទេ។ សំណួរដូចតទៅនេះ៖ នៅក្នុងឯកសារលេខ 3/438 លោក -- ចៅក្រមស៊ើបអង្កេតបានសួរលោកថា "តើលោកមានបានដឹងអំពីការចូលរួមរបស់លោក នួន ជា ក្នុងការសរសេរទស្សនាវដ្ដីទង់បដិវត្ត និងយុវជនបដិវត្តដែរឬទេ?"

[០៩:០៥:០០]

ពេលនុ៎ងលោកបានឆ្លើយជម្រាបទៅខាងចៅក្រមស៊ើបអង្កេតថា "ខ្ញុំមិនដឹងពីការចូលរួមរបស់លោក នួន ជា ក្នុងការសរសេរទស្សនាវដ្ដីទង់បដិវត្ត និងទង់យុវជនបដិវត្ត តែលោកបានទទួលទស្សនាវដ្ដីទាំងពីរនេះរាល់ខែ"។ សំណួររបស់ខ្ញុំសូមសួរថា លោកសាក្សីបានអានទស្សនាវដ្ដីទង់បដិវត្តញឹកញាប់ទេ?

**លោក ខៀវ អេន៖**

**ឆ៖** ខ្ញុំសូមគោរពលោកប្រធាន! ខ្ញុំសូមឆ្លើយនូវសំណួរ បាទ មេធាវីរបស់លោក នួន ជា គាត់បានសួរបន្ថែម។ ចំពោះទង់នេះ ខ្ញុំហាក់ដូចជាមិនមានពេលអីអានច្រើនទេ អាហ្នឹងបើគិតថាឆ្នាំដែលរស់នៅកន្លែងមក តាមមើលប្រហែលជាពីរបីដងទេ។ ហើយក៏មិនដែលអានអីឲ្យបានថា ដឹងថាខ្លឹមសារហ្នឹងវាមានយ៉ាងម៉េចៗ ចប់ ដឹងរឿងចុងដើមទេ អត់ទេ។ បើខ្ញុំបញ្ជាក់ខាងដើមថា ខ្ញុំគិតតែរឿងការងារដែលផ្ទាល់ខ្លួនខ្ញុំ ដែលត្រូវទទួលខាងបច្ចេកទេសហ្នឹង។ ដល់អ៊ីចឹងអត់មានពេលវេលាទៅមើលទង់មើលអីហ្នឹងច្រើនទេ។ សូម --

[០៩:០៦:១៩]

ហើយទង់ដែលឃើញនេះ គឺថាឃើញជាការដែលចែកហើយ យកមកដាក់នៅកន្លែងក្នុងមន្ទីរខ្ញុំហ្នឹង។ តែដល់ការដែលខ្ញុំយកទង់ហ្នឹងមកមើល មកពិនិត្យពិចារណាអីយ៉ាងនេះយ៉ាងនោះ ច្រើនលើកច្រើនសា ចង់ដឹងថាសរសេរពីអី អត់មានបានដឹងទេ។ ហើយក្នុងការមើលដែលខ្ញុំថាប្រហែលម្ដងម្កាលក្នុងរយៈពេល១ឆ្នាំ ២ឆ្នាំហ្នឹង គឺថាមិនដែលបានចប់ ដឹងថាសាច់រឿងក្នុងទង់ហ្នឹង និយាយអីពីដើមមកដល់ចុងហ្នឹង អត់ដឹងផង។ ដល់អ៊ីចឹងខ្ញុំបញ្ជាក់ដោយខ្លីថា ខ្ញុំគិតខាងការងារបច្ចេកទេសរបស់ខ្ញុំហ្នឹងច្រើន ឯការងារក្រៅដែលៗគេមិនប្រគល់ឲ្យខ្ញុំ ខ្ញុំអត់យកចិត្តដាក់ទេ នេះសូមជម្រាបជូនខ្លីប៉ុណ្ណឹងបាទ។

**សៈ** អរគុណលោកសាក្សី ខ្ញុំសួរសំណួរខ្ញុំបន្តទៅទៀត។ លោកបានអានតិចតួចណាស់ ហើយមិនសូវមានការចងចាំទេក្នុងរឿងទង់បដិវត្ត និងយុវជនបដិវត្តនោះ។ ប៉ុន្តែលោកបានចំណាំទេ? លោកនៅចងចាំខ្លះទេ ថាទង់បដិវត្តហ្នឹងមានលក្ខណៈយ៉ាងម៉េច? ជាសៀវភៅ ឬក៏ជារបៀបកាសែត ឬទស្សនាវដ្តី? លក្ខណៈហ្នឹងយ៉ាងម៉េច? ហើយនិងក្របយ៉ាងម៉េច? ពណ៌អី? មានក្របខាងក្រៅហ្នឹងវាមានគូសវាស ឬក៏សរសេររបៀបម៉េច លោកចាំទេខាងក្រៅ?

[០៩:០៨:០៧]

**ឆៈ** ខ្ញុំសូមឆ្លើយនូវសៀវភៅនេះ។ បើគិតពេលវេលាដែលខ្ញុំមកឥឡូវនេះ ខ្ញុំគ្រាន់ថានៅចាំបានថា មានសញ្ញាទង់ជាតិ។ តែរឿងពណ៌រឿងស្អីៗហ្នឹង ហើយមិនដឹងថាទង់ហ្នឹងមានទង់ពីរៗផ្នែកអ៊ីចឹង ក៏អត់ដឹងដែរ តែគ្រាន់តែដឹងថាអង្កាល់មានទង់ជាតិ តែពណ៌ក៏ដូចជាលែងនឹកឃើញអីពណ៌សម្បុរយ៉ាងម៉េច ព្រោះដូចខ្ញុំបញ្ជាក់ខាងដើម ថាខ្ញុំមិនៗចាប់អារម្មណ៍រឿងអស់ហ្នឹង វាគិតតែរឿងការងាររបស់ឯងដែរ។ មកៗបញ្ជាក់រឿងហ្នឹង ខ្ញុំនឹកទៅវិញទៅក៏គ្រាន់តែដឹងអង្កាល់ហ្នឹងវាមានទង់ជាតិ ហើយទង់ជាតិក៏មិនដឹងជាទង់ហ្នឹងមានប៉ុន្មានទង់ទៀតណា។ ខ្ញុំនៅសល់តែប៉ុណ្ណឹងទេ ដែលត្រូវដឹងត្រូវជូន។ សូមអស់មតិបាទ។

**សៈ** លោកចាំមិនច្បាស់ តែលោក ខ្ញុំសួរសំណួរមួយទៀត លោកមិនចាំខាងក្រៅយ៉ាងម៉េចទេ ប៉ុន្តែខាងក្នុងអក្សរដែលលោកបានអានខ្លះរួចមកហើយនោះ។ អក្សរហ្នឹងសរសេរជាអក្សរដៃ ហើយយកទៅបោះពុម្ព ឬក៏វាយ*ដាក់ទីឡូ*?

[០៩:០៩:២៨]

**ឆៈ** ខ្ញុំសូមឆ្លើយ។ កន្លែងនេះខ្ញុំដូចជាស្រពេចស្រពិលអស់ហើយ តែខ្ញុំគ្រាន់តែគិតថា វាយដាក់ទីឡូច្រើនជាង និងខុសពីដាក់ទីឡូដូចជាមិនមានទេ។ ព្រោះខ្ញុំមកពីខ្ញុំលើកបញ្ហានេះ ដោយសារថាកាលជំនាន់ហ្នឹងគឺថាមានតែដាក់ទីឡូទេ ធ្វើការៗ។ នេះខ្ញុំសូមជូនប៉ុណ្ណឹងបាទ។

**សៈ** អរគុណ។ អំមិញលោកបញ្ជាក់ដូចជាមិនសូវច្បាស់ថា ដូចជាមានដាក់ទីឡូច្រើនជាង។ ច្រើនជាងមានន័យថាយ៉ាងម៉េច សូមបញ្ជាក់ឲ្យច្បាស់ជូនតុលាការ?

**ឆៈ** ខ្ញុំសូមបញ្ជាក់បន្ថែម ក្នុងន័យដែលខ្ញុំថា ដាក់ទីឡូច្រើនជាងនេះ ព្រោះខ្ញុំគិតទៅពេលហ្នឹងដែលខ្ញុំអ្នកជួសជុលអង្គុលីលេខដែរហ្នឹង ហើយអ្នកដែលធ្វើការនៅកន្លែងខ្ញុំហ្នឹងគឺ អ្នកដែលប្រើភាសាខ្មែរហ្នឹង គឺគេវាយតែដាក់ទីឡូហ្នឹងសម្រាប់បញ្ជូនឯកសារចុះឡើងហ្នឹង។ ដល់អ៊ីចឹងការចងចាំខ្ញុំវាៗមិន

ស្ងួវច្បាស់ តែខ្ញុំគ្រាន់តែគិតឃើញរបៀបដែលខ្ញុំនៅហ្នឹង គឺថាប្រើតែអង្គុលីលេខដែលវាយដៃហ្នឹង ហើយខ្ញុំក៏កំណត់ថា វាយដៃហើយហ្នឹង បានចេញទៅជាឯកសារយកទៅអូសធ្វើ។ អូសម៉ាស៊ីនទូរពុម្ព ម៉ាស៊ីនបោះពុម្ពនោះ។ នេះខ្ញុំៗ គិតទៅតាមកាលៈទេសៈហ្នឹងទេ។ បាទ ដោយសារថា ការងារដែលជុំវិញមន្ទីរខ្ញុំហ្នឹង គេវាយតែ*ដាក់ទីឡូ*ហ្នឹង។ អ៊ីចឹងខ្ញុំសូមបញ្ជាក់ប៉ុណ្ណឹងបាទ។

[០៩:១១:៣០]

**ស៖** អរគុណ។ ខ្ញុំឆ្លងទៅទំព័រថ្មីមួយទៀត នៅក្នុងឯកសារការសួរចម្លើយរបស់ចៅក្រមស៊ើបអង្កេតដដែលហ្នឹង លេខដដែល E3/438 ដដែលហ្នឹង បាន -- ចៅក្រមស៊ើបអង្កេតបានសួរលោកថា "តើគេមានកំណត់និយមន័យថា យ៉ាងម៉េចជាសារធាតុមិនល្អទេ? លោកឆ្លើយថា ខ្ញុំមិនដឹងទេ។ តែពេល នួន ជា ចូលមក គេបានណែនាំថា ឲ្យឈប់និយាយពីរឿងប្រជាជន១៧ មេសាទៀត គឺឲ្យឈប់និយាយពីប្រជាជនថ្មី និងប្រជាជនចាស់។ ខ្ញុំមិនដឹងថា ពាក្យថា សារធាតុមិនល្អ មានន័យយ៉ាងណាទេ។ ប៉ុន្តែមានមនុស្សបាត់ខ្លួនម្តងមួយៗជាបន្តបន្ទាប់។ បើខ្ញុំស្វែងយល់ខ្លួនឯង បើអ្នកណាជាបក្សជន ជាយុវកកបើមកតាមខ្សែមួយណា ហើយខ្សែនោះត្រូវបានចាប់ខ្លួន ពួកគេក៏ត្រូវបានចាប់ខ្លួនដែរ។ ហើយពេលនោះខ្ញុំជាបុគ្គលម្នាក់ដែលមកពីខាងបស្ចិម ទៅនៅក្នុងចំណោមពួកខ្សែបូព៌ា ហើយអ្នកដែលធ្វើការជាមួយខ្ញុំហើយត្រូវគេដកចេញទៅនោះ ភាគច្រើនជាខ្សែបក្ស -- បក្ខជន ឬយុវកក"។ ត្រង់សំណួរមួយទៀត -- ត្រង់ សួរនិងឆ្លើយមួយវគ្គទៀតថា "តើគោលនយោបាយនេះគេបន្តអនុវត្តដល់ពេលណា?" ពេលនោះលោកឆ្លើយថា "គោលនយោបាយនេះ នៅជិតដាមរហូត ទោះបីជា នួន ជា ចង់ឲ្យលែងនិយាយពីបញ្ហាបែងចែកប្រជាជនថ្មី និងប្រជាជនចាស់ក៏ដោយ។ ហើយក៏នៅមានការបាត់ខ្លួនជាបន្តបន្ទាប់ដដែល។ បើតាមខ្ញុំយល់ខ្លះ គឺថា អ្នកខាងនិរតី គឺជាអ្នកបដិវត្តន៍ល្អ ហើយក្រោយពេលពួកបូព៌ា និងពួកបស្ចិមត្រូវបានបោសសម្អាត ភាគច្រើនគេបញ្ជូនពួកនិរតីទៅជំនួស"។ នេះជាអត្ថបទដែលមានសរសេរទុកមកខ្ញុំបាន -- ខ្ញុំក៏នៅក្នុងអត្ថបទទាំងនេះ ខ្ញុំសូមសួរលោកដូចតទៅនេះ៖

[០៩:១៤:០៧]

ពាក្យថា "អ្នកខាងនិរតី ជាអ្នកបដិវត្តន៍ល្អ ហើយក្រោយពេលពួកបូព៌ា និងពួកបស្ចិមត្រូវបានបោសសម្អាត ភាគច្រើនគេបញ្ជូនពួកនិរតីទៅជំនួស"។ ខ្ញុំសួរថា នៅលើការពិសោធអ្វី ដែលលោកអាចនិយាយថា អ្នកខាងនិរតីជាអ្នកបដិវត្តន៍ល្អ?

**ឆ៖** ខ្ញុំសូមឆ្លើយនូវសំណួរនេះបន្ថែម ដោយកាលពីម្សិលមិញក៏នៅមិនទាន់បានអស់ចម្ងល់ក្នុងការឆ្លើយរបស់ខ្ញុំ។ សំណួរនេះបានសួរទាក់ទងនឹងការដកកម្លាំងដែលចេញពីកន្លែងខ្ញុំ រវាងកម្លាំងមកពីបូព៌ា និងនិរតី ហើយគាត់ចង់បញ្ជាក់បន្ថែមពីរឿងថា ដកខាងបូព៌ាហើយ តើនិរតីយ៉ាងម៉េចបានជាថានិរតីជាអ្នកបដិវត្តន៍ល្អ? ចម្លើយនេះ ខ្ញុំសូមឆ្លើយ ឆ្លើយក្នុងសភាពការណ៍ពេលដែលខ្ញុំរស់នៅហ្នឹងគឺ ខ្ញុំមិនមែនជាអ្នកអនុវត្ត ខ្ញុំជាដឹង ជាអ្នកចេញទៅដើរហើរទេ តែគ្រាន់តែថា ឮពីអ្នកដែលដើរហើរមកវិញកាលហ្នឹងដឹងថា ខាងបូព៌ាគេយកគណៈភូមិភាគ ចង់ភ្លេចឈ្មោះហើយ គ្រាន់តែដឹងថា វាទាក់ទងនឹងខាងភូមិភាគ។ ហើយដល់មានប៉ះពាល់ឮខាងភូមិភាគទៅ ដល់អ៊ីចឹងកម្លាំងនៅខាងខ្ញុំហ្នឹងក៏សុទ្ធតែភូមិភាគខាងនុ៎ង ដល់អ៊ីចឹងឃើញគេដកពួកហ្នឹងចេញទៅ ដល់អ៊ីចឹងក៏បញ្ចូលមកវិញពេល យុន យ៉ាត មកទទួល យុន យ៉ាត ឃើញកម្លាំងសុទ្ធតែមកពីនិរតីមកវិញ។ ដល់អ៊ីចឹងអ្នកដែលគេនៅហ្នឹង ខ្ញុំមិនមានអ្នកដើរ អ្នកឃើញទៅដឹងរឿងអីក្រៅអត់ទេ។ តែគ្រាន់តែអ្នកនៅហ្នឹងថា អ្ហឺ! បូព៌ាមានបញ្ហាអ៊ីចុះ ឥឡូវគេដកអស់ហើយ ឥឡូវគេយកនិរតីមក។ នេះជាការដឹង ការឃើញនឹងកម្លាំងជាក់ស្តែងរបស់ខ្លួនទេ។ បាទ ឲ្យទៅដឹងរឿងក្រៅអីដែលបានដើរហើរទៅឃើញអត់ទេ។ គឺខ្ញុំដឹងនៅក្នុងការដែលធ្វើការងារហើយឃើញ ឃើញកម្លាំងយកចេញទៅ និងយកចូលមកនេះទេ។ ហើយដោយសារការដែលឮខាងបូព៌ាមានបញ្ហាខាងភូមិភាគហ្នឹង ស្រាប់តែឃើញបាត់កម្លាំងពីខាងបូព៌ាដែលធ្វើការជាមួយខ្ញុំហ្នឹងចេញអស់ទៅ អ៊ីចេះ។ នេះខ្ញុំសូមជូនមតិប៉ុណ្ណឹងបាទ។

[០៩:១៧:១៤]

**ស៖** លោកគ្រាន់តែឃើញខាងបូព៌ា និងបស្ចិមចេញអស់ លោកសន្និដ្ឋានថា និរតីជាអ្នកបដិវត្តន៍ល្អ។ ម៉េចក៏លោកសន្និដ្ឋានអ៊ីចឹងទៅវិញ? បដិវត្តន៍ក្រែងបដិវត្តន៍ទាំងអស់គ្នាមួយនគរ ហើយលោកសន្និដ្ឋានថា ឲ្យតែខាងនិរតីហ្នឹងល្អតែមួយភូមិភាគអ៊ីចឹង អាហ្នឹងលោកយល់យ៉ាងម៉េចបានជាលោកសន្និដ្ឋានថា អ៊ីចឹង?

**ឆ៖** ខ្ញុំសូមឆ្លើយ។ ភាសានិយាយល្អនិយាយអាក្រក់នេះគឺថា ខ្ញុំបានបញ្ជាក់នេះតែភាសានេះមិនមែនជាភាសារបស់ខ្ញុំផ្ទាល់ដែលមក -- បញ្ជាក់ថា អ្នេខាងនេះល្អ ខាងនោះល្អអាក្រក់ទេ។ ភាសានេះខ្ញុំឮពីគេមកវិញទេ។ ឮពីអ្នកដែលគេដើរហើរមកវិញទេ។ ឯខ្ញុំអ្នកនៅនឹងកន្លែងហ្នឹង គឺខ្ញុំមិនបានទៅបែកចែកយ៉ាងម៉េចទេ តែដល់ឮគេថា អ៊ីចឹងហើយ ខ្ញុំមកឃើញកម្លាំងជាក់ស្តែងដែលនៅនឹងខ្ញុំហ្នឹងឃើញគេចេញទៅអស់។ គេដកទៅអស់ក៏ខ្ញុំគិតខ្លួនឯងថា អ្ហឺ! គេថាហ្នឹងវាយ៉ាងម៉េចអីយ៉ាងម៉េច ដល់យើងវាមិន

បានដើរហើរ តែគ្រាន់តែសកម្មភាពជាក់ស្ដែងនៅកន្លែងខ្ញុំវាឃើញអ៊ីចឹង។ ឯខ្ញុំវិនិច្ឆ័យទៅ នេះអំមិញ ហ្នឹងរឿងខាងលើគេដកអីម៉េច អាហ្នឹងខ្ញុំអត់ដឹងអីទាំងអស់។ ហើយការដើរហើរទៅឃើញខាងក្រៅក៏អត់ដឹង។ ដឹងតែត្រឹមមនុស្សដែលមានការងារនឹងផ្ទាល់ទេ ឃើញគេយកចេញទៅហើយក៏បញ្ចូលអ្នកនោះមកពីខាងនិរតីមកវិញ។ នេះដឹងតែប៉ុណ្ណឹង ហើយនិងឮពីក្រៅមកគិតខ្លួនឯងទេបាទ។

[០៩:១៨:៥៦]

**ស៖** អរគុណ។ ខ្ញុំ -- នេះជាសំណួរចុងក្រោយរបស់ខ្ញុំ។ ខ្ញុំសូមសួរថា លោកបានធ្វើការនៅក្រោមការគ្រប់គ្រងរបស់លោក នួន ជា ជាចុងក្រោយបំផុតដែលរដ្ឋមន្ត្រីពីរកន្លងហួសទៅហើយនុ៎ងបានចាកចេញហើយ ហើយ នួន ជា ចូលមកចុងក្រោយបំផុត។ តើលោកបានធ្វើការនៅក្រោមការគ្រប់គ្រងរបស់ នួន ជា ហ្នឹងប៉ុន្មានខែប៉ុន្មានឆ្នាំ អស់រយៈពេលប៉ុន្មាន?

**ឆ៖** ខ្ញុំសូមឆ្លើយនឹងសំណួរនេះ តែខ្ញុំគ្រាន់តែកាលបរិច្ឆេទថ្ងៃពេលខែមិនច្បាស់ តែខ្ញុំគ្រាន់តែដឹងថា កាលដែល យុន យ៉ាត ហ្នឹងឈប់ ហើយ នួន ជា គាត់មកទទួល ប្រហែលជាចុង៧៨។ រត់ចេញហ្នឹង។ អ៊ីចឹងប្រហែលជាចុង៧៨ អាហ្នឹង ខ្ញុំមិនដឹង ប៉ុន្តែអាចចន្លោះពីពាក់កណ្ដាល៧៨ហ្នឹង មកក្រោយមិនមែនទៅមុខទេ ខ្ញុំគ្រាន់តែគិត គ្រាន់តែពេលវេលាដែលគាត់មកទទួលហ្នឹង ពេលខ្លីដែរទេ។

**ស៖** ពីម្សិលមិញ លោកបានឆ្លើយ -- ខ្ញុំសួរៗ ផ្ទាល់ថា នៅក្នុងបក្សហ្នឹង -- នៅក្នុងកម្ពុជាប្រជាធិបតេយ្យហ្នឹង មានពីររចនាសម្ព័ន្ធរបស់គេមានពីរបក្ស -- មានពីរក្រុម។ មួយក្រុម គឺរដ្ឋបាលមួយក្រុម គឺបក្ស។ ហើយដល់ចុងក្រោយមក លោកបានឆ្លើយប្រាប់ខ្ញុំ ថា នួន ជា លោកធ្លាប់ឮគេថាគាត់ជាប្រធានរដ្ឋសភា។ តើចម្លើយហ្នឹង ខ្ញុំរំឭកឡើងវិញ តើលោកឆ្លើយអ៊ីចឹងត្រឹមត្រូវទេពីម្សិលមិញ?

[០៩:២១:០៧]

**ឆ៖** ខ្ញុំគ្រាន់តែដឹងថា អាហ្នឹងប្រហែលជាខ្ញុំភ្លេចក៏មិនដឹងអីមិនដឹង ប៉ុន្តែខ្ញុំគ្រាន់តែដឹង ម្សិលមិញហ្នឹង ខ្ញុំមាននិយាយ ថាគាត់ទទួលផ្នែកខាងសភាដែរ។ តែជាប្រធានអីហ្នឹង ខ្ញុំដូចជាភ្លេចមិនដឹងអីមិនដឹង អាហ្នឹងព្រោះខ្ញុំ អានេះ តែគ្រាន់ថាការងារខាងសភា គាត់ត្រូវទទួល។ ហើយខ្ញុំបានបញ្ជាក់ថាពីរឿងថាគាត់ជាគណៈអចិន្ត្រៃយ៍ទៀត បាទ។

**ស៖** ពេលរយៈពេលខ្លី ដែល នួន ជា បានមកគ្រប់គ្រងក្រសួង បើតាមឯកសារ ហើយតាមចម្លើយរបស់លោកជាមួយនឹងចៅក្រមស៊ើបអង្កេតថា នួន ជា មកកាន់ជារដ្ឋមន្ត្រី ឬគ្រប់គ្រងក្រសួងឃោសនាការ និងព័ត៌មាន។ លោកឆ្ងល់ទេ ថាតើហេតុអីបានជាមកកាន់ក្រសួងហ្នឹងវិញ បើលោកជា

នៅគណៈអចិន្ត្រៃយ៍ ហើយលោកជាប្រធានរដ្ឋសភា -- លោកជា ថាប្រធានរដ្ឋសភាអ៊ីចឹង ព្រោះឯកសារដាក់ប្រធានអ៊ីចឹងមែន។ ប្រធានរដ្ឋសភានោះ លោកមានការងឿងឆ្ងល់ ការយល់ ឬក៏យ៉ាងម៉េចទេ ថាហេតុអីបានជាមកកាន់ក្រសួងព័ត៌មានអ៊ីចឹង រួចក្រសួងព័ត៌មានជាសាខារបស់រដ្ឋាភិបាល?

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយ!

សូមអញ្ជើញតំណាងសហព្រះរាជអាជ្ញា!

**លោក ឌេល លីសាក់៖**

លោកប្រធាន យើងខ្ញុំជំទាស់ទៅនឹងសំណួរនេះ ដែលសំណួរនេះ ហាក់ដូចជាឲ្យសាក្សីនេះស្មាន។ ដូច្នេះហើយ ខ្ញុំគិតថា នេះគឺអ្វីដែលសាក្សីគាត់មិនបានដឹងនោះទេ ហើយវាជាការសួរឲ្យសាក្សីទាយស្មានតែប៉ុណ្ណោះ។

[០៩:២៣:០៩]

**លោក សុន អរុណ៖**

ខ្ញុំមិនបានសួររឿងថាសាក្សី -- សាក្សីអត់ទាន់ឆ្លើយថា មិនដឹង លោក នួន ជា គាត់បានឆ្លើយហើយ ថាគាត់ឮគេថា នួន ជា ជាសមាជិកអចិន្ត្រៃយ៍ ហើយនិងប្រធានរដ្ឋ -- ហើយនិងសភា។ គាត់គ្រាន់មិនដឹង គាត់មិនដឹងពីរឿងថាប្រធាន ឬមិនប្រធានទេ។ ហ្នឹង តាមចម្លើយរបស់គាត់អំមិញអ៊ីចឹង។ ដល់អ៊ីចឹងទៅ ខ្ញុំថាបើ ខ្ញុំសួរថា បើតាមគាត់ដឹង គាត់ជាប្រធាន អំ! គាត់ជាសមាជិកអចិន្ត្រៃយ៍ ហើយគាត់ជា ធ្វើការនៅក្នុងសភា ប៉ុន្តែមិនដឹងជាប្រធាន ឬមិនប្រធានទេ។ អាហ្នឹងតាមឆ្លើយរបស់គាត់។ ខ្ញុំសួរបន្តថា ហេតុអីលោកមានឆ្ងល់ថា តើហេតុអីបានជាគាត់មកកាន់ក្រសួងមួយ ក្រសួងហ្នឹងជាសាខារបស់រដ្ឋាភិបាល។ អានេះ សំណួររបស់ខ្ញុំអ៊ីចឹង។

**ប្រធានអង្គជំនុំ៖**

លោកអាចរៀបចំនូវសំណួរសាជាថ្មីទៀត សំណួរដែលលោកសួរហ្នឹង មិនទំនងនោះទេ នៅក្នុងការតាំងសំណួរបែបនេះ។

**សួរដោយលោក សុន អរុណ៖**

**ស៖** ខ្ញុំសូមបន្តសំណួរ ខ្ញុំសូមលុបចោល ខ្ញុំសូមរំលងសំណួរអំមិញ។ ក្នុងរយៈពេលលោកធ្វើការនៅក្រោមការគ្រប់គ្រងរបស់លោក នួន ជា ក្នុងរយៈពេលខ្លី អាហ្នឹង យោងតាមឯកសារ និងចម្លើយ

របស់លោកជាមួយថៅក្រមស៊ើបអង្កេត។ រយៈពេលខ្លីនេះ លោកស្គាល់ លោកដែលបានជួបលោក នួន ជា ញឹកញាប់ទេ? ហើយបានស្គាល់គាត់ប្រាកដប្រជាទេ ព្រោះក្នុងឋានៈលោក នួន ជា ជាមេរបស់លោក?

[០៩:២៥:០០]

**ឆ៖** ខ្ញុំសូមឆ្លើយនូវសំណួរនេះ។ ហើយសំណួរនេះហាក់ដូចជាម្សិលមិញបានបញ្ជាក់ខ្លះហើយ ពីកាលវេលាដែលស្គាល់អីៗហ្នឹង ការទំនាក់ទំនងហ្នឹងគ្រាន់តែ -- បើចង់ឲ្យខ្ញុំបញ្ជាក់បន្ថែមទៀត ក៏ខ្ញុំសូមបញ្ជាក់បន្ថែមថា រវាងខ្ញុំនិងលោក នួន ជា គឺហៅថា "ការស្គាល់ ខ្ញុំស្គាល់" តែជាការជិតស្និទ្ធជាប់ជាមួយគាត់ អត់ទេ។ តែខ្ញុំបញ្ជាក់ថា ការស្គាល់នេះ ស្គាល់ក្នុងន័យថា ខ្ញុំយកឯកសារពេលខ្លះ យកទៅជួបអ្នកផ្សេងដែលគេត្រូវទទួល ខ្ញុំជូនគេ ព្រោះអាហ្នឹងគេអ្នកជាប់។ តែដល់ខ្ញុំ គ្រាន់តែស្គាល់នោះជា នួន ជា បាទ តែដល់ៗគេអត់នៅខ្ញុំជូនគាត់ តែដែល ខ្ញុំបញ្ជាក់ថាឲ្យទៅជាការជាប់លាប់ ការជាក់លាក់ជាមួយគាត់នឹងការងារអីហ្នឹង អត់ទេ។ បានន័យថាការងារខ្ញុំ ការងារគាត់ រឿងគាត់ ហើយខ្ញុំមិនៗជា ហៅថា អ្នកនៅផ្ទាល់ នៅអីទេ ហៅថា ការងារជាប្រយោល ហើយមានអ្នកបន្តបន្ទាប់សម្រាប់ខ្ញុំធ្វើការជាមួយ។ ដល់អ៊ីចឹង ស្គាល់ជាមួយគាត់ ស្គាល់បានត្រឹមថា គាត់ហៅថា ម្តងម្កាល គាត់ត្រូវប្រជុំត្រូវអ៊ីចឹងបានទៅឃើញគាត់។ នេះខ្ញុំបញ្ជាក់ក្នុងន័យអ៊ីចឹងទេ ដែលថាស្គាល់ណា។ ហើយបើទៅជាការដឹងរឿងអី ពីរឿងថាវែងឆ្ងាយទៀត ខ្ញុំអត់មានដឹង។ សូមអស់មតិប៉ុណ្ណឹងបាទ។

[០៩:២៧:១០]

**ស៖** អរគុណ។ ក្នុងឋានៈលោកជាអ្នកធ្វើការក្រោមបង្គាប់គាត់ យោងតាមឯកសារដែលមាន យោងតាមចម្លើយរបស់លោកជាមួយថៅក្រមស៊ើបអង្កេត លោកបានស្គាល់គាត់ជាប្រយោលមានន័យថា មិនបានជិតដិត ហើយលោកសម្គាល់ឃើញថា លោក នួន ជា ហ្នឹង មិនជាមនុស្សមានលក្ខណៈយ៉ាងម៉េច គាត់ជាមនុស្សមានលក្ខណៈចរិតឃោរឃៅ កាប់សម្លាប់ ចាប់មនុស្ស បញ្ជូនមនុស្សយកទៅធ្វើទោសពៃដាក់គុក ដាក់ច្រវាក់ សម្តីគាត់ឃោរឃៅ ឬក៏គាត់ជាមនុស្សល្អ គួរគោរពក្នុងឋានៈជាអ្នកដឹកនាំ គាត់ជាមនុស្សម្នាក់ដែលមានចរិតដឹកនាំទៅតាមឧត្តមគតិជាតិរបស់គាត់ ឬក៏គាត់ជាមនុស្សជាតិនិយម ដែលគួរឲ្យគោរព?

**ឆ៖** ខ្ញុំសូមឆ្លើយនូវសំណួរនេះ។ ការឆ្លើយរបស់ខ្ញុំ ខ្ញុំមិនមានលទ្ធភាពវិនិច្ឆ័យ វាយតម្លៃថាគាត់យ៉ាងម៉េចៗអីទេ ខ្ញុំៗមិនមាន គេហៅថា កម្រិតគេឲ្យតម្លៃគាត់យ៉ាងម៉េចទេ។ តែគ្រាន់តែខ្ញុំនិយាយពី

សកម្មភាពជាក់ស្ដែងដែលរបស់ -- ជាក់ស្ដែងដែលនៅកន្លែងខ្ញុំ តែឯការងារខាងក្រៅអីទៀត អាហ្នឹង គាត់ធ្វើទៀត ខ្ញុំអត់ដឹងទេ។ ខ្ញុំមិនមានទៅប៉ាន់វាយតម្លៃអីថា គាត់អ៊ីចេះអ៊ីចុះអីទេ តែគ្រាន់ថាដល់ជាក់ស្ដែងជាមួយកន្លែងខ្ញុំ ខ្ញុំគ្រាន់តែឃើញថា ក្នុងន័យកាលហ្នឹងគឺថា ជាន័យមួយគឺហៅថា ពាក្យថា "ម៉ឺងម៉ាត់"។ បាទ ម៉ឺងម៉ាត់ បានន័យថា ធ្វើអីឲ្យប្រាកដប្រជា។ ខ្ញុំៗនិយាយអ៊ីចឹង។ ហើយមួយទៀត ខ្ញុំគ្រាន់តែនិយាយថា ការរស់នៅក្នុងការហូបចុក គាត់មានការគិតច្រើន តាំងពីការដេកពួន តាំងពីការពិសាបារីអីឡើង គាត់ហាមឃាត់មិនឲ្យពិសា នេះដែលខ្ញុំនៅចងចាំ អាហ្នឹងខ្ញុំនិយាយតែម៉ាត្រឹមត្រូវដែលខ្ញុំដឹង ខ្ញុំចាំមកដល់ពេលនេះគឺថា តាំងពីបារីអីហ្នឹង គាត់ហាមមិនឲ្យជក់ ឲ្យអី ការដេកពួនស្នាក់នៅអី គាត់ឲ្យខំក្រោកហាត់ប្រាណ ហាត់អី ពីព្រឹកព្រាងអីហ្នឹង។ នេះជាការឃើញជាក់ស្ដែង និងជួបប្រទះខ្លួនខ្ញុំជាមួយគាត់ ដែលៗគាត់ទៅដល់កន្លែងហើយ គាត់ដើរមើលហើយ គាត់ចេះតែក្រើនរំឭករឿងហ្នឹង។ តែឲ្យដឹងទៅជាជម្រៅអី ដែលគាត់អត់ចូលកន្លែងខ្ញុំផង ហើយគាត់ទៅនៅក្រៅអីឯណាណោះ អាហ្នឹងខ្ញុំទៅថាគាត់យ៉ាងនេះ យ៉ាងនោះ ខ្ញុំនិយាយអត់កើត។ ខ្ញុំឃើញតែសកម្មភាពដែលកន្លែងខ្ញុំ។ ខ្ញុំដឹងតែប៉ុណ្ណឹង។ ខ្ញុំជម្រាបជូនប៉ុណ្ណឹងបាទ អរគុណ។

**លោក សុន អរុណ៖**

ខ្ញុំអស់សំណួរហើយលោកប្រធាន។ ខ្ញុំសូមអរគុណ ហើយនិងអរគុណលោកសាក្សី។ ខ្ញុំមាន -- សហភាតាខ្ញុំនឹងមានសំណួរបន្តទៅទៀត។

[០៩:៣០:៥១]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ សូមអញ្ជើញលោកមេធាវី!

**លោក ហ្សាស្តេ ប៉ៅ៖**

សូមអរគុណលោកប្រធាន។ សូមជម្រាបសួរអស់លោក លោកស្រីទាំងអស់នៅក្នុងសាលសវនាការ ហើយជាពិសេស សូមជម្រាបសួរលោកសាក្សី ខៀវ អេន។

**សួរដោយលោក ហ្សាស្តេ ប៉ៅ៖**

**ស៖** ខ្ញុំឈ្មោះ ហ្សាស្តេ ប៉ៅ។ ខ្ញុំជាមេធាវីការពារក្ដីអន្តរជាតិសម្រាប់លោក នួន ជា។ ខ្ញុំសូមធ្វើការចោទសួរលោកបន្ថែមទៅលើសក្ខីកម្មរបស់លោក ផ្អែកទៅលើចម្លើយដែលលោកបានផ្ដល់កាលពីពេលមុន។ ខ្ញុំនឹងនិយាយឲ្យបានយឺតៗ ដើម្បីងាយស្រួលដល់ការបកប្រែ។ ក្នុងករណីដែលលោកមិន

ច្បាស់អំពីសំណួររបស់ខ្ញុំ សូមលោកធ្វើការសួរបញ្ជាក់។ សំណួរទី១របស់ខ្ញុំ គឺពាក់ព័ន្ធទៅនឹងការសម្ភាសដែលលោកធ្វើជាមួយអ្នកស៊ើបអង្កេតនៃការិយាល័យសហចៅក្រមស៊ើបអង្កេត។ នៅពេលអ្នកស៊ើបអង្កេតបានមកសម្ភាសលោក តើគាត់មានបានពន្យល់ដែរឬទេ ថាហេតុអ្វីបានជាគាត់ចង់សម្ភាសលោក?

[០៩:៣២:២០]

**លោក ខៀវ អេន៖**

**ឆ៖** ខ្ញុំសូមឆ្លើយ ការដែលគេទៅស៊ើបអង្កេតថា ចង់សម្ភាសជាមួយខ្ញុំ។ គេមិនមានការបង្ខិតបង្ខំ ហើយគេឲ្យខ្ញុំតែនិយាយអីដែលជាការពិត ដែលខ្ញុំដឹង និងឮ និងចាំ។ ហើយអ៊ីចឹងបានខ្ញុំមកបញ្ជាក់មកថ្ងៃនេះ គឺថាស្អីដែលខ្ញុំចាំ ខ្ញុំឮ ខ្ញុំៗលើកឡើងបញ្ហាហ្នឹង។ ហើយស្អីដែលខ្ញុំនៅស្រពេចស្រពិល ខ្ញុំបញ្ជាក់ថាស្រពេចស្រពិល ដូចជាមិនច្បាស់ ហើយកន្លែងខ្លះ ខ្ញុំអត់លើកមក។ អ៊ីចឹងខ្ញុំឆ្លើយនៅមុខអង្គចៅក្រមនេះ គឺថាជាពាក្យពិតស្មោះត្រង់របស់ខ្ញុំ ដែលខ្ញុំនៅសល់ការចងចាំប៉ុនណា ខ្ញុំនិយាយប៉ុណ្ណឹង។ ហើយក៏ខ្ញុំមិនមានបំណងអីទៅថា ខ្ញុំទទួលខាងនេះ ខាងនោះ ឬមួយការបង្ខិតបង្ខំអីខាងណា អត់ទេ។ ព្រោះខ្ញុំគិតថា ខ្ញុំជាមនុស្សអាជ្ញាកណ្ដាលមួយដែល ដើម្បីផ្សំអាចឆ្លើយហ្នឹងដោះស្រាយនៅក្នុងតុលាការហ្នឹង។ ដល់អ៊ីចឹង ខ្ញុំបញ្ជាក់ជូនប៉ុណ្ណឹងថា ការដែលធ្វើគឺ ដោយការស្ម័គ្រចិត្ត ឲ្យចម្លើយ តែអង្គាល់ហ្នឹងខ្ញុំគ្រាន់តែសុំសិទ្ធិមួយថា ខ្ញុំមិនចង់មកបំភ្លឺនៅទីនេះទេ។

[០៩:៣៤:០៥]

បាទ ថាខាង ចង់និយាយថា ខាងចៅក្រម ខាងរដ្ឋាភិបាលរៀបចំធ្វើយ៉ាងម៉េច ធ្វើទៅ។ ខ្ញុំមិន -- ហើយក្នុងហ្នឹង ខ្ញុំមានពាក្យមួយថា "ឥឡូវធ្វើយ៉ាងម៉េចក៏ដោយ ធ្វើម៉េចខាង អ.វ.ត.ក ហ្នឹងរកកន្លែងជ្រុងឲ្យខ្មែរចម្រើន ឲ្យខ្មែរកុំកើតរឿងទៀត"។ នេះខ្ញុំចង់បានតែប៉ុណ្ណឹងទេ។ ដល់អ៊ីចឹងខ្ញុំឲ្យចម្លើយនេះ ក៏ខ្ញុំមិនចង់ថា កាន់ខាងនេះ ខាងនោះដែរ ធ្វើម៉េចឲ្យតែដោះស្រាយបញ្ហាហ្នឹងឲ្យស្រួល។ នេះខ្ញុំសូមមានមតិប៉ុណ្ណឹង។

**ស៖** សូមអរគុណលោក ខៀវ អេន។ ខ្ញុំចង់បញ្ជាក់ថា តាមចម្លើយរបស់លោកកាលពីម្សិលមិញ គឺបានបញ្ជាក់ច្បាស់ដែលថា លោកមិនធ្វើការប៉ាន់ស្មាននោះទេ។ ហើយយើងសូមថ្លែងអំណរគុណហើយយើងសូមឲ្យលោកកុំធ្វើការប៉ាន់ស្មានផងដែរនៅថ្ងៃនេះ នៅពេលដែលខ្ញុំធ្វើការចោទសួរ ទៅលើលោក។ សំណួរដែលខ្ញុំចង់សួរលោក គឺជាសំណួរមួយផ្សេងដែលខ្ញុំសូមលើកឡើងវិញ ហើយខ្ញុំស្នើសុំ

ឲ្យលោកជួយឆ្លើយនូវសំណួររបស់ខ្ញុំ។ សំណួររបស់ខ្ញុំ គឺថាតើអ្នកស៊ើបអង្កេតនៃការិយាល័យសហចៅក្រមស៊ើបអង្កេតបានពន្យល់ដែរឬទេ ថាហេតុអ្វី ថាតើមូលហេតុអ្វីដែលពួកគេចង់សម្ភាសរូបលោក? តើលោកដឹងដែរឬទេ ថាតើគេធ្វើយ៉ាងណាបានរកលោកឃើញ? ថាតើហេតុអ្វីបានជាគេមកសុំឲ្យលោកផ្តល់សក្ខីកម្មបែបនេះ?

[០៩:៣៥:៥៦]

**ឆ៖** សំណួរនេះ ខ្ញុំគ្រាន់តែឆ្លើយបន្ថែមទៀត បើខាងលោកមិនៗអស់ចម្ងល់។ ខ្ញុំបញ្ជាក់ថា ជាបុគ្គលខ្ញុំម្នាក់ ខ្ញុំមិនៗចង់មកៗៗ ធ្វើអីទេ គឺថាតែសម្រាប់ប្រទេសជាតិទាំងមូលរៀបចំយ៉ាងម៉េច រៀបទៅ តែដល់ពេលដែលធ្វើហើយវាត្រូវការរូបខ្ញុំ ខ្ញុំក៏ស្ម័គ្រចិត្តសម្ភាស។ នេះៗជាទឹកចិត្តរបស់ខ្ញុំផ្ទាល់បាទស្ម័គ្រចិត្តសម្ភាសជាមួយ។ ហើយដល់សម្ភាសហើយ ខ្ញុំបានសូមសិទ្ធិមួយថា ឥឡូវបើសម្ភាស ហើយបានជាចម្លើយពីខ្ញុំខ្លះហើយ ខ្ញុំសូមសិទ្ធិមួយថាខ្ញុំមិនបាច់មកបំភ្លឺនៅសវនាការយ៉ាងម៉េច។ គេថា អេ្ហ! អត់បានទេ ឈ្មោះខ្ញុំត្រូវមកនេះ។ ហើយដល់អ៊ីចឹងខ្ញុំក៏ -- ហើយការរកឃើញមិនរកឃើញខ្ញុំអីយ៉ាងម៉េចៗ អានេះវាៗខាងលើ ខាងលើគេរៀបចំយ៉ាងម៉េចដើម្បីស្រាវជ្រាវ អាហ្នឹងខ្ញុំអត់ដឹង។ ស្រាប់តែទៅជួបខ្ញុំ សួរទៅដឹងថា គេរកឯងឃើញដែរតើ! ដឹងថាឯង ដឹងថាខ្ញុំនៅឯណាៗពីមុនមក។ ហើយដល់សម្ភាស ខ្ញុំសុខចិត្តឲ្យសម្ភាស។ នេះខ្ញុំសូមជូនមតិប៉ុណ្ណឹងបាទ។

**ស៖** សូមអរគុណ។ ខ្ញុំគិតថា នេះជាផ្នែកមួយនៃចម្លើយដែលលោកផ្តល់ឲ្យខ្ញុំ។ ឥឡូវនេះខ្ញុំសូមសួរបន្ថែមបន្តិចទៅលើចំណុចនេះ។ លោកបាននិយាយថា អ្នកស៊ើបអង្កេតនៃតុលាការបានរកឃើញ តើលោកអាចពន្យល់បន្ថែមដែរឬទេ ថាតើលោកបានទទួលការទូរ -- ទទួលទូរសព្ទ ឬមួយក៏មានអ្នកណាម្នាក់មកជួបលោកនៅក្នុងភូមិ មកគោះទ្វារលោក? តើលោកអាចពន្យល់បានដែរទេ ថាតើពួកគេហ្នឹងរកឃើញលោកហ្នឹងដោយរបៀបណាដែរ?

[០៩:៣៨:២៦]

**ឆ៖** ខ្ញុំសូមឆ្លើយបន្ថែម។ ខ្ញុំឃើញសំណួរនេះសួរទៅ -- អ៊ូ ខ្ញុំមិនបដិសេធទេ តែគ្រាន់ថាការឆ្លើយទៅវាហាក់ដូចជាការរកហ្នឹងវាលំបាក វាចង្អៀតដូចពេលសម័យរាប់សិបឆ្នាំមុន។ ដល់អ៊ីចឹងខ្ញុំគ្រាន់តែឆ្លើយបន្ថែមចុះថា ខ្ញុំ ក្នុងគ្រាន់ទស្សនៈខ្ញុំទេ គឺថាសួរហាក់ដូចជា២០, ៣០, ៤០ ឆ្នាំមុន តែដល់ឥឡូវវាអត់អ៊ីចឹង ហើយដល់អ៊ីចឹងខ្ញុំក៏គិតថា ការដែលរកខ្ញុំគ្មាន គេដឹងថាខ្ញុំនៅអីនេះ គ្មានអ្នកណាទៅគោះទៅផ្តល់អីរក បង្ខំឲ្យខ្ញុំឆ្លើយអី អត់ទេ។ តែការពិតវាថា យើងលក្ខណៈថាជួប ការនិយាយការអី

ដែលទំនាក់ទំនងនេះ គឺថាក្នុងលក្ខណៈមួយវាៗ យើងទទួលបានទាំងអស់គ្នា។ អានេះខ្ញុំនិយាយអ៊ីចឹងថា ទទួលបានទាំងអស់គ្នា អ្នកមកទំនាក់ទំនងខ្ញុំ ក៏ៗខ្ញុំត្រូវទទួលយកពីគេ ហើយគេមកជួបខ្ញុំក៏ខ្ញុំមិនៗទំនាស់ហ្នឹង។ បានសេចក្តីថា ខ្ញុំ កន្លែងខ្លះខ្ញុំគ្រាន់តែសុំសិទ្ធិថា ខ្ញុំអត់មកទេ តែគេថា អាហ្នឹងខាងផ្លូវច្បាប់អត់បាន! អឺះ! ខ្ញុំសម្រួលតាមហ្នឹង។ នេះខ្ញុំសូមបញ្ជាក់អ៊ីចឹង សូមអស់មតិបាទ។

**ស៖** លោកសាក្សី ខ្ញុំយល់ដែលលោកបានបញ្ជាក់ច្រើនដងរួមកហើយថា ការសម្ភាសធ្វើឡើងដោយការស្ម័គ្រចិត្ត ហើយលោករីករាយក្នុងការសហការជាមួយការសម្ភាស ប៉ុន្តែសំណួររបស់ខ្ញុំគឺផ្សេងពីនេះទេ។ សំណួររបស់ខ្ញុំគឺចង់ដឹងថា ហេតុអ្វីបានជាអ្នកស៊ើបអង្កេតមកជួបលោកដើម្បីសុំឲ្យលោកផ្តល់សក្ខីកម្ម? តើលោកដឹងដែរឬទេថាហេតុអ្វី? តើពួកគេមានប្រាប់លោកដែរឬទេ ថាហេតុអ្វីបានជាគេមកជួបលោក ប៉ុន្តែមិនជួបជាមួយអ្នកជិតខាងរបស់លោក ឬក៏ជួបអ្នកផ្សេងអ៊ីចឹង?

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយ!

សូមអញ្ជើញតំណាងសហព្រះរាជអាជ្ញា!

[០៩:៤០:៤២]

**លោក ខេល លីសាក់៖**

លោកប្រធាន យើងសូមជំទាស់ទៅលើការចោទសំណួរ ដែលសួរដដែលៗព្រោះគាត់សួរច្រើនដងរួចមកហើយ ហើយសាក្សីបានបញ្ជាក់ថា គាត់មិនដឹងថា ហេតុអ្វីបានជាមក មិនបានឆ្លើយតប។ ដូច្នេះ ខ្ញុំមិនយល់ថា ហេតុអ្វីបានជាមានការពាក់ព័ន្ធទៅពេលដែលធ្វើការសួរសំណួរបែបនេះច្រើនដងបែបនេះ។ ខ្ញុំសូមជំទាស់។

**លោក ហ្វាស្តេ ប៉ោ៖**

ការពិតទៅសាក្សីមិនបានឆ្លើយថាគាត់មិនដឹងថា ហេតុអ្វីបានអ្នកស៊ើបអង្កេតមកសួរគាត់នោះទេ។ ប្រហែលជាអ្នកស៊ើបអង្កេតបានប្រាប់គាត់ នៅពេលចាប់ផ្តើមសម្ភាសអំពីមូលហេតុដែលគេមកជួប ហេតុអ្វីបានជាឈ្មោះគាត់ត្រូវបានគេលើកយកមកនិយាយនៅក្នុងឯកសារ ឬក៏មានបង្ហាញអ្វី។ ហេតុដូច្នេះហើយ ប្រហែលជាមានហេតុផល ដែលអ្នកស៊ើបអង្កេតគាត់មកទីក្រុងប៉ៃលិន ដើម្បីសួរសាក្សីនេះ។ ហើយយើងមិនទាន់ដឹងអំពីហេតុផលទាំងអស់នេះទេ ព្រោះសាក្សីមិនទាន់បានឆ្លើយនៅឡើយ។ ដូច្នេះ យើងមិនទាន់ដឹងថា ហេតុអ្វីបានជាគេមកសាកសួរសាក្សីនេះ។

**ប្រធានអង្គជំនុំ៖**

បាទ សេចក្តីជំទាស់ និងសំអាងហេតុនៃសេចក្តីជំទាស់ត្រឹមត្រូវ។ សេចក្តីជំទាស់មានប្រសិទ្ធភាព។ សាក្សីមិនចាំបាច់ឆ្លើយតបទៅនឹងសំណួរបែបនេះទេ!

[០៩:៤២:១៨]

**សួរដោយលោក ហ្សាស្តើ ប៉ោះ**

**ស៖** ការសម្ភាសត្រូវធ្វើឡើងនៅហាងកាហ្វេមួយ។ តើខ្ញុំនិយាយនេះត្រឹមត្រូវដែរឬទេលោកសាក្សី?

**លោក ខៀវ អេន៖**

**ឆ៖** បាទ សំណួរសួរនេះគឺជាការត្រឹមត្រូវ មិនជាហាងកាហ្វេទេ ខ្ញុំគ្រាន់តែបញ្ជាក់បន្ថែម គឺថានៅចម្ការកាហ្វេ។ កន្លែងទីតាំងហ្នឹង បើឈ្មោះទឹកដីប៉ៃលិនហ្នឹងមានទឹកដីមួយ ពីជំនាន់មុនមកហៅថាចម្ការកាហ្វេហ្នឹង។ ហើយទៅសម្ភាសខ្ញុំនោះ គេមកជួបខ្ញុំហើយ គេអញ្ជើញខ្ញុំទៅសម្ភាសនៅកន្លែងចម្ការកាហ្វេ។

**ស៖** តើពួកគេស្នើលោកឲ្យធ្វើការសម្ភាសនៅចម្ការហ្នឹងដោយរបៀបណា? តើគេទូរសព្ទទៅលោក ឬក៏គេមកជួបលោកដោយផ្ទាល់នៅផ្ទះ?

**ឆ៖** ខ្ញុំសូមឆ្លើយ។ មុននឹងទៅសម្ភាសនៅចម្ការកាហ្វេហ្នឹង គឺគេមកជួបខ្ញុំនៅផ្ទះសិន។ ហើយដល់នៅផ្ទះហើយ ខ្ញុំក៏ ដោយសារខាងអស់លោកមើលទៅទំនាក់ទំនងដឹងពីការចង់បានចម្លើយពីខាងខ្ញុំដែលខ្ញុំរស់នៅហ្នឹងហើយ ខ្ញុំក៏ស្ម័គ្រចិត្តជាមួយគេហ្នឹងទៅសម្ភាសនៅទឹកដីចម្ការកាហ្វេហ្នឹង ជាកន្លែងហូបចុក តែការកន្លែងសម្ភាសហ្នឹងគឺថា វាមិនអង្គុយកន្លែងហូបទេ គឺអង្គុយកន្លែងបន្ទប់ដែលគេមានផ្ទះសម្រាប់សម្រាកនៅ ជាផ្ទះជួល បាទជាផ្ទះជួល ផ្ទះស្នាក់នៅ ផ្ទះសំណាក់ហ្នឹង។ នេះខ្ញុំសូមបញ្ជាក់ប៉ុណ្ណឹងបាទ។

**ស៖** សូមអរគុណ។ នៅពេលដែលគេពន្យល់ថា គេចង់បានព័ត៌មានមួយចំនួនពីលោក តើពួកគេមានបានប្រាប់លោកដែរឬទេ ថាតើព័ត៌មានបែបណាដែលគេចង់បាន? តើគេមានបញ្ជាក់ថា ព័ត៌មានដែលគេចង់បានគឺព័ត៌មានទាក់ទងទៅនឹងរបបខ្មែរក្រហម ឬមួយក៏មានជាអ្វីដែរឬទេ?

[០៩:៤៥:០០]

**ឆ៖** ខ្ញុំសូមឆ្លើយថា ព័ត៌មានដែលចង់បានគឺរយៈពេលដែលខ្ញុំរស់នៅ៣ឆ្នាំនៅនឹងភ្នំពេញហ្នឹងតែ

ម្តង។ តែក៏ ក្នុងហ្នឹងក៏មានសួរពីប្រវត្តិខ្ញុំខ្លះមកដែលមុននឹងខ្ញុំមកនៅភ្នំពេញ ភ្នំអីហ្នឹងក៏មានសួរខ្លះដែរ។ ដល់អ៊ីចឹងមែនទែនចម្លើយដែលខ្ញុំបានឆ្លើយថ្ងៃនេះ និងខាងមេធាវីអីលើកសួរមកទាំងអស់សុទ្ធតែសំណួរពាក់ព័ន្ធកាលពេលនុ៎ងដែរ។ សូមអស់មតិប៉ុណ្ណឹង។

**ស៖** សូមអរគុណលោកសាក្សី។ ខ្ញុំសូមបន្តទៅប្រធានបទថ្មីមួយទៀត ហើយខ្ញុំគិតថាប្រហែលជាសហការីខ្ញុំចង់បន្ថែមទៅលើចំណុចនេះដែរមើលទៅ។ ដើម្បីបញ្ជាក់ឲ្យបានច្បាស់ខ្ញុំមិនមែនចង់បង្ហាញថាមានអ្វីមិនល្អកើតឡើងនៅពេលដែលគេសួរលោកនោះទេ ខ្ញុំគ្រាន់តែចង់ឲ្យបានយល់ឃើញអំពីទិដ្ឋភាពនៃការផ្តល់ចម្លើយរបស់លោកតែប៉ុណ្ណោះ។ សំណួររបស់ខ្ញុំគឺថា មានសាក្សីមួយរូបផ្សេងទៀតដែលធ្វើការនៅក្រសួងឃោសនាការដែលបានមកផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះនេះ ហើយឈ្មោះរបស់គាត់ គឺលោក គឹម វុន ហើយគាត់មានរហស្សនាមហៅនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យហៅថា ឆោម តើលោកស្គាល់លោក គឹម វុន ដែរឬទេ? ឬមួយក៏ប្រហែលជាលោកស្គាល់ឈ្មោះរហស្សនាម ឈ្មោះហៅក្រៅរបស់គាត់ដែលហៅថា ឆោម នោះដែរឬទេ?

[០៩:៤៧:០៦]

**ឆ៖** ខ្ញុំសូមឆ្លើយ ឈ្មោះនេះ ខ្ញុំស្គាល់។ បាទ ស្គាល់តែឥឡូវគាត់នៅធ្វើការនៅប៉ៃលិនទាំងអស់គ្នាទេ គ្រាន់តែកន្លែងគាត់ធ្វើផ្សេង ខ្ញុំធ្វើផ្សេង។ ផ្ទះសម្បែងនៅដោយឡែក។ សូមមានមតិប៉ុណ្ណឹង។

**ស៖** តើលោកស្គាល់គាត់នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យផងដែរទេ?

**ឆ៖** ខ្ញុំសូមឆ្លើយ។ អាសំណួរនេះហាក់ដូចជាស្ទួនដដែលៗរបបកម្ពុជាប្រជាធិបតេយ្យហ្នឹងដែលអំមិញខ្ញុំបញ្ជាក់ចុង ប៉ៃលិន តែឥឡូវហ្នឹងវានៅស្គាល់ទៀត អ៊ីចេះ។ តែឥឡូវបើនេះ ខ្ញុំបញ្ជាក់បន្ថែមឈ្មោះ ឆោម ហ្នឹងគឺស្គាល់នៅៗក្នុងមន្ទីរ ក-៣៣ ហ្នឹង។ តែគ្រាន់តែគេនៅមុនខ្ញុំ។ ខ្ញុំចូលទៅឃើញគេនៅមុនហើយអ៊ីចេះ។ សូមមានមតិប៉ុណ្ណឹងបាទ។

[០៩:៤៨:២៨]

**ស៖** ហើយឥឡូវនេះគាត់រស់នៅក្នុងប៉ៃលិន ដូច្នេះនៅពេលដែលលោកជួបគាត់ចុងក្រោយហ្នឹងថា ជួបនៅពេលណា?

**ឆ៖** ខ្ញុំសូមឆ្លើយថា នេះដូចជាមិនមានពាក់ព័ន្ធក្នុងនេះសោះ តែថាសួរហើយខ្ញុំឆ្លើយ។ មួយដីប៉ៃលិន ហើយការដែលធ្វើការដែលថា ជួបគ្នាព្រឹកល្ងាច តែមកឥឡូវនេះអត់ដែលមានជួបទេ គ្រាន់តែថាមនុស្សវាស្គាល់គ្នាតាំងពីមុនមករហូតដល់ឥឡូវនេះនៅតែស្គាល់ទៀត។ ដល់អ៊ីចឹងក្នុងន័យថា បើគិតថា

ពេលណាអីពេលណា ឬមួយក៏ឥឡូវនេះវាអត់មានទំនាក់ទំនងគ្នាទេ។ តែគ្រាន់តែឥឡូវនេះ មនុស្សហ្នឹង នៅស្គាល់ នៅ -- ហើយដឹងថាធ្វើការអីណាៗហ្នឹង យូរជួបគ្នាម្តងក្នុងហ្នឹង វាអ៊ីចឹង។ វាជាមិត្តភក្តិចាស់។ នេះសូមមានមតិប៉ុណ្ណឹងបាទ។

[០៩:៤៩:៣៤]

**ស៖** តើលោកបានជួបលោក គឹម វុន ហ្នឹងក្រោយពេលដែលលោក គឹម វុន មកផ្តល់សក្ខីកម្មនៅ អ.វ.ត.ក ដែរឬទេ?

**ឆ៖** ខ្ញុំសូមឆ្លើយថា ដែលក្រោយពីគេទៅអញ្ជើញខ្ញុំហើយ ដែលខ្ញុំត្រូវដឹងថា ខ្ញុំត្រូវឡើងមកដែរនេះ។ តែការពិត មុនខ្ញុំឡើងមកហ្នឹង ក៏ឈ្មោះ ឆោម ហ្នឹង ឮថាឡើងមកហើយ តែខ្ញុំមិនដែលទៅជួបអីទៀតទេ អត់ដែលជួបទេ។ ហើយដល់អ៊ីចឹង គ្រាន់តែនឹកឃើញថា បើគេឡើងទៅហើយ ហើយមនុស្សនៅក្នុង ៣៣ ដែរ ឡើងមកហើយ កាលថ្ងៃណាមួយ គឺខ្ញុំត្រូវឡើងដែរ។ ហើយដល់ឮថា ត្រូវហៅមកខ្ញុំដែរ ខ្ញុំក៏អត់បានទៅជួបអីគេទៀតដែរ។ ព្រោះនឹកឃើញថា ដូចមិនមានបញ្ហាអី គ្រាន់តែមកឆ្លើយនូវប៉ុណ្ណឹង ដែលខ្ញុំដឹង ខ្ញុំឮប៉ុណ្ណឹង។ ដល់អ៊ីចឹង ខ្ញុំអត់ស្វែងយល់អីគេ ថាមកម៉េច អីម៉េចទៀតអត់។ នេះសូមជូនមតិប៉ុណ្ណឹង។

[០៩:៥០:៥៤]

**ស៖** តើលោកធ្វើយ៉ាងដូចម្តេច ទើបដឹងថា ឆោម ហ្នឹង ត្រូវបានគេកោះអញ្ជើញមកទីនេះ?

**ឆ៖** ខ្ញុំសូមឆ្លើយ។ ការពិត ពេលដែលគេទៅអញ្ជើញខ្ញុំៗ បានដូចជាជួបគ្រួសារគេមិនដឹង អីមិនដឹង ខ្ញុំដូចជាវាមិនសូវចងចាំ មិនដឹង។ គេថា ឪពុក -- គ្រួសារខ្ញុំឡើងទៅបាត់ហើយ ឥឡូវគេមកវិញ។ បាទ អ៊ីចឹង ខ្ញុំក៏អត់ចាប់អារម្មណ៍ដែរ ថាថ្ងៃណានេះ ខ្ញុំទៅដែរ ព្រោះខ្ញុំមានឈ្មោះគេហៅដែរ។ ហើយខ្ញុំឲ្យ -- ហើយដល់គេទៅហើយ គេបកទៅវិញនោះ ក៏ខ្ញុំមិនដែលបានទៅទំនាក់ទំនងដែរ ក៏គ្រាន់តែឮថា គេទៅហើយ។ ដល់អ៊ីចឹង ថ្ងៃណាត្រូវខ្ញុំមកទៀត ខ្ញុំមកហើយ។ ដល់អ៊ីចឹង ទទួលថ្ងៃដែលគេមកហ្នឹង គឺខ្ញុំមកអត់ដឹងថា មនុស្សទៅថ្ងៃណា អីថ្ងៃណា បកទៅវិញថ្ងៃណាផង កាលហ្នឹង ក៏អត់ដឹង។ តែគ្រាន់តែដឹងថា គេបានមក។ អ៊ីចេះ មកផ្តល់ហើយ។ នេះ ខ្ញុំសូមជូនមតិប៉ុណ្ណឹងបាទ។

**ស៖** លោកបានបញ្ជាក់ថា លោកមិនបានជួបលោក គឹម វុន ទេ។ ដូច្នេះ ខ្ញុំចង់សួរថា ប្រហែលជាលោកធ្លាប់និយាយជាមួយគាត់តាមទូរសព្ទ តើធ្លាប់ដែរឬទេ?

**ឆ៖** ខ្ញុំ អានេះ ខ្ញុំបញ្ជាក់ឲ្យខ្លីងាយវិញ។ លោក ឆោម ហ្នឹង សូម្បីទូរស័ព្ទ ក៏គាត់អត់ប្រើដែរ

រហូតដល់ម៉ូតូ ក៏គាត់អត់ចេះដែរ អានេះ ខ្ញុំនិយាយឲ្យងាយ ឲ្យនេះ។ ដល់អ៊ីចឹង គាត់អត់មានលេខ អត់មានទូរសព្ទអីផងហ្នឹង ហើយខ្ញុំក៏គ្មានបំណងអី ចង់ទៅទាក់ទងគាត់សួរអារឿងហ្នឹងដែរ។ ទទួលថា អត់មានទូរសព្ទអីទៀត លែង គឺកាន់តែលែងរវីរវល់បណ្ដោយ។ សូមអស់មតិប៉ុណ្ណេះ។

[០៩:៥៣:០៨]

**ប្រធានអង្គជំនុំ៖**

លោកមេធាវី សូមលោកជំរុញនូវការតាំងសំណួរទៅមុខទៅ។ ហើយសំណួររបស់លោក ដូចជាច្រើនសំណួរហើយ មិនមានភាពពាក់ព័ន្ធអីទៅនឹងអង្គហេតុដែលត្រូវពិភាក្សាដេញដោលនេះទេ។ ហើយបំណងរបស់លោក ដើម្បីចង់មោឃភាពនូវកិច្ចដំណើរការនីតិវិធីរបស់សហចៅក្រមស៊ើបអង្កេតនោះ គឺបាន ត្រូវបានលុបលាងដោយដីកាដំណោះស្រាយរួចហើយ។ យើងមិនចង់កាត់លោកទេ ប៉ុន្តែយើងស្ដាប់ច្រើនសំណួរហើយ ដូចជារកសារធាតុអីដែលវាមានការពាក់ព័ន្ធទៅនឹងអង្គហេតុ នៅក្នុងការបញ្ជាក់ការពិតនៃរឿងក្ដីនេះ ដូចជាមិនទាន់មានសំណួរណាពាក់ព័ន្ធទាល់តែសោះ។

[០៩:៥៤:១៨]

**លោក ហ្សាស្តេី ប៉ោ៖**

តាមចេតនារបស់ខ្ញុំ គឺមិនមែនចង់ធ្វើការមោឃភាពលើកិច្ចដំណើរការនីតិវិធីនោះទេ។ ខ្ញុំគ្រាន់តែចង់សាកសួរអំពីខ្លឹមសារនៃអ្វីដែលគាត់បានផ្ដល់ ហើយឥឡូវនេះ គាត់បានមកផ្ដល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះ។ ហើយសាក្សីកាលពីមុនហ្នឹង គឺដែលប្រហែលជា១ខែមុនហ្នឹង ក៏គាត់បានមកផ្ដល់សក្ខីកម្មពីបញ្ហានៅក្រសួងឃោសនាការដែរ ហើយសក្ខីកម្ម -- ហើយសាក្សីនោះ ក៏គាត់រស់នៅក្នុងទីក្រុង នៅក្នុងកន្លែងជាមួយគ្នា ជាមួយនឹងលោកសាក្សីនេះដែរ ហើយសម័យខ្មែរក្រហម ក៏គាត់នៅធ្វើការជាមួយគ្នានោះដែរ។ ដូច្នេះ វាមិនមានបញ្ហាទាក់ទងទៅនឹងការមោឃភាព ឬក៏ប្រសិទ្ធភាពនៃការសម្ភាស ឬក៏ការធ្វើកិច្ចដំណើរការនីតិវិធីនោះឡើយ។ ខ្ញុំគ្រាន់តែចង់សួរបញ្ជាក់អំពីការសម្ភាស ប្រសិនបើលោកប្រធាន និងអង្គជំនុំជម្រះអនុញ្ញាតខ្ញុំសូមបន្តការសួររបស់ខ្ញុំ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញ! ប៉ុន្តែឥឡូវហ្នឹងមានវត្តមានគាត់នៅទីនេះហើយ។ ហើយយើងមិនយល់ ពីព្រោះថាបំណងរបស់លោកសួរអម្បាញ់មិញនេះ ក្រៅពីគោលដៅនៃមោឃភាពនូវកិច្ចដំណើរការនីតិវិធីនៃការស៊ើបអង្កេត យើងអត់យល់ថា តើបំណងអីទេ ព្រោះមានការ -- មិនមានការពាក់ព័ន្ធទាល់តែសោះនូវ

សារធាតុទាំងឡាយដែលវាកើតមានឡើង ដែលសាក្សីដែលមានលទ្ធភាពអាចដឹង ពីព្រោះឥឡូវហ្នឹងមានវត្តមានសាក្សីនៅចំពោះមុខលោកហើយ។ ហើយសាក្សីបានបញ្ជាក់ហើយគាត់នឹងប្រឹងប្រែងឆ្លើយនូវអ្វីដែលគាត់បានដឹង បានឮ ចងចាំ។ អ្វីដែលមិនច្បាស់គាត់នឹងប្រាប់អង្គជំនុំជម្រះវិញថា គាត់មិនច្បាស់ គាត់មិនឆ្លើយដូចអ្វី ដែលគាត់បានឆ្លើយកន្លងមក។ យើងគ្រាន់តែជំរុញ ដើម្បីឲ្យលោកទៅមុខទៅ ក្រែងលោវាបានប្រយោជន៍នៅក្នុងការតម្លៃនៃការផ្តល់ភស្តុតាង សក្ខីកម្មរបស់គាត់ហ្នឹងរួមចំណែក រួមវិភាគទានក្នុងការស្វែងរកការពិត។

[០៩:៥៦:១៩]

**លោក ហ្សាស្តេ ប៉ោះ**

លោកប្រធាន ខ្ញុំមិនមានចេតនាក្នុងការធ្វើមោឃភាពទៅលើកិច្ចដំណើរការនីតិវិធីណាមួយឡើយ។ ខ្ញុំគ្រាន់--

**ប្រធានអង្គជំនុំ៖**

យើងមិនថាឲ្យលោកមោឃភាពទេ ប៉ុន្តែលោកសួរអំពីនីតិវិធីនៃការស៊ើបអង្កេតវាអត់មានអីដែលវាក្រៅពីហ្នឹងទេ។ ការប្រព្រឹត្តទៅនៃការស៊ើបអង្កេត វាមានប្រយោជន៍ស្អី បើមិនមោឃភាពកិច្ចដំណើរការនីតិវិធីនោះ។ យើងដឹងពីព្រោះលោកមិនបានប្តឹងអំពីមោឃភាពកិច្ចដំណើរការនីតិវិធីទេ ប៉ុន្តែសំណួរហ្នឹងវាពាក់ព័ន្ធនឹងរបៀបក្នុងការស៊ើបអង្កេត។ ហើយថ្ងៃនេះ វាអង្គជំនុំជម្រះចង់ដឹងគឺចង់ដឹងសារធាតុភស្តុតាងជាសារធាតុ ដែលចោទប្រកាន់ទៅលើជនជាប់ចោទ។ លោកអាចបន្តសំណួរទៅមុខបាន។

[០៩:៥៧:១៥]

**លោក ហ្សាស្តេ ប៉ោះ**

តាមអ្វីដែលបានសម្រេចគឺខ្ញុំមិនអាចធ្វើការស្វែងរកឃើញអំពីការទំនាក់ទំនងរវាងលោក គឹម វុន និងសាក្សីមួយនេះទេ ប្រសិនបើខ្ញុំមិនអាចធ្វើការសាកសួរអំពីទំនាក់ទំនងនេះ ខ្ញុំមិនអាចបន្តទៅមុខទៀតនោះឡើយ។ ដូច្នេះ ខ្ញុំចង់ឲ្យខាងចៅក្រមអន្តរជាតិជួយផ្តល់នូវមតិយោបល់ផងដែរពីបញ្ហានេះ ខ្ញុំមិនមែនធ្វើការជំទាស់ទៅលើការដំណើរ -- ទៅលើកិច្ចដំណើរការនីតិវិធីនោះទេ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកតំណាងសហព្រះរាជអាជ្ញា!

**លោក ខេល លីសាក់៖**

ខ្ញុំសូមធ្វើការឆ្លើយតបទៅនឹងបញ្ហានេះ គឺថាមេធាវីការពារក្តីបានសួរសាក្សីនូវសំណួរជាច្រើនរួចមកហើយ។ ហើយសាក្សីក៏បានបញ្ជាក់ច្រើនដងរួចមកហើយថា គាត់មិនដែលទាក់ទងជាមួយលោក គីម វុន នោះទេ។ ខ្ញុំគិតថាមេធាវីបានសួរគ្រប់ចំណុចទាំងអស់ហើយទាក់ទងទៅនឹងអ្វីដែលគាត់គិតថាអាចនឹងមិនត្រឹមត្រូវ ឬក៏អ្វីដែលកើតឡើង ហើយគាត់មានឱកាសគ្រប់គ្រាន់។ ដូច្នេះ ខ្ញុំគិតថាគ្មានមូលដ្ឋានណាមួយដើម្បីបន្តលើការសួរទៅលើសាក្សីនៅពេលដែលគាត់ឆ្លើយច្រើនដងរួចមកហើយថា គាត់មិនដែលទាក់ទងជាមួយលោក គីម វុន នោះទេ។ ដូច្នេះ ខ្ញុំគិតថាជាការត្រឹមត្រូវដើម្បីឲ្យមេធាវីការពារក្តីបន្តទៅនឹងសំណួរប្រភេទផ្សេងៗទៀត។

[០៩:៥៨:៤៣]

**លោក ហ្សាស្តេី ប៉ោ៖**

ខ្ញុំត្រូវបានគេកាត់ ដូច្នេះ ខ្ញុំចង់បន្តនូវសំណួរប្រភេទបែបនេះ ដូច្នេះ ខ្ញុំមិនគិតថាគួរតែប្រើប្រាស់ពាក្យរំខាន ឬក៏ពាក្យធ្វើបាបទៅលើសាក្សីនោះឡើយ។ ដូច្នេះប្រសិនបើខ្ញុំមិនអាចសាកសួរទៅលើបរិបទនៃសាក្សីនេះជាមួយនឹងលោក គីម វុន នៅក្នុងអតីតកាល ដូច្នេះ ខ្ញុំគ្មាន -- ខ្ញុំគិតថាវាគ្មានប្រយោជន៍អ្វីដើម្បីខ្ញុំធ្វើការសាកសួរដេញដោលទៅលើសាក្សីរូបនេះនោះទេ។

[០៩:៥៩:១៦]

*(ចៅក្រមពិភាក្សាគ្នា)*

[០៩:៥៩:៤៩]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកស្រីចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍!

**ចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍៖**

ទោះបីអង្គជំនុំជម្រះទទួលបានសំណើឲ្យដកចៅក្រមក៏ដោយ ប៉ុន្តែវាហាក់ដូចជាមានការច្បាស់លាស់ ដែលថាមេធាវី នួន ជា បាន -- យើងបញ្ជាក់ថា គឺយើង អង្គជំនុំជម្រះបានយល់ស្របជាមួយនឹងលោកប្រធាន គឺយើងបានពិភាក្សាគ្នារួចទៅហើយ។ ដូច្នេះហើយគ្មានបញ្ហា ឬក៏គ្មានសារប្រយោជន៍អ្វីទៀតទេ ក្នុងការបន្តសំណួរនេះដូចដែលលោកប្រធានបានស្នើរួចទៅហើយ គឺថាសូមឲ្យលោកមេធាវីបន្តទៅសំណួរផ្សេងទៀត ដែលនិយាយអំពីអង្គសេចក្តី។

**សួរដោយលោក ហ្សាស្តេី ប៉ៅ៖**

**ស៖** លោក ខៀវ អេន លោកបាននិយាយថា លោកស្គាល់លោក គឹម វុន។ សូម្បីនៅក្នុងរបប កម្ពុជាប្រជាធិបតេយ្យ ក៏លោកស្គាល់គាត់ដែរ។ តើលោកអាចជម្រាបទេ នៅក្រសួងឃោសនាការនោះ លោក គឹម វុន នោះគាត់មានតួនាទីអ្វីដែរ?

**លោក ខៀវ អេន៖**

**ឆ៖** ខ្ញុំសូមឆ្លើយ។ ដូចលើកឈ្មោះដើមនេះ ឈ្មោះនេះ ខ្ញុំមិននេះទេ ខ្ញុំដឹងតែឈ្មោះ ឆោម។ ឈ្មោះ ឆោម នៅក្នុង ក-៣៣ មន្ទីរជាមួយខ្ញុំហ្នឹងដែរ។ តែគ្រាន់តែការងារ វាខុសគ្នា ការងារដោយឡែក។ ដល់អ៊ីចឹងគ្រាន់តែបានដឹងថាខាង ឆោម ហ្នឹងគាត់ជាអ្នកសរសេរអីៗទេ ខ្ញុំអត់ដឹង ហើយសរសេររឿងអីៗ អាហ្នឹងគេមានមេកោយរបស់គេផ្សេង។ អ៊ីចឹងបានថា ស្គាល់ត្រឹមថា ឆោម ហ្នឹងបាននៅនឹង ក-៣៣ ដែរ និងៗជំនាន់កម្ពុជាប្រជាធិតេយ្យហ្នឹងដែរ ហើយរហូតដល់ៗ ចេញពីភ្នំពេញនេះហើយ រហូតដល់ថ្ងៃនេះក៏គាត់នៅរស់ បានទៅនៅប៉ៃលិន ស្គាល់គ្នា ដឹងថាមិត្តភក្តិចាស់ទៀត។ តែកាលពីមុនហ្នឹង គឺថាគាត់ហ្នឹងនៅមុនខ្ញុំ។ ខ្ញុំនិយាយអ៊ីចឹង ហើយនិយាយថា ដឹងគាត់នៅពីឆ្នាំណាមក ខ្ញុំមិនដឹងទេ។ តែដែលខ្ញុំចូលទៅនៅហើយ គឺខ្ញុំឃើញគាត់នៅនុំងហើយហើយ។ នេះខ្ញុំសូមជូនមតិផ្តល់មតិប៉ុណ្ណឹងបាទ។

[១០:០២:២៤]

**ស៖** ដូច្នេះក្រោយរបបកម្ពុជាប្រជាធិបតេយ្យមក លោកបានឆ្លើយថា លោកធ្លាប់បានជួបលោក គឹម វុន ញឹកញាប់ផងដែរ។ តើនៅពេលដែលជួបគ្នានោះ លោកមាននិយាយជជែកគ្នាអំពីពេលវេលាដែលលោកធ្វើការងាររួមគ្នានៅក្រសួងឃោសនាការដែរឬទេ?

**ឆ៖** ខ្ញុំសូមឆ្លើយ។ ក្រោយពីកម្ម -- ក្រោយៗ ពីចេញភ្នំពេញហើយហ្នឹង ខ្ញុំជម្រាបជូនថា រហូតដល់មកឥឡូវនេះទៀត ធ្វើសមាហរណកម្មនេះក៏ បើនិយាយទៅថា គិតតែពីរឿងជីវភាព គេក៏គិតជីវភាពរបស់គេ ខ្ញុំគិតជីវភាពរបស់យើងសម្រាប់គ្រួសារខ្ញុំដែរ ដែលខ្ញុំរស់នៅមានកូន មានប្រពន្ធ។ ដល់អ៊ីចឹងពីរឿងអតីតកាលអីម៉េចៗហ្នឹង ដូចជាមិនបាននឹកនាអីដល់ទេបាទ អត់។ អាហៅថាអតីតកាល ឲ្យវាទៅបាត់ គិតតែពីរឿងថាទៅមុខទៅ ធ្វើម៉េចឲ្យរស់ស្រួលក្នុងសង្គមឥឡូវហ្នឹង។ អាហ្នឹងគិតទៅអ៊ីចឹងវិញ អាហ្នឹងខ្ញុំបញ្ជាក់ជូនដោយខ្លីប៉ុណ្ណឹងបាទ។

[១០:០៣:៤៦]

**ស៖** ខ្ញុំដឹងថាលោកត្រូវគិតអំពីការចិញ្ចឹមជីវិត សុខុមាលភាពរបស់គ្រួសាររបស់លោក។ លោកបាននិយាយផងដែរថា "លោកជួបជាមួយលោក គឹម វុន នោះញឹកញាប់ផងដែរ"។ តើនៅក្នុងពេលដែលជួបគ្នានៅក្នុងសង្គម ឬក៏នៅក្នុងពិធីរៀបអាពាហ៍ពិពាហ៍ ឬក៏ជួបជុំនៅពេលហូបបាយល្ងាចជាមួយគ្នា? នៅក្នុងឱកាសណាដែរ ដែលលោកជួបគាត់ញឹកញាប់នោះ?

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយ! សូមអញ្ជើញតំណាងសហព្រះរាជអាជ្ញា!

**លោក ឌេល លីសាក់៖**

ជាថ្មីម្ដងទៀត ខ្ញុំសូមជំទាស់ទៅលើមូលដ្ឋានដែលបានសួរសំណួរនេះ។ គ្មានហេតុផលណាមួយដែលលោក ប៉ោ នេះត្រូវសួរអំពីឱកាសដែលជួបគ្នាក្នុងពេលរៀបអាពាហ៍ពិពាហ៍ ឬក៏ពេលហូបអាហារល្ងាចនោះទេ គឺគួរតែផ្ដោតទៅលើរបបកម្ពុជាប្រជាធិបតេយ្យ។

**លោក ហ្សាស្ដើ ប៉ោ៖**

លោកប្រធាន តាំងពីឆ្នាំ១៩៧៩ គឺ៣៣ឆ្នាំកន្លងផុតមកហើយ។ បុគ្គលពីររូបនេះ គឺបានធ្លាប់ជួបគ្នាជាញឹកញាប់។ អ្នកទាំងពីរធ្លាប់ធ្វើការងារនៅក្នុងមន្ទីរជាមួយគ្នាផងដែរ។ មេធាវីការពារក្ដី គឺគ្រាន់តែសង្ស័យតែប៉ុណ្ណោះ ថាតើបុគ្គលពីររូបនេះ គឺពិតជាមិនដែលធ្លាប់បានជជែកគ្នាអំពីពេលវេលា ដែលគាត់ធ្វើការងារនៅក្នុងក្រសួងឃោសនាការតែប៉ុណ្ណោះ។ នេះគឺជាវាពាក់ព័ន្ធទៅនឹងភាពជឿជាក់ និងចម្លើយដែលលើកឡើងដោយសាក្សី ហើយវាជាប់ទាក់ទងនៅក្នុងរយៈកាលឆ្នាំ៧៥ ដល់៧៩ ដែលយើងត្រូវដឹងអំពីតម្លៃនៃភស្តុតាងនៃសក្ខីកម្មរបស់សាក្សី។ ដូច្នេះមេធាវីការពារក្ដីគួរតែត្រូវបានអនុញ្ញាតឲ្យសួរទៅលើបញ្ហានេះ។

[១០:០៥:៣៧]

**ប្រធានអង្គជំនុំ៖**

សេចក្ដីជំទាស់ និងសំអាងហេតុនៃសេចក្ដីជំទាស់ត្រឹមត្រូវ។ សំណួរនេះគឺអង្គជំនុំជម្រះបានសម្រេចរួចហើយ មិនឲ្យបន្តការសួរបែបនេះទៀតទេ ឲ្យសួរទៅសារធាតុពាក់ព័ន្ធនឹងអង្គហេតុដែលចោទប្រកាន់លើជនជាប់ចោទ។ តែលោកមេធាវីគឺគាត់នៅតែប្រព្រឹត្តដដែល ដោយផ្ទុយនឹងការសម្រេចរបស់យើង។ សូម្បីតែអង្គជំនុំជម្រះសម្រេចរួចហើយ បញ្ជាក់ដោយ គាំទ្រដោយចៅក្រមអន្តរជាតិដែលគាត់ចង់បញ្ជាក់ថា តើសម្រេចរបស់ប្រធានហ្នឹងមានការគាំទ្រដោយអន្តរជាតិ ពីចៅក្រមអន្តរជាតិដែរ

អត់? ចៅក្រមអន្តរជាតិបានបញ្ជាក់រួចហើយ ប៉ុន្តែនៅតែដដែល។

សាក្សីមិនបាច់ឆ្លើយតបទៅនឹងសំណួរចុងក្រោយនេះទេ!

**លោក ហ្សាស្តើ ប៉ោ៖**

ខ្ញុំកត់សម្គាល់ឃើញសេចក្តីសម្រេចរបស់លោកប្រធាន យើងខ្ញុំនឹងធ្វើតាម។ ដូច្នេះខ្ញុំសូមបន្តការតាំងសំណួររបស់ខ្ញុំសួរទៅសំណួរបន្ទាប់មួយទៀត។ ខ្ញុំយល់ថា ខ្ញុំមិនត្រូវបានអនុញ្ញាតឲ្យជជីកសួរអំពីបញ្ហានេះបន្ថែមទៀតនោះទេ--

[១០:០៧:១៣]

**ប្រធានអង្គជំនុំ៖**

យើងមិនអនុញ្ញាតឲ្យជជីកសួរនូវសំណួរបែបនេះទៀតទេ។ យើងបញ្ជាក់តែម្តង មិនបាច់លោកបញ្ជាក់ទេ។

**សួរដោយលោក ហ្សាស្តើ ប៉ោ៖**

**ស៖** លោក ខៀវ អេន លោកកាលពីម្សិលមិញលោកបានឆ្លើយថា “អាមេរិកដកកងកម្លាំងទ័ពរបស់គេនៅក្នុងឆ្នាំ១៩៧៣ ចេញពីប្រទេសនេះ”។ តើលោកធ្លាប់ឃើញយន្តរបស់អាមេរិកហោះហើរនៅលើប្រទេសកម្ពុជាក្នុងចន្លោះឆ្នាំ១៩៧៣ ឬក៏មុនអំឡុងឆ្នាំ៧៣ ដែរឬទេ?

**លោក ខៀវ អេន៖**

**ឆ៖** ខ្ញុំសូមឆ្លើយ។ ចំពោះការឃើញជាជនជាតិអាមេរិកអីបើកអីលើយន្តហោះហ្នឹងមិនឃើញទេ តែគ្រាន់តែដឹងថាយន្តហោះហ្នឹងជាយន្តហោះរបស់អាមេរិកាំងជាអ្នកផលិត ហើយមកហោះហើរនៅលើដីខ្មែរ។ ហើយដូចខ្ញុំបញ្ជាក់ខាងដើមថា ភូមិខ្ញុំដែលឆេះហ្នឹងក៏ជាការឆេះដោយសារយន្តហោះនេះទម្លាក់ដែរៗ។ នេះខ្ញុំសូមបញ្ជាក់ខ្លីប៉ុណ្ណឹងបាទ។

[១០:០៨:៤៧]

**ស៖** ដូច្នេះយន្តហោះរបស់អាមេរិកនោះហើយ ដែលទម្លាក់គ្រាប់បែកលើភូមិកររបស់លោក។ តើខ្ញុំយល់តាមដែលលោកឆ្លើយអ៊ីចឹង ត្រឹមត្រូវដែរឬទេ?

**ឆ៖** ខ្ញុំសូមឆ្លើយថា សម្តីខ្ញុំត្រឹមត្រូវមិនត្រឹមត្រូវ ខាងអស់លោកអ្នកវិនិច្ឆ័យទេ តែគ្រាន់តែការដែលសំណួរសួរហើយ ខ្ញុំឆ្លើយទៅតាមដែលស្អីដែលខ្ញុំដឹង ខ្ញុំឃើញ។ នេះខ្ញុំនិយាយតាមដែលៗដឹងហើយនិងឃើញ និងនៅសល់ការចងចាំ បាទ។

**ស៖** ខ្ញុំអធ្យាស្រ័យលោក អេន ខ្ញុំមិនមែនថាខ្ញុំមិនជឿចម្លើយរបស់លោកនោះទេ ខ្ញុំគ្មានហេតុផលណាមួយដែលខ្ញុំមិនជឿទៅលើចម្លើយរបស់លោកនោះឡើយ។ តើលោកអាចជម្រាបជូនយើងខ្ញុំដែរឬទេ លទ្ធផលចេញពីការទម្លាក់គ្រាប់បែករបស់អាមេរិកនៅក្នុងភូមិកររបស់លោកនោះ គឺយ៉ាងម៉េចដែរ? គឺកម្ទេចបំផ្លាញបន្តិចបន្តួច ឬក៏បំផ្លិចបំផ្លាញទាំងស្រុងតែម្តង?

**ផ៖** ខ្ញុំសូមឆ្លើយ។ ឥឡូវ ខ្ញុំថាខាងណាកម្ទេចខាងណា មិនដឹងទេ។ តែភាសាថា សង្គ្រាម បានសេចក្តីថាភាគីមួយចង់កម្ទេចភាគីមួយ។ នេះខ្ញុំចង់និយាយអ៊ីចឹង ដល់អ៊ីចឹង ហេតុផលខ្ញុំមិននេះទេ គ្រាន់តែថា ភូមិខ្ញុំផ្ទះដែលខ្ញុំនៅសល់ការចងចាំខ្លះជំនាន់ហ្នឹងប្រហែលជាប្រាំ-ប្រាំមួយរយខ្នង តែដល់ពេលបញ្ចប់ការទម្លាក់ហ្នឹងហើយ ដែលប្រជាជនចូលមកនៅវិញហើយ នៅសល់ប្រហែល១០០ខ្នងផ្ទះទេ ហើយសល់ សល់ចុងដើម។ អាឆ្ងាយៗ ព្រោះផ្ទះខ្ញុំភូមិខ្ញុំជាផ្ទះភូមិប្រមូលផ្តុំ ដល់អ៊ីចឹងតែឆេះមួយហើយវាតោងគ្នាជាប់ហើយ។ ហើយដល់មនុស្សចេញអស់ហើយ អាហ្នឹងវាទៅតាមដំណើរហើយ។ នេះខ្ញុំសូមបញ្ជាក់អ៊ីចឹងបាទ។

**ស៖** តើមានប្រជាជនស្លាប់ដែរឬទេ នៅក្នុងការទម្លាក់គ្រាប់បែកនោះ? ឬក៏ប្រជាជនត្រូវបានគេជម្លៀសទាន់ពេលវេលា ហើយរួចផុតពីការស្លាប់?

[១០:១១:៣៣]

**ផ៖** ខ្ញុំមិនចាំទេ រឿងស្លាប់ជាប្រជាជននេះ។ តែគ្រាន់តែដឹងថា ការស្លាប់ក៏មានតិចតួចទេ។ ដោយសារអី? ដោយសារមុនដែលវ៉ៃហ្នឹង គឺតែពេលយប់ឡើងទាហានក្នុងបន្ទាយ ហើយដល់អ៊ីចឹងមុនវ៉ៃហ្នឹងគឺថាកម្លាំងខាងបដិវត្តន៍ទៅបង្ខំឲ្យប្រជាជនចេញអ៊ីចេះ ចេញ។ ហើយអ៊ីចឹងការដែលទម្លាក់គ្រាប់បែកគ្រាប់អីហ្នឹង គឺថាការប៉ះក្នុងការស្លាប់ហ្នឹងដូចជាមានក៏តិចតួច មិនច្រើនទេ។ ដោយសារអ្នកខ្លះនៅស្តាយទ្រព្យស្តាយអីហ្នឹង ដែលមិនចង់ចេញហ្នឹង។ តែចំនួនប៉ុន្មានខ្ញុំមិនអាចបញ្ជាក់ជូនបាន ដោយសារថាខ្ញុំអត់មានការចងចាំទៀតទេ។ ហើយដល់អ៊ីចឹង បើនិយាយពីរឿងខូច ភាគច្រើនគឺថាផ្ទះសម្បែងហ្នឹងគឺខូច ខូចអស់។ ដូចខ្ញុំបញ្ជាក់ខាងដើមអំមិញហើយថា សល់តែចុងភូមិ ដែលវាអត់ជាប់គ្នា វាឆ្ងាយផ្ទះឆ្ងាយៗ អាហ្នឹងសល់ចុងដើមភូមិហ្នឹង។ បាទសូមអស់ប៉ុណ្ណឹងបាទ។

**ស៖** សូមអរគុណ ដែលលោកបានឆ្លើយជូនយើងខ្ញុំ។ ខ្ញុំសូមបន្តចូលទៅដល់ប្រធានបទមួយទៀត ដែលពាក់ព័ន្ធនឹងការងាររបស់លោកនៅក្រសួងឃោសនាការ។ លោកបានឆ្លើយកាលពីម្សិលមិញថា លោកមិនយល់ មិនដឹងខ្លឹមសារនៅក្នុងឯកសារដែលផ្នែករបស់លោកនោះផលិតចេញ យកចេញមក

ពីម៉ាស៊ីននោះទេ។ តើលោកអាចពន្យល់ទេ ហេតុអ្វីលោកមិនយល់ និងមិនដឹងទៅលើខ្លឹមសារនៅក្នុងឯកសារនោះ?

[១០:១៣:២៨]

**ឆៈ** ខ្ញុំសូមឆ្លើយ ថាខ្ញុំ ការដែលចាប់ហ្នឹង វាមិនមែនជាអក្សរខ្មែរទេ។ វាជាអក្សរអង់គ្លេស និងអក្សរបារាំង។ ដល់ខ្ញុំហ្នឹងវាមិនមែនអ្នកចេះបារាំង ចេះអង់គ្លេសទេ ខ្ញុំដឹងតែភាសាខ្មែរ ឯអង់គ្លេសគ្រាន់តែ បារាំងអីហ្នឹង ដែលថា ន័យវាអត់ដឹងទាំងអស់ មិនដឹងគេនិយាយពីអីខ្លះទេ។ តែគ្រាន់តែថាយើងចេះតែធ្វើការជាប់បន្តិចទៅ យើងធ្លាប់ធ្វើដឹងថា អានេះដូចជាវា ចាប់អារម្មណ៍ថា អានេះដូចជាមិនត្រឹមត្រូវ ខ្វះនេះខ្វះនោះ ដូចថា អក្សរបារាំងថា *ឡេ* ហ្នឹង ខ្វះ *អេស* អីចឹង។ អារបស់ថាច្រើន ត្រូវមាន *អេស* ១ចុងអីចឹង។ អាហ្នឹងយើងចាប់អារម្មណ៍ ហើយយើងសួរគេទៀតទេ។ សួរទៅគេអ្នកដឹងថា ជូនយើងសួរទៅថា អ្នី អានេះដូចកន្លែងហ្នឹងត្រូវមាន*អេស* ចុងដឹង? ព្រោះមុនដូចធ្លាប់ឃើញអីចឹង។ ដល់អីចឹង វាជាឯកសារដែលគេទម្លាក់មកហើយ គ្រាន់តែថាគេឲ្យមកយ៉ាងម៉េច យើងធ្វើអីចឹង។ ហើយអាយើងចាប់មកវិញ ក៏អីចឹងដែរ។ ខ្លឹមសារហ្នឹងយើងអត់ដឹងអីទេ ដូចខ្ញុំ ខ្ញុំថាខ្ញុំអត់ចេះអង់គ្លេស ដល់សម្ភាស ខាងលោកនេះទៅស៊ើបអង្កេតខ្ញុំក៏ខ្ញុំបញ្ជាក់ថា បារាំង និងអង់គ្លេសអត់ចេះទេ ចិនអីហ្នឹង។ ចិនកូរ៉េក៏អត់ចេះ។ សម្ភាសខ្ញុំក៏អីចឹងទៀត ខ្ញុំបញ្ជាក់។ ដល់អីចឹងខ្លឹមសារអីខ្ញុំអត់ដឹងទេ។ តែគ្រាន់ថា ដល់ធ្វើការយូរទៅ ចេះតែសួរ អ្នី! អានេះពាក្យត្រង់នេះគេហៅអី ។ៗ អាហ្នឹងអីចឹងទេ។ នេះ ខ្ញុំសូមជូនជាមតិរបស់ខ្ញុំប៉ុណ្ណឹង។

[១០:១៥:០០]

**សៈ** កាលពីម្សិលមិញលោកក៏បានឆ្លើយផងដែរថា ពេលខ្លះលោកបានយកឯកសារទៅឲ្យនួនជា តើឯកសារនោះ គឺឯកសារដែលសរសេរជាភាសាបារាំង និងភាសាអង់គ្លេសដូចដែលលោកបានលើកឡើងហ្នឹងដូចគ្នា ឬក៏យ៉ាងម៉េច?

**ឆៈ** ខ្ញុំសូមឆ្លើយ។ ការងារខ្ញុំគឺការងារតែប៉ុណ្ណឹងទេ។ ដល់អីចឹងគ្មានឯកសារណាក្រៅពីភាសាហ្នឹងយកទៅជូនគាត់ទេ។ នេះខ្ញុំបញ្ជាក់ខ្លីអីចឹង។ ដល់អីចឹងឯកសារគ្រាន់តែកាន់ទៅកាន់មក និងចាប់ហ្នឹង តែជាខ្លឹមសារ ន័យវាគេនិយាយពីរឿងអីហ្នឹងយើងអត់ដឹងរឿងអីជ្រៅជ្រះអីក្នុងហ្នឹងអត់មានទេ។ ដូចខ្ញុំបញ្ជាក់ខាងដើមហើយ គ្រាន់តែធ្វើហើយបានជាឯកសារយកទៅជូនគេ គេធ្វើម៉េចទៀតធ្វើទៅអាហ្នឹងវារឿងរបស់គេទៀត។ ឯរឿងរបស់ខ្ញុំដឹងតែធ្វើតែប៉ុណ្ណឹងទេ។ បាទ សូមអស់មតិ។

[១០:១៦:២០]

**ស៖** សូមអរគុណ។ គឺយើងខ្ញុំយល់ច្បាស់ហើយត្រង់ចំណុចនេះ។ កាលពីម្សិលមិញលោកក៏បាននិយាយប្អូនប្រាំដងផងដែរ គឺថាលោកផ្ដោតតែលើសកម្មភាព និងការងាររបស់លោកតែប៉ុណ្ណោះ។ ហើយលោកបាននិយាយផងថា លោករវល់នឹងយកចិត្តទុកដាក់ចំពោះតែការងារខ្លួនឯងតែប៉ុណ្ណោះ ហើយលោកក៏មិនខ្វល់នឹងការងាររបស់គេនោះដែរ។ តើនេះគឺជាអ្វីដែលវាត្រឹមត្រូវទៅអ្វីដែលលោកឆ្លើយកាលពីម្សិលមិញដែរឬទេ គឺអាហ្នឹងជាចម្លើយរបស់លោកកាលពីម្សិលមិញដែរឬទេ?

**ឆ៖** ខ្ញុំសូមឆ្លើយ។ នេះជាចម្លើយពិតរបស់ខ្ញុំ។ ខ្ញុំសូមបញ្ជាក់ថា ន័យដែលត្រឹមត្រូវសម្រាប់កាលពេលនុ៎ង គេឱ្យធ្វើអីយ៉ាងធ្វើហ្នឹងទៅ តែទៅចង់ដឹងរឿងគេច្រើន អាហ្នឹងរឿងមិនល្អវិញ។ ដល់អ៊ីចឹងក្នុងន័យដែលយើងចង់ធ្វើល្អហ្នឹង គឺស្អីដែលគេឱ្យធ្វើ ធ្វើទៅ យើងកុំស្វែងរកយល់ដឹងក្រៅពីៗរបស់យើង។ នេះខ្ញុំបញ្ជាក់ខ្លីអ៊ីចឹងបាទ។

[១០:១៧:៤២]

**ស៖** លោកបាននិយាយថា បាទ ខ្ញុំសូមអធ្យាស្រ័យ លោកទើបតែនិយាយថា យើងមិនត្រូវខ្វល់ទៅនឹងការងាររបស់គេនោះទេក្នុងសម័យនោះ។ ដូច្នេះតើលោកមានខ្វល់ចង់ដឹងអំពីការងាររបស់ថ្នាក់ដឹកនាំនៅក្រសួងឃោសនាការដែរឬទេ?

**ឆ៖** ខ្ញុំសូមឆ្លើយ កន្លងមកខ្ញុំដូចជាមិនបានយកចិត្តទុកដាក់អីរឿងគេទេ។ មែនទែនវាៗគិតតែរឿងថា របស់ឯងហ្នឹងតើវាដំណើរការបានល្អ ហ្នឹងគិតតែប៉ុណ្ណឹងទៅវិញទេ។ តែរឿងគេអាហ្នឹងស្រេចលើគេ។ គេធ្វើម៉េចបានល្អអាហ្នឹងរឿងគេ។ អ៊ីចឹងចំណុចដែលខ្ញុំថា សម្រាប់ល្អរបស់ខ្ញុំ ហើយសម្រាប់ល្អក្នុងពេលសម័យនុ៎ងគឺថា បើគេប្រគល់អីឱ្យ យើងប្រឹងធ្វើអាហ្នឹងឱ្យល្អទៅវាចប់រឿងហើយ។ វាចប់រឿងហើយ។ ហើយដល់ចង់ដឹងរឿងក្រៅអានុ៎សុទ្ធតែកើតរឿងដែលៗ ដូចម្សិលមិញសួរហ្នឹង វាសុទ្ធតែរឿងដែលយើងចេះតែស្វែងរកក្រៅ យល់ក្រៅ អាហ្នឹងហើយដែលអត់សុខ។ នេះខ្ញុំនិយាយអ៊ីចេះវិញ។ សូមអស់មតិបាទ។

[១០:១៨:២៥]

**ស៖** ឧទាហរណ៍ទៅថា តើលោកធ្លាប់ចង់ដឹង ចង់ឮការងាររបស់ ហ៊ូ នឹម ឬក៏ យុន យ៉ាត ដែរឬទេ? ហើយលោកដឹងថា ពួកគាត់ទាំងពីរនោះមួយថ្ងៃៗហ្នឹងធ្វើអីខ្លះដែរឬទេ?

**ឆ៖** ខ្ញុំសូមឆ្លើយថា សូម្បីតែការនឹកភ្នកថា គាត់ធ្វើអីៗហ្នឹងដូចជាមិនដែលនឹកនាផង។ អាហ្នឹង

និយាយទៅថា អាសំណួរហ្នឹង ដូចថាចេះតែថែម ខ្ញុំថា បើខ្ញុំគិតតែការងាររបស់ខ្ញុំ មិនដឹងជាល្អ ឬមិនល្អ មិនធានាផង។ ខ្ញុំមានពេលណាទៅយកចិត្តទុកដាក់រឿងខាងលើដែលកម្ពស់មេឃនោះ ខ្ញុំមិនដែលទៅជួប មិនដែលទៅអី និយាយណាផ្ទាល់ផង។ អ៊ីចឹងបានថា កន្លែងនេះទៅ ស្តាប់ទៅ ហាក់ដូចជា វាជ្រុំ ហើយជ្រុំទៀត ចង់ដឹងតែ -- បើខ្ញុំថា ខ្ញុំគិតតែរឿងការងាររបស់ខ្ញុំទេ ដល់អ៊ីចឹងសូម្បីតែនឹកភ្នកថា គេធ្វើអី គាត់ធ្វើអីលើអ៊ីចេះអ៊ីចុះ ឲ្យនឹកនាអ៊ីចឹងៗ អត់ វាអត់មានពេល និយាយទៅ គ្មានពេលប្រើអារម្មណ៍ទៅគិតខាងអ៊ីចឹងៗ អត់។ នេះ សូមជម្រាបប៉ុណ្ណេះបាទ។

**ស៖** សូមអរគុណចំពោះចម្លើយរបស់លោក។ ខ្ញុំយល់តាមអ្វីដែលលោកឆ្លើយ កាលពីម្សិលមិញ លោកបានលើកឡើងផងដែរ ថាលោកក៏មិនដឹងថា ការងារប្រភេទរបស់ នួន ជា នោះ គឺយ៉ាងម៉េចយ៉ាងម៉ានោះដែរ។ លោកមិនដឹងនេះ ដោយសារតែលោកមិនរវល់ទៅនឹងការងារដែលគេធ្វើ ឬក៏មានហេតុផលផ្សេង ដែលលោកមិនចង់ដឹង មិនចង់ឮការងាររបស់គេនោះ?

[១០:២១:៣៧]

**ឆ៖** ខ្ញុំសូមឆ្លើយតទៅទៀត ខ្ញុំបញ្ជាក់ថា ខ្ញុំហាក់ដូចជាគ្រឿងម៉ាស៊ីនមួយ ដែលគេថា ដាក់តាំងត្រង់ហ្នឹង ត្រូវធ្វើអាហ្នឹងឲ្យចេញ។ ដល់អ៊ីចឹង ខ្លួនឯងនេះ គិតៗស្តុងតែក្នុងការងាររបស់ឯងនេះ ដូចថាមិនមានយកអារម្មណ៍ណា ទៅគិតពីរឿងណាណីទេ។ ហើយទទួលថា ដូចខ្ញុំបញ្ជាក់ខាងដើម ថាដល់ពេលគេដកអ្នកផ្សេងដែលធ្លាប់នៅជាមួយយើងគ្នាច្រើន គេធ្វើនេះផង ធ្វើនោះផង តែដល់គេដកទៅ នៅសល់តែយើងម្នាក់ទៀត។ អ៊ីចឹង អាការពេលទៅស្វែងយល់ ចង់ដឹងរឿងអីក្រៅពីការងារហ្នឹង វាអត់ៗ។ ដល់អ៊ីចឹង គឺថាដាក់ហ្នឹង គឺថាគិតអារឿងហ្នឹង កុំឲ្យមានបញ្ហាដល់ខ្លួនយើង ដែលត្រូវទទួលអានុំង។ ដល់អ៊ីចឹងពេលវេលាសម្រាប់គិតទៅផ្សេងទៀត អត់មានទេ។ សូមបញ្ជាក់អ៊ីចឹងបាទ។ អានេះ លើកលែងតែចេញពីកន្លែងមកហើយ ឮអ្នកផ្សេងនិយាយ អាហ្នឹងវាទទួលផ្សេង។ តែដល់ៗអារម្មណ៍ដែលសម្រាប់នេះ គឺគិតតែការងាររបស់ឯង មិនមែនទៅចង់ដឹង ចង់ឮ ចង់យល់អីពីរឿងខាងលើ អីធ្វើម៉េចៗទៀត អត់ទេ។ នេះ សូមអស់មតិបាទ។

**ស៖** ខ្ញុំឮលោកនិយាយថា នៅពេលដែលលោកចាកចេញទៅនោះ គឺលោកធ្លាប់ឮប្រជាជននិយាយអំពីបញ្ហាទាំងអស់នេះ។ លោកចង់បានន័យថា គឺក្រោយពេលដែលលោកចាកចេញពីក្រសួងឃោសនាការឆ្នាំ៧៩ ទៅនោះ ទើបលោកឮប្រជាជននិយាយពីបញ្ហាការងារទាំងអស់ហ្នឹង ឬក៏យ៉ាងម៉េច?

[១០:២៣:៤៦]

**ឆ៖** សំណួរនេះ ខ្ញុំស្តាប់អត់យល់។ មិនដឹងចង់សួរខ្ញុំពីស្អី ថាចាកចេញពី៧៩ ឮប្រជាជននិយាយពីបញ្ហាការងារទាំងអស់នោះ។ តើការងារអី? ខ្ញុំមិនដឹងឆ្លើយយ៉ាងត្រង់នេះ ខ្ញុំឆ្លើយអត់កើត។ ខ្ញុំស្តាប់សំណួរហ្នឹង អត់ទាន់យល់។

**ស៖** ខ្ញុំអធ្យាស្រ័យ ដោយសារខ្ញុំសួរសំណួរអត់ច្បាស់។ លោកទើបតែឆ្លើយអម្បាញ់មិញនេះតាមការបកប្រែជាភាសាអង់គ្លេសនោះ គឺថានៅពេលដែលលោកចាកចេញទៅនោះ គឺលោកបានឮប្រជាជននិយាយអំពីបញ្ហានេះ។ ខ្ញុំសន្និតថា លោក ក្រោយពីការចាកចេញទៅនោះ គឺលោកធ្លាប់ឮប្រជាជននិយាយអំពីការងាររបស់ក្រសួងឃោសនាការ។ ដូច្នេះ សូមឲ្យលោកជួយពន្យល់បញ្ជាក់បំភ្លឺជូនខ្ញុំបន្តិច នូវអ្វីដែលលោកឆ្លើយអម្បាញ់មិញនេះ នៅពេលដែលលោកឆ្លើយថា "ខ្ញុំ ពេលដែលខ្ញុំចាកចេញទៅនេះ" តើលោកមានន័យយ៉ាងម៉េចដែរ ទៅលើពាក្យ "ពេលដែលខ្ញុំចាកចេញទៅនេះ"។

**ឆ៖** ខ្ញុំដូចជាយកចម្លើយខ្ញុំអំមិញ ហើយនិងសំណួរសួរអំមិញគឺខ្ញុំទទួលត្រូវឆ្លើយទៀតហ្នឹង ដូចឆ្លើយ រកកន្លែងឆ្លើយអត់ឃើញ។ សួរថាពេលចាកចេញទៅ ហើយតើបានឮពីប្រជាជនថាយ៉ាងម៉េចខ្លះ? ហើយដល់អ៊ីចឹង ខ្ញុំមិនដឹងថាឆ្លើយយ៉ាងម៉េច ហើយសួរៗរឿងអី អត់ ដូចទទួលៗការស្តាប់ហ្នឹងនូវចម្លើយ នូវសំណួរហ្នឹងអត់បាន ហើយដល់អ៊ីចឹងខ្ញុំរកវិធីឆ្លើយអត់ទាន់ឃើញ មិនដឹងខ្ញុំឆ្លើយយ៉ាងម៉េច។

**ប្រធានអង្គជំនុំ៖**

លោកមេធាវីរៀបចំសំណួរឡើងវិញ ហើយសូមសម្រួលសំណួរធ្វើយ៉ាងណាឲ្យគោលដៅនៃការឆ្លើយ ត្រូវឆ្លើយហ្នឹងគឺស្តាប់យល់នូវសំណួរដែលបានសួរ នោះជាការល្អ។

[១០:២៦:១០]

**លោក ហ្សាស្តេ ប៉ោ៖**

សូមអរគុណលោកប្រធាន។ ខ្ញុំទុកចំណុចនេះមួយឡែកសិន ដោយសារតែការទំនាក់ទំនងរបស់យើងឆ្លើយឆ្លងគ្នាប្រហែលជាវានៅមានការយល់ច្រឡំ តែខ្ញុំនឹងធ្វើការបញ្ជាក់បំភ្លឺក្រោយពីយើងឈប់សម្រាកត្រង់ចំណុចនេះឡើងវិញ។

**សួរដោយលោក ហ្សាស្តេ ប៉ោ៖**

**ស៖** លោក ខៀវ អេន កាលពីម្សិលមិញសហព្រះរាជអាជ្ញាបានសួរលោកនូវសំណួរមួយចំនួន ខ្ញុំនឹងដកស្រង់សំណួរនោះចេញមកពីប្រតិចារឹក ត្រង់ទំព័រ៣៥ នៃភាសាអង់គ្លេសនៃប្រតិចារឹកជាភាសា

អង់គ្លេសទំព័រ៣៥។ សំណួរបានសួរលោកថា សហព្រះរាជអាជ្ញាបានសួរលោកថា "តើលោកដឹងទេក្រៅពីការងារជា -- ក្រៅពីជាសមាជិកអចិន្ត្រៃយ៍នោះ តើគាត់មានតួនាទីអ្វីទៀតនៅក្នុងក្រសួងឃោសនាការនេះ" សំណួរនេះគឺអំពីបញ្ហា នួន ជា។ លោកបានឆ្លើយថា ខ្ញុំដកស្រង់សម្ដីដែលលោកឆ្លើយ "ខ្ញុំមិនដឹងតួនាទីរបស់គាត់នោះទេ នៅពេលដែលគាត់មកនោះគឺខ្ញុំមិនដឹងថាគាត់មានតួនាទីកាន់កាប់នៅក្រសួងនោះជាអ្វីនោះទេ។ រាល់ព្រឹកគឺខ្ញុំឃើញគាត់មកអើត ក៏ប៉ុន្តែខ្ញុំមិនដឹងថាគាត់ក្ដោបក្ដាប់រួមនូវការងារក្រសួងនោះយ៉ាងម៉េចនោះទេ ខ្ញុំមិនដឹងទេ នៅពេលនោះ"។ លោក ខៀវ អេន តើលោកអាចជួយពន្យល់យើងខ្ញុំបានដែរឬទេថា ហេតុអ្វីបានជាលោកមិនដឹងអំពីតួនាទីរួមទាំងមូលរបស់គាត់នៅក្នុងក្រសួងឃោសនាការនោះ?

[១០:២៨:០៨]

**លោក ខៀវ អេន៖**

**ឆ៖** ខ្ញុំសូមឆ្លើយសំណួរនេះតទៀត។ ពាក្យថា ខ្ញុំមិនដឹងនេះដោយសារថា គ្មានពេល ឬមួយក៏ជាអង្គប្រជុំណាមួយថា ឲ្យខ្ញុំទៅចូលរួមហើយថា "ឥឡូវលោក នួន ជា គាត់មកទទួលខុសត្រូវជំនួសលោក យុន យ៉ាត អីក្នុងការទទួលខុសត្រូវក្នុងក្រសួងនេះ។ អាហ្នឹងវាអត់មាន តែគ្រាន់តែសកម្មភាពការងារជាក់ស្ដែងហ្នឹង ត្រង់ថាដក យុន យ៉ាត ហើយ ឃើញគាត់អញ្ជើញមកៗជួប មកធ្វើការងារហ្នឹងព្រឹកៗឃើញមក ហើយដល់មកគាត់ទៅកន្លែងគាត់ ខ្ញុំមកកន្លែងខ្ញុំធ្វើការធម្មតាទៅ។ ហើយពេលខ្លះឃើញ ពេលខ្លះអត់ ដូចខ្ញុំបញ្ជាក់អ៊ីចឹង ហើយពេលគាត់ចេញទៅក៏ខ្ញុំមិនដឹង ហើយពេលខ្លះឃើញតែគាត់មក ដល់ពេលចេញក៏ៗយើងមិនឃើញ ហើយគាត់នៅលើ នៅកន្លែងគាត់ក៏យើងមិនដឹង។ ហើយអាកម្មវិធីដែលប្រកាសថា គាត់មកទទួលក៏យើងអត់ដឹង។ តែគ្រាន់តែការងារឃើញគាត់មកអ៊ីចេះ។ ហើយទទួលដែលមកហើយ គឺថា យុន យ៉ាត ហ្នឹងត្រូវគេដកចេញ។ ហើយដល់អ៊ីចឹងជាៗឯកសារ ហើយដែលខ្ញុំបានដឹង បានឮថា គាត់មានប្រជុំអីបញ្ជាក់ថា នួន ជា ត្រូវមកទទួលចេះចុះ ខ្ញុំអត់ៗបានដឹងទេ។ នេះខ្ញុំបញ្ជាក់អ៊ីចឹងបាទ តែសកម្មភាពឃើញអ៊ីចឹង។ បាទ សូមអស់មតិប៉ុណ្ណឹង។

[១០:៣០:០៨]

**ស៖** បន្តទៅនឹងចម្លើយដែលលោកបានឆ្លើយ។ ម្សិលមិញនេះ គឺលោកបានឆ្លើយថា "គាត់មានថ្ងៃមួយនោះ មកអើតមើលបន្តិចបន្តួច។ ស្អែកឡើងហ្នឹង ក៏គាត់មកអើតមើលម្ដងទៀតដែរ មកមើលមួយភ្លែត" គឺត្រង់ទំព័រ៨៥ នៅក្នុងប្រតិចារឹកជាភាសាអង់គ្លេស។ ខ្ញុំសូមសួរសំណួរឡើងវិញ។ តើ

លោកអាចនិយាយបានដែរឬទេថា នួន ជា នោះគឺទម្លាប់របស់គាត់នោះ គឺនៅក្នុងមួយថ្ងៃហ្នឹង គឺគាត់មកមើលមួយភ្លែត ហើយដល់ស្អែកឡើងទៅគាត់អាចមកមើលយូរបន្តិចទៅលើការងាររបស់អ្នកនៅក្នុងក្រសួងហ្នឹង។ តើអ៊ីចឹងដែរឬទេ លោកអាចនិយាយអ៊ីចឹងបានដែរឬទេ?

**ឆ៖** ខ្ញុំសូមនិយាយថា ម្សិលមិញក៏ខ្ញុំមាននិយាយ ហើយថ្ងៃនេះ សួរបញ្ជាក់ ខ្ញុំនិយាយបន្ថែមទៀតថា ចរិតក្នុងនាមជាអ្នកដឹកនាំ ខ្ញុំមិនថាលោក នួន ជា តែខ្ញុំបញ្ជាក់ជាទូទៅថា គេដើរមើល មិនអាចកំណត់ថាម៉ោងនេះយូរ ម៉ោងនោះខ្លី។ តែអើតទីនេះបន្តិច អើតទៅនោះបន្តិចទៅ។ កន្លែងខ្លះជួបអ្នកស្គាល់ទៅ គាត់និយាយយូរបន្តិចទៅ។ កន្លែងខ្លះ បើអត់ស្គាល់ គាត់ដើរតែអើត ដើរតែមើលទៅ។ អានេះជាចរិតរបស់អ្នកដឹកនាំទូទៅ។ ឯគាត់ហ្នឹង ក៏ខ្ញុំបញ្ជាក់ថា កាលហ្នឹង ក៏គាត់ជាអ្នកដឹកនាំមួយដែរ ដល់អ៊ីចឹងដូចពាក្យខ្ញុំថា គាត់ទៅអើតមើលទៅ អ្នកខ្លះហាមកុំឲ្យជក់ថ្នាំ ជក់បារីអីទៅ ហើយអ្នកខ្លះឲ្យហាត់ងើបហាត់ប្រាណ។ ខ្លះទៅបើកឆ្នាំងគេទៅ បានអីហូប ស្ងួរ។ នេះក្នុងៗ ពេលដែលខ្ញុំរស់នៅហ្នឹង ពេលដែលគាត់ទៅទទួលហ្នឹង ខ្ញុំឃើញលក្ខណៈហ្នឹង។ ហើយបើមិននិយាយថាយូរ វែងពេលអីអ៊ីចេះ អ៊ីចុះអាហ្នឹងខ្ញុំនិយាយអត់កើតទេ។ តែគ្រាន់តែថា ការដើរអើត ដើរមើល ដើរសួរលិច កើត អ្នកណាឈឺអ្នកណាថ្កាត់អីអ៊ីចេះអ៊ីចុះ អាហ្នឹងមាន។ អានេះខ្ញុំសូមបញ្ជាក់ជូនអ៊ីចឹងបាទ។ និយាយតែស្អីដែលឃើញដឹងឮប៉ុណ្ណឹងបាទ។ សូមអស់មតិបាទ។

[១០:៣២:៤៣]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណច្រើន។ ឥឡូវនេះដល់ពេលសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាក២០នាទីចាប់ពីពេលនេះតទៅ រហូតដល់ម៉ោងដប់មួយ ខ្ទះដប់នាទី សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលផ្តល់កន្លែងសម្រាកនៅបន្ទប់រង់ចាំសម្រាប់សាក្សីនៅក្នុងអំឡុងពេលឈប់សម្រាក និងឲ្យអញ្ជើញគាត់មកកាន់កន្លែងផ្តល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការនេះវិញនៅវេលាម៉ោងដប់មួយ ខ្ទះដប់នាទី។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១០:៣៣ នាទី ដល់ម៉ោង ១០:៥៣ នាទី)*

[១០:៥៣:៥០]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ ហើយនិងផ្តល់វេទិកាជូនទៅក្រុមមេធាវីការពារក្តីលោក នួន ជា ដើម្បីមានឱកាសបន្តការតាំងសំណួរដេញដោលចំពោះសាក្សីរូបនេះ។ សូមអញ្ជើញ!

**លោក ហ្សាស្តើ ប៉ោ៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោក ហ្សាស្តើ ប៉ោ៖**

**ស៖** លោកសាក្សី ខៀវ អេន មុនពេលដែលយើងឈប់សម្រាក លោកបានបញ្ជាក់ថា "មិនមានការប្រជុំណាមួយ ដែលមានការប្រកាសថា លោក នួន ជា ហ្នឹងត្រូវទទួលខុសត្រូវទៅលើក្រសួងឃោសនាការនោះទេ"។ តើខ្ញុំអាចនិយាយបានដែរឬទេថា លោកសន្និដ្ឋានថា ការងារទាំងអស់ហ្នឹងគឺផ្អែកទៅលើសកម្មភាពរបស់លោក នួន ជា នៅក្រសួងឃោសនាការ គឺថា ដោយសារតែផ្អែកទៅលើសកម្មភាពរបស់លោក នួន ជា នៅក្រសួងនេះ ទើបលោកសន្និដ្ឋានថា គាត់គឺជាអ្នកទទួលខុសត្រូវនៅក្រសួងឃោសនាការនោះ?

[១០:៥៥:២១]

**លោក ខៀវ អេន៖**

**ឆ៖** ខ្ញុំសូមឆ្លើយបាទ។ ន័យដែលខ្ញុំបានបញ្ជាក់ហើយ តែសំណួរនៅបានលើកតាំងមកសួរទៀត។ ខ្ញុំសូមបញ្ជាក់បន្ថែមទៀតថា ដោយឃើញការងារជាក់ស្តែង ក្នុងនាមខ្ញុំជាបុគ្គលិកម្នាក់នៅហ្នឹងគឺថា ពីមុន ហ៊ូ នឹម ៗទទួល។ អាហ្នឹងការងារខាងលើខ្ញុំអត់ដឹងទេ។ តែឃើញៗតែអ្នកដែលនៅហ្នឹងដឹងតែ ហ៊ូ នឹម បាទ។ ហ៊ូ នឹម ហើយ យុន យ៉ាត មកទទួល។ ដល់ យុន យ៉ាត ចេញទៅទៀត ឃើញលោក នួន ជា មកទទួល។ ហើយដល់អ៊ីចឹង អារឿងការងារខាងលើជាៗទិដ្ឋភាពដឹងថាការចាត់ចែង ចាត់ -- ការរៀបចំរបស់ខាងលើហ្នឹងយ៉ាងម៉េចៗខ្ញុំអត់ដឹងទេ។ តែគ្រាន់តែក្នុងន័យថាទទួលហ្នឹងគឺថា ឃើញមកស្នាក់នៅសម្រាប់មើលការខុសត្រូវនៅពីលើអ្នកដែលនៅក្នុង ក-៣៣ ហ្នឹង។ ដូចថា ដកបុគ្គលដែល

ខ្ពស់ៗ ធ្លាប់មានមុនហ្នឹងមួយៗទៅ ដល់នេះឃើញចុងក្រោយមក ឃើញគាត់មកទទួលហ្នឹង។ ដល់អ៊ីចឹង ក្នុងន័យដែលខ្ញុំបញ្ជាក់ខាងដើមហើយហ្នឹងថា ការឲ្យបានទៅប្រជុំប្រកាសថា គាត់មកទទួលអ៊ីចេះអ៊ីចុះ អត់មានទេ តែឃើញពីសកម្មភាពការងារគាត់មក។ គាត់មកបាទ។ ផុតពី យុន យ៉ាត ទៅគាត់មកនៅ។ ដូចថា ពីមុនដែលធ្លាប់ឃើញ យុន យ៉ាត ចេញមកព្រឹកមកល្ងាចអី គាត់ទៅមកតាមពេលវេលាដែលគាត់ លៃមកបាន គាត់មក។ តែដល់ផុតពីហ្នឹងទៅ ឃើញ នួន ជា ក៏មកអ៊ីចឹង។ មកពេលថ្វើរម៉ានគាត់មក គាត់មក ពេលគាត់ទៅវិញ ក៏ៗអាហ្នឹងរឿងការងាររបស់គាត់។ នេះក្នុងន័យដែលសន្និដ្ឋាន ឲ្យមានកម្ម វិធីប្រកាសថា គាត់ទទួលរួមធ្វើអីយ៉ាងម៉េចៗនៅក្រសួងហ្នឹង ខ្ញុំអត់ដឹងទេ គ្រាន់តែដឹងថា ឃើញដំណើរ ដែលមាននៅក្នុងកន្លែងហ្នឹងវាអ៊ីចឹង។ នេះ សូមមានមតិអ៊ីចឹងបាទ។

[១០:៥៧:៣០]

**សៈ** សូមអរគុណចំពោះចម្លើយរបស់លោក។ ខាងសហព្រះរាជអាជ្ញាបានសួរ -- ខាងសហ ចៅក្រមស៊ើបអង្កេតបានសួរលោកថា "តើលោកធ្លាប់ចូលរួមនៅការប្រជុំដែលមាន នួន ជា ជា -- ដែល ធ្វើការរៀបចំឡើងដោយ នួន ជា ដែរឬទេ?" ហើយលោកបានឆ្លើយថា "ខ្ញុំគិតថា ប្រហែលជាមានការ ប្រជុំតូចតាច តិចតួច"។ គឺខ្ញុំដកស្រង់ចេញពីឯកសារ E3/438, ភាសាអង់គ្លេស លេខ 00375874, ភាសាខ្មែរមាន 00373434 កាលពីម្សិលមិញនេះគឺគេសួរលោកនូវសំណួរដែលពាក់ព័ន្ធទៅលើបញ្ហានេះ គឺគេសួរថា "តើលោកធ្លាប់ចូលរួមការប្រជុំដែលដឹកនាំដោយ នួន ជា ដែរឬអត់?" ហើយលោកបាន ឆ្លើយជាថ្មីម្តងទៀតថា "ប្រសិនបើខ្ញុំធ្លាប់ចូល ក៏ប្រហែលជាមានតិចតួចដែរ គឺមានកិច្ចប្រជុំតិចតួច ហើយមិនធំដុំនោះទេ គឺកិច្ចប្រជុំតូចតាច គឺអាចថាជាការរៀបចំ ប្រជុំរៀបចំរចនាសម្ព័ន្ធឡើងវិញជា ដើម"។ គឺថាមិនមានការដកស្រង់ចេញពីប្រតិចារឹកទេ ប៉ុន្តែជាការកត់ត្រាផ្ទាល់ខ្លួនរបស់ខ្ញុំ។ ដូច្នេះខ្ញុំចង់ សួរលោក ខៀវ អេន ថាចម្លើយរបស់លោក ដែលបញ្ជាក់ថា លោកមិនប្រាកដ លោកមិនច្បាស់ ថាតើលោកធ្លាប់ចូលរួមកិច្ចប្រជុំឬអត់នោះ គឺថា ចូលរួមកិច្ចប្រជុំដែលដឹកនាំដោយ នួន ជា ឬក៏អត់នោះ តើវាត្រឹមត្រូវដែរឬទេ ដែលថាលោកមិនប្រាកដថាលោកធ្លាប់ចូលរួមកិច្ចប្រជុំណាមួយ ដែលដឹកនាំ ដោយលោក នួន ជា នោះ?

[១០:៥៩:៣០]

**ឆះ** ខ្ញុំសូមឆ្លើយ។ សំណួរនេះ ក៏សួរហើយ ឆ្លើយពីម្សិលមិញ។ តែសំណួរថ្ងៃនេះសួរបញ្ជាក់ ទៀតក៏មិនខុសពីម្សិលមិញដែរ គឺថា ជាការប្រជុំអីដែលធំដុំ ដូចជាខ្ញុំមិនដែលបានចូលរួមទេ។ តែបើ

ជាការងារតិចតួច ប្រហែលជាមាន។ ព្រោះបានជាខ្ញុំបញ្ជាក់អ៊ីចឹងគឺថា ខ្ញុំជាមនុស្សបច្ចេកទេសហ្នឹងគឺ វាចោលការងារហ្នឹងអត់បាន ហើយវាមានគេនៅពីលើខ្ញុំទៀត។ ដល់អ៊ីចឹងបើអ្នកខាងលើទៀតគេហៅប្រជុំអីៗទៀតអាហ្នឹងខ្ញុំអត់ដឹងទេ។ អាហ្នឹងរឿងការងារគេទៀត តែដល់ខ្ញុំនឹង ខ្ញុំចាំទទួលពីស្អីដែលអ្នកពីលើខ្ញុំដែលគ្រប់គ្រងខ្ញុំនឹងគេឲ្យមកខ្ញុំដឹងតែធ្វើតាមគេ។ ដល់អ៊ីចឹងបើអ្នកខាងលើទៀតគេទៅធ្វើ គេទៅប្រជុំអីជាមួយគាត់ទៀតអាហ្នឹងខ្ញុំអត់ដឹងទេ តែដល់ខ្ញុំផ្ទាល់ការប្រជុំហ្នឹង ដូចខ្ញុំបញ្ជាក់អ៊ីចឹងប្រហែលជាមានតិចតួចមិនអត់ទេ។ តែខ្ញុំរកកាលកំណត់រកពេលវេលាថា ខ្ញុំប្រជុំបានប៉ុណ្ណោះដង ប៉ុណ្ណោះដងរឿងអី អាហ្នឹងខ្ញុំបញ្ជាក់អត់បានទេ។ ដោយសារថា ខ្ញុំដូចជាអត់មានចងចាំអីច្រើនតែដឹងថា មានប្រជុំតែជារឿងអីដុំកំភួន ជារឿងអីការងារអីធំដុំអត់ទេ។ ព្រោះខ្ញុំហ្នឹងមនុស្សវានៅក្នុងបច្ចេកទេសហ្នឹងគឺថាដើរៗទៅណាអត់រួច ដល់អ៊ីចឹងចាំតែទទួលពីមេដែលទទួលខុសត្រូវខ្ញុំ ដែលថា អុល ដែលខ្ញុំបញ្ជាក់ហ្នឹងគេប្រើធ្វើអីខ្ញុំធ្វើតាមគេទៅ។ ហើយបើនៅហ្នឹងគេហៅទៅប្រជុំទៀត អាហ្នឹងរឿងៗអ្នកខាងលើទៀតខ្ញុំអត់ដឹង។ នេះសូមមានមតិប៉ុណ្ណឹង។

[១១:០១:២២]

**ស៖** ដើម្បីឲ្យមានការបញ្ជាក់ច្បាស់លាស់ខ្ញុំយល់ថា លោកបានចូលរួមនៅការប្រជុំតូចតាចដែលមិនសូវជាសំខាន់នោះ។ តើលោកចាំដែរឬទេថាតើកិច្ចប្រជុំដែលលោកចូលរួមហ្នឹងគឺដឹកនាំដោយលោក នួន ជា ឬក៏អត់? ប្រសិនបើលោកចាំសូមបញ្ជាក់ ប្រសិបើលោកមិនចាំទេវាមិនមានបញ្ហាអ្វីនោះទេ?

**ឆ៖** ខ្ញុំសូមឆ្លើយ។ ខាងដើមដូចខ្ញុំបញ្ជាក់ដែរហើយ។ បើប្រជុំប្រចាំថ្ងៃហ្នឹង អាហ្នឹងរាល់ល្ងាចហ្នឹង អាហ្នឹងប្រធានមន្ទីរគេប្រជុំតែម្តង។ ល្ងាចឡើងដឹងតែប្រជុំហើយ តែបើជាមួយ នួន ជា ដូចខ្ញុំបញ្ជាក់ថា ខ្ញុំមិនបដិសេធថា អត់ទេ តែការងារវាធំដុំអីដែលទៅប្រជុំជាមួយគាត់អត់។ ហើយបើតូចតាចប្រហែលជាមាន បើតិចតួចតែខ្ញុំអត់ចាំ រកកំណត់អត់កើតទេ។ ហើយបើប្រជុំពីការងាររឿងកំប៉ិកកំប៉ុកជុំវិញការងារបច្ចេកទេសរបស់ខ្ញុំហ្នឹងទេ។ ឯរឿងៗការងារអីដែលៗហួសពីការងារខ្ញុំហ្នឹង ខ្ញុំអត់មានដែលបានចូលរួមដឹងឮអីទេ។ នេះសូមមានមតិប៉ុណ្ណឹង។

[១១:០២:៤៩]

**ស៖** សូមអរគុណ គឺលោកបានបញ្ជាក់ច្បាស់ទៅលើបញ្ហានេះហើយ។ លោកក៏បានបញ្ជាក់ផងដែរថា លោកបានស្តាប់តាមវិទ្យុថា នួន ជា គឺជាសមាជិកគណៈអចិន្ត្រៃយ៍។ តើលោកអាចប្រាប់បាន

ដែរឬទេ ថាតើលោកស្ដាប់ឮវិទ្យុហ្នឹង គឺឮនៅពេលណា?

**ឆ៖** ខ្ញុំសូមឆ្លើយថា កាលបរិច្ឆេទថាពេលព្រឹកពេលល្ងាចអីហ្នឹងដូចជាកំណត់មិនបានទេ។ វាមិនខុសអីដែលខ្ញុំមើលទូរទស្សន៍ ស្ដាប់វិទ្យុរាល់ថ្ងៃនេះ វាមិនដឹងជាឮថ្ងៃណាអីថ្ងៃណា ជួនកាលចេះតែឮមកហើយដល់អ៊ីចឹង ខ្ញុំគ្រាន់តែបញ្ជាក់ថា ពាក្យនេះធ្លាប់ឮបាទ។ ពាក្យនេះធ្លាប់ឮ ឮដោយការស្ដាប់វិទ្យុបាទ តែពេលវេលាណាអីណា ហ្នឹងបញ្ជាក់អត់បានទេ។ អត់មានបរិច្ឆេទអីថា ខ្ញុំស្ដាប់បានពេលព្រឹកពេលល្ងាចអី ឬថ្ងៃនេះថ្ងៃនោះ ខែនេះខែនោះ អត់ទេ។ បាទ សូមមានមតិ។

[១១:០៤:០២]

**ស៖** ខ្ញុំយល់ថាលោកអត់ចាំថាតើលោកស្ដាប់ឮពេលព្រឹក ឬពេលល្ងាច។ ខ្ញុំមិនចង់ឲ្យលោកបញ្ជាក់ដល់លម្អិតបែបនេះទេ ប៉ុន្តែតើលោកអាចប្រាប់បានទេថា ក្នុងឆ្នាំណាដែលលោកស្ដាប់ឮការប្រកាសបែបនេះនៅតាមវិទ្យុនោះ?

**ឆ៖** កន្លែងនេះក៏ខ្ញុំឆ្លើយអត់បាន។ ឆ្លើយអត់បានឃើញថា ខ្ញុំអត់ចាំថាឆ្នាំណា ខ្ញុំ ឧបមាថាមកទទួលគាត់ត្រូវទទួលអ៊ីចឹងហើយឆ្នាំណាដែលខ្ញុំស្ដាប់ ខ្ញុំឆ្លើយអត់បាន។ តែគ្រាន់តែថា ខ្ញុំគ្រាន់គិតថាអង្គាល់ហ្នឹងវាដូចមិនមានថាជាសម្ងាត់អីទេ ព្រោះប្រកាសហ្នឹងជាចំហផ្សាយតាមវិទ្យុផ្សាយអីហើយ។ តាមមិនដឹងឆ្នាំណាប្រកាស ខ្ញុំក៏ខ្ញុំអត់ចាំដែរ។ តែគ្រាន់ថា ពាក្យហ្នឹងថា ន័យហ្នឹងដែលៗផ្សព្វផ្សាយហ្នឹងគឺថាវាអត់មានការបិតបាំងថា អូ! អត់ឲ្យដឹង អត់ឲ្យអីទេ គឺថាពាក្យហ្នឹងគឺថា វាផ្សាយចេញតាមវិទ្យុហើយបាទ។

**ស៖** ប្រសិនបើលោកមិនចាំច្បាស់អំពីឆ្នាំ ថាតើលោកចាំដែរឬទេថា គេផ្សព្វផ្សាយហ្នឹងនៅពេលដែលលោកទើបមកដល់ក្រសួងឃោសនាការ ឬមួយក៏នៅទៅដល់ចុង ឬក៏គឺថាទៅដល់ចុងពេលដែលថាជិតដល់ពេលវៀតណាមចូល គឺទៅដល់ជិត៧៩ ហ្នឹង។ តើពេលណាមួយដែរ?

**ឆ៖** ខ្ញុំសូមឆ្លើយ។ ពាក្យនេះ ពីមុនមកក៏ខ្ញុំ គាត់ក៏ខ្ញុំអត់ស្គាល់ ហើយពាក្យនេះក៏ដូចជាមិនទាន់បញ្ចេញឮ។ អាហ្នឹងខ្ញុំនិយាយអ៊ីចឹង តែគ្រាន់ថាខ្ញុំមិនបានកំណត់ថាត្រឹមត្រូវទាំងអស់ទេ។ តែគ្រាន់ខ្ញុំក៏មិនទាន់ស្គាល់គាត់ ហើយពាក្យហ្នឹងក៏ដូចជាខ្ញុំមិនទាន់ដឹង មិនទាន់ឮអីប៉ុន្មាន ដែលៗខ្ញុំពាក្យថាឮតាមវិទ្យុហ្នឹង ប្រហែលជាឮមកចុងឆ្នាំហើយទេ ចុង -- មុនៗដកចេញពីភ្នំពេញហ្នឹង តែដល់មុនទៀតហ្នឹងដូចខ្ញុំបញ្ជាក់ខាងដើមថា ខ្ញុំទៅវាជួបតែខាង ហ៊ូ នឹម ដល់អ៊ីចឹង នួន ជា អីណាណីហ្នឹង ខ្ញុំអត់ដឹងទេ យុន យ៉ាត ហ្នឹងក៏អត់ដឹងដែរ។ ស្រាប់តែបាត់ ហ៊ូ នឹម ទៅឃើញ យុន យ៉ាត។ ហើយអាដំណើរថាគេទមុន

អាហ្នឹងគេដឹងរឿង ដល់ខ្ញុំទៅក្រោយដូចរីមរើមៗដូចអាដែងគេថាយកមកចូលកន្លែងថ្មី វាអត់ដឹងរឿងអី។ ដល់អ៊ីចឹងចេះតែមើលគេ ចេះតែអីទៅ។ ដល់អ៊ីចឹងពាក្យដែលឮនេះ ថាជាៗគណៈអចិន្ត្រៃយ៍អីនេះ ទទួលឃើញគាត់ហើយ បានឮពាក្យនេះដែរ។ និយាយឲ្យៗការស្រមើស្រមៃដែលខ្ញុំគិតទៅវិញបកក្រោយវិញហ្នឹង គឺថាពីមុនហ្នឹងដូចជាមិននឹកនា មិនដឹងអី យល់អីផង។ ស្គាល់តែមនុស្សដែលខ្លួនចូលទៅឃើញ ដឹងឮតែរឿងមនុស្សឃើញបាទ។ សូមអស់។

[១១:០៧:៤៣]

**ស៖** តើលោកដឹងដែរឬទេ ថាគណៈអចិន្ត្រៃយ៍ហ្នឹងគឺជាអ្វី? នៅពេលដែលលោកបានស្តាប់ឮគេប្រកាសថា នួន ជា ជាសមាជិកគណៈអចិន្ត្រៃយ៍នោះ?

**ឆ៖** ខ្ញុំសូមឆ្លើយ។ ពីមុនកាលនុ៎ងឮហើយក៏ដូចជាគ្មានបានយកមកគិតអីថា គណៈអចិន្ត្រៃយ៍ហ្នឹងស្អីគេៗ អត់ទេ។ មិនដឹងស្អីផងទេ មែនទែននោះ វាអត់ដូចថា មើលទៅចែកដាច់ដូចយើងឥឡូវនេះថា អូ! នេះធ្វើអីៗច្បាស់ទេ។ គ្រាន់តែឮអ៊ីចឹង ក៏មិនៗចាប់អារម្មណ៍ថា អាហ្នឹងត្រូវធ្វើអ្វី ត្រូវទទួលអីការងារអី អត់ទេ។ ដូចខ្ញុំបញ្ជាក់ថា ខ្ញុំដឹងតែរឿងខ្ញុំទេ ហើយទទួលដែលឃើញគាត់មកស្គាល់គាត់ហើយដែលថាឮថា នួន ជាៗ ថាគណៈអចិន្ត្រៃយ៍ហ្នឹង បានក្រោយមកក៏ថា អឺ! ផុតពី ប៉ុល ពត មកគាត់អ៊ីចេះ។ នេះពាក្យហ្នឹងគឺថាយើងមិនបានដឹងជ្រៅ តែពាក្យនេះបានឮៗបាទ។ ការស្វែងយល់របស់ខ្ញុំៗមិនបានស្វែងយល់ តែពាក្យនេះបានឮ។ តែឲ្យខ្ញុំទៅស្វែងយល់ថា អ្វេ នួន ជា អ៎! ប៉ុល ពត ជាបុគ្គលទី១ ហើយផុតពីហ្នឹងមក នួន ជា។ ស្វែងយល់ខ្លួនឯងអ៊ីចឹងអត់មានទេៗបាទ។ គ្រាន់តែដឹងពីក្រៅមកថាផុតពី ប៉ុល ពត មកគឺ នួន ជា។ ដឹងថាអ៊ីចឹង។ នេះសូមមានមតិប៉ុណ្ណឹងបាទ។

[១១:០៩:២៩]

**ស៖** ដើម្បីបញ្ជាក់ឲ្យបានច្បាស់ទៅលើបញ្ហាចុងក្រោយនេះ ថាតើអ្នកណាជាមនុស្សដែលប្រាប់លោកថា នួន ជា គឺជាមនុស្សទី២ គឺជាអនុបន្ទាប់ពី ប៉ុល ពត នោះ?

**ឆ៖** កន្លែងនេះ ខ្ញុំរកការចាំឈ្មោះចាំអីអត់បានទេ រកអត់ឃើញទេ។ តែគ្រាន់ថាការងារខ្ញុំ ដល់ចេញផុតពីការងារខ្ញុំមក ខ្ញុំមកអង្គុយលេងទៅ គេនិយាយលេងទៅ ឮតែតាមគេអ៊ីចឹងទៅ។ អាហ្នឹង ខ្ញុំហើយដល់បញ្ជាក់ថា ឈ្មោះអីៗ វាអត់ អាហ្នឹងគេហៅ កន្លែងខ្លះ គេនិយាយធម្មតាទៅ យើងគ្រាន់តែឮត្រចៀកស្តាប់ទៅ។ ហើយអត់បានគិតគូរពិចារណាថា អូ! ម៉េចអីម៉េច ព្រោះដូចខ្ញុំថា ខ្ញុំអត់មានពេលទៅសិក្សាស្រាវជ្រាវរឿងខាងលើ រឿងណាអី ណាណីម៉េចៗអត់ទេ តែពាក្យនេះ ខ្ញុំបានឮ។ នេះ ខ្ញុំសូម

បញ្ជាក់ត្រង់។

**ស៖** ខ្ញុំច្បាស់ហើយ អំពីបញ្ហានេះ។ យើងបាននិយាយកាលពីពេលមុន អំពីលោក គឹម វុន។ លោក គឹម វុន បានមកផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះនេះរួចហើយ ហើយគាត់បានផ្តល់សក្ខីកម្មអំពីក្រសួងឃោសនាការផងដែរ ហើយក៏គាត់បានផ្តល់សក្ខីកម្មអំពីតួនាទីរបស់ យុន យ៉ាត ផងដែរ។

[១១:១១:០៨]

លោក គឹម វុន បានពន្យល់ថា មានក្រសួងពីរ គឺក្រសួងឃោសនាការអប់រំ និងមួយទៀត គឺក្រសួងអប់រំ។ លោក គឹម វុន បានបញ្ជាក់ថា គឺគាត់បានបញ្ជាក់នៅចំពោះមុខអង្គជំនុំជម្រះនេះថា យុន យ៉ាត ទទួលខុសត្រូវក្រសួងទាំងពីរ។ គឺគាត់ទទួលខុសត្រូវលើក្រសួងទាំងពីរ រហូតដល់ពេលដែលវៀតណាមចូល គឺរហូតដល់ថ្ងៃ០៦ មករា ១៩៧៩។ យោងទៅតាមលោក គឹម វុន "នួន ជា មកក្រសួងឃោសនាការតែនៅពេលណាដែល យុន យ៉ាត អវត្តមានប៉ុណ្ណោះ។ ហើយ នួន ជា គាត់ផ្តោតតែទៅលើកម្មវិធីអប់រំអំពីកសិកម្មប៉ុណ្ណោះ"។ លោក គឹម វុន ក៏បានផ្តល់សក្ខីកម្មផងដែរថា "នួន ជា មិនធ្វើការនៅក្រសួងក្នុងតួនាទីអចិន្ត្រៃយ៍នោះទេ ក្នុងតួនាទីប្រចាំនោះទេ"។ ហើយលោក គឹម វុន ក៏បានផ្តល់សក្ខីកម្មបន្ថែមថា "មិនមានរដ្ឋមន្ត្រីណាផ្សេងក្រៅពី យុន យ៉ាត ដែលត្រូវទទួលខុសត្រូវនៅក្រសួងឃោសនាការនោះឡើយ"។ នេះគឺជាសក្ខីកម្មរបស់លោក គឹម វុន។ ហើយលោកបានបញ្ជាក់ថា លោកបានស្គាល់លោក គឹម វុន ហើយលោកបានបញ្ជាក់ថា លោកធ្វើការជាមួយលោក គឹម វុន នៅក្រសួងឃោសនាការដែរ។

[១១:១៣:០៥]

ដូច្នេះ សំណួរទី១ ដែលខ្ញុំចង់សួរលោកដូចតទៅនេះ។ តើលោកដឹងដែរទេ ថាតើចម្លើយរបស់លោក គឹម វុន ហ្នឹង គឺត្រឹមត្រូវ។ គឺចម្លើយដែលថា "លោក នួន ជា ទទួលខុសត្រូវផ្តោតសំខាន់តែទៅលើកម្មវិធីអប់រំកសិកម្មនុ៎ង"។ តើលោកដឹងដែរឬទេ ថា នួន ជា ផ្តោតតែទៅលើកម្មវិធីកសិកម្ម -- កម្មវិធីអប់រំកសិកម្មនោះ?

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប!

សូមអញ្ជើញតំណាងសហព្រះរាជអាជ្ញា!

[១១:១៣:៤៨]

**លោក ឌេល លីសាក់៖**

លោកប្រធាន ខ្ញុំមានការជំទាស់ ដោយថាមេធាវីគាត់សួរសាក្សីអំពីសក្ខីកម្មរបស់សាក្សី គឹម វុន។ ដោយគាត់គួរតែផ្តល់នូវសក្ខីកម្ម ហើយយើងជំទាស់ទៅលើការនិយាយបែបនេះ។ តាមដែលខ្ញុំចាំ លោក គឹម វុន គ្រាន់តែផ្តល់ព័ត៌មានដែលថា អ្វីដែលគាត់បានសង្កេតឃើញ នៅពេលដែលគាត់ឃើញ នួន ជា។ គាត់មិនមែននិយាយអ្វីៗទាំងអស់ ទាក់ទងទៅនឹងអ្វីដែលលោក នួន ជា បានធ្វើនៅក្នុងក្រសួង នោះទេ។ ដូច្នេះ ខ្ញុំគិតថា មេធាវីប្រហែលជាផ្តល់នូវព័ត៌មានដែលមិនច្បាស់លាស់ ដូច្នេះ ខ្ញុំចង់ឲ្យគាត់ -- នៅពេលដែលគាត់និយាយអំពីសក្ខីកម្មជាក់លាក់ណាមួយ សូមឲ្យគាត់ដកស្រង់នូវឯកសារយោងទៅលើសក្ខីកម្មទាំងអស់នោះ។

**លោក ហ្សាស្តេ ប៉ោ៖**

លោកប្រធាន ខ្ញុំនឹងធ្វើបែបនេះ។ ខ្ញុំនឹងផ្តល់នូវព័ត៌មានបែបនេះ គឺជាសក្ខីកម្មរបស់លោក គឹម វុន ទាក់ទងទៅនឹងសាក្សី។ ហើយខ្ញុំរីករាយដែលថាខ្ញុំនឹងអាននូវប្រតិចារឹករបស់លោក -- របស់សក្ខីកម្ម លោក គឹម វុន។ ប៉ុន្តែខ្ញុំគិតថា វាជាការចំណាយពេលវេលាច្រើន ហើយខ្ញុំគិតថាវាជាការមានប្រសិទ្ធភាពជាង ប្រសិនបើខ្ញុំធ្វើបែបនេះ។

**ប្រធានអង្គជំនុំ៖**

អញ្ជើញលោកធ្វើទៅ ការកត់សម្គាល់របស់លោកតំណាងសហព្រះរាជអាជ្ញាសមស្រប ពីព្រោះលោកផ្អែកទៅលើប្រតិចារឹកដកស្រង់នូវប្រតិចារឹកដែលជាខ្លឹមសារជាក់លាក់នុំង គួរតែត្រូវបានដកស្រង់ ហើយបង្ហាញនូវចំណុចជាក់ច្បាស់នៅក្នុងប្រតិចារឹកអំពីកាលបរិច្ឆេទទំព័រក៏ដូចជាទំព័រដែលពាក់ព័ន្ធ ដើម្បីភាគីផ្សេងទៀតបានតាមទាន់ ហើយនិងបានក្តាប់បាននូវបញ្ហានេះផងដែរ។

[១១:១៦:០០]

**លោក ហ្សាស្តេ ប៉ោ៖**

សូមអរគុណលោកប្រធាន។ ខ្ញុំនឹងបន្ត ដោយសារតែខ្ញុំបានសង្ខេបទៅលើចម្លើយរបស់លោក គឹម វុន។ ឥឡូវនេះ ខ្ញុំសូមអាននូវចម្លើយ ហើយសូមភាគីទាំងអស់តាមដានជាមួយខ្ញុំ ហើយខ្ញុំគិតថា ប្រហែលជាការលំបាកបន្តិច ប៉ុន្តែដើម្បីជាការកំណត់ត្រា ខ្ញុំសូមចាប់ផ្តើម។

**សួរដោយលោក ហ្សាស្តេ ប៉ោ៖**

**ស៖** ឯកសារដែលមានលេខ E1/113.1 ភាសាអង់គ្លេស ERN 00841885, ភាសាខ្មែរគឺ

មានលេខ 00838789 គឺប្រតិចារឹកចុះថ្ងៃ១០១ គឺថ្ងៃលេខ៣ ខែ៨ ឆ្នាំ២០១២ ហើយវាមាននៅទំព័រដែលគេចោទសួរចំពោះលោក គឹម វុន ទាក់ទងទៅនឹងក្រសួងពីរដែល យុន យ៉ាត គាត់គ្រប់គ្រង។ "តើលោក គឹម វុន ចាំដែរទេថាឆ្នាំណាដែល យុន យ៉ាត ចាប់ផ្តើមគ្រប់គ្រងក្រសួងទាំងពីរនេះ"។ ហើយលោក គឹម វុន បានឆ្លើយថា "ខ្ញុំមិនចាំទេ ប៉ុន្តែគាត់ប្រហែលជាគ្រប់គ្រងក្រសួងទាំងពីរនេះនៅក្នុងឆ្នាំ ៧៧ ឬ៧៨"។

តាមលោកដឹង លោក គឹម វុន "តើ យុន យ៉ាត នៅទទួលខុសត្រូវក្រសួងទាំងពីរនេះរហូតដល់ពេលដែលវៀតណាមចូលមកដល់នៅក្នុងខែមករា ឆ្នាំ៧៩ ដែរទេ?" ហើយលោក គឹម វុន បានឆ្លើយថា "បាទ គឺគាត់នៅបន្ត គឺគាត់នៅទទួលគ្រប់គ្រងរហូតដល់ពេលនោះ"។ នេះគឺជាការដកស្រង់ទី១ ដែលគាំទ្រទៅលើអ្វីដែលខ្ញុំបាននិយាយដែលថា តាមលោក គឹម វុន បញ្ជាក់គឺ យុន យ៉ាត គាត់នៅទទួលខុសត្រូវរហូតដល់ខែមករា ឆ្នាំ១៩៧៩?"។ នៅទំព័រ២៩ នៃឯកសារដដែលនេះ គឺភាសាអង់គ្លេសមានលេខ 00841881, ភាសាខ្មែរគឺមានលេខ 00838786 សំណួរគឺបានលើកឡើងទៅលើលោកសាក្សី ហើយគេសួរលោកដូចតទៅនេះ គឺនៅជួរទី១២ លោកនិយាយថា "លោកស្គាល់លោក នួន ជា ថាជាប្រធានសភាតំណាងប្រជាជន ប៉ុន្តែក្រៅពីមុខងារប្រធានសភាហ្នឹងលោកសាក្សីដឹងថា លោក នួន ជា មានមុខងារអ្វីផ្សេងទៀតទេ?" ហើយលោក គឹម វុន បានឆ្លើយថា "ដូចខ្ញុំនិយាយពាក់ព័ន្ធអ៊ីចឹង គឺថាពេលលោកស្រី យុន យ៉ាត អត់នៅអ៊ីចឹងទៅ គាត់មានភារកិច្ចទៅជាប់ខាងឃោសនាការ គឺផ្សាយនាទីអប់រំ។ គឺគាត់នៅធ្វើការផ្សព្វផ្សាយទាក់ទងទៅនឹងព័ត៌មានកសិកម្ម។ គឺគាត់ធ្វើការដកស្រង់ចេញពីឯកសារដែលអ្នកបច្ចេកទេសចិន។ ហើយគឺគាត់នៅធ្វើការនៅខាងឃោសនាការនោះ"។

[១១:១៩:០៧]

ហើយឯកសារដដែលនេះ គឺ 00841888 ភាសា-- នេះគឺជា ERN ភាសាអង់គ្លេស ហើយភាសាខ្មែរគឺមានលេខ 00838792 គឺគេចោទសួរសំណួរនៅជួរទី១៥ "ថាតើលោក គឹម វុន គាំទ្រទៅលើចម្លើយដែលលោកបាននិយាយដែរឬទេ? ដែលថាតួនាទីនៅខាងឃោសនាការៗនៅពេលនោះ ហើយលោក គឹម វុន បានឆ្លើយថា គឺថានៅពេលដែលលោកស្រី យុន យ៉ាត មានវត្តមានគឺគាត់មកទទួលខុសត្រូវតែខាងអប់រំ ឃោសនាការ អប់រំ គឺគាត់ទទួលខុសត្រូវលើផ្នែកនេះ"។ ហើយបន្ទាប់មកទៀតឯកសារដែលមានលេខ E1/112.1 ERN, ភាសាអង់គ្លេស គឺមាន 00841179, ខ្មែរមានលេខ ERN 00839886 គឺជាការនិយាយដដែលៗទៅលើអ្វីដែលខ្ញុំបានដកស្រង់ គឺមានពីរទំព័របន្ថែមទៀត គឺ

ឯកសារ E1/112.1, ភាសាអង់គ្លេសមាន ERN 00841211 និងភាសាខ្មែរគឺមានលេខ 00839911។ ហើយទាំងអស់នេះ គឺជាសំណួរដែលលើកឡើងដោយចៅក្រម ឡាវែន៍ ហើយសំណួរគឺនៅជួរទី១៨។ ថាតើលោកអាចប្រាប់បន្ថែមទេ ថា "តើ នួន ជា ធ្វើអ្វីនៅក្រសួងឃោសនាការ និងអប់រំ" ហើយចម្លើយគឺថា "នួន ជា គឺមានតួនាទីនៅក្នុងកម្មវិធីអប់រំ គឺកម្មវិធីអប់រំ ដែលនិយាយអំពីកសិកម្ម។ គឺគាត់យកសៀវភៅក្រាសមួយពីអ្នកជំនាញចិន ហើយគាត់ដកស្រង់ពីសៀវភៅហ្នឹង ដើម្បីធ្វើការអប់រំអំពីកសិកម្ម។ អានេះគឺជាអ្វីដែលខ្ញុំដឹងនៅជំនាន់នោះ"។

[១១:២១:៣៤]

ហើយបន្តមកទៀត គឺនៅទំព័រមួយទៀត គឺមានលេខ 00841212 ហើយភាសាខ្មែរគឺមានលេខ 00839911 ដល់ 12។ ហើយវាជាសំណួរដដែលដែលសួរឡើងដោយលោកចៅក្រម ឡាវែន៍ គឺជួរទី៨ "តើលោក នួន ជា មកជំនួសលោកស្រី យុន យ៉ាត ឬក៏មកជួយ?" ហើយលោក គឹម វុន បានបញ្ជាក់ថា "កម្មវិធីជាមូលដ្ឋានរបស់គាត់ ដូចខ្ញុំលើកឡើងពីខាងដើម គឺមានកម្មវិធីអប់រំអំពីកសិកម្ម មិនមានទាក់ទងនឹងផ្នែកផ្សេងឡើយ។ ហើយ ប៉ុន្តែខ្ញុំមិនដឹងច្បាស់ទេ ព្រោះក្រោយមកខ្ញុំត្រូវបានគេដកមកខាងវិទ្យុកម្ពុជាក្រោមវិញ។ ក្នុងរយៈពេលហ្នឹង លោក នួន ជា ទៅធ្វើការនៅឃោសនាការ ហើយវត្តមានរបស់គាត់នៅពេលនោះ គឺច្រើនតែលោកស្រី យុន យ៉ាត អត់នៅ"។ នេះ គឺជាប្រតិចារឹកនៃសក្ខីកម្មរបស់លោក គឹម វុន។ ហើយសំណួរដែលខ្ញុំចង់សួរលោក គឺថា ក្នុងថ្ងៃនេះតើលោកដឹងដែរឬទេ ថាតើចម្លើយរបស់លោក គឹម វុន ហ្នឹងវាត្រឹមត្រូវ ដែលលោក គឹម វុន បានបញ្ជាក់ថា លោក នួន ជា ផ្តោតសំខាន់តែទៅលើកម្មវិធីអប់រំកសិកម្ម ដែលផ្តល់នៅក្រសួងឃោសនាការនោះ។ តើលោកដឹងអំពីព័ត៌មានទាក់ទងទៅនឹងបញ្ហានេះទេ?

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប! សូមអញ្ជើញតំណាងសហព្រះរាជអាជ្ញា!

[១១:២៣:២៣]

**លោក ឌេល លីសាក់៖**

លោកប្រធាន យើងមិនមានការជំទាស់ទៅលើការកែសម្រួលសំណួររបស់មេធាវីការពារក្តី ដែលថាសួរថាដឹងអំពីតួនាទីរបស់ នួន ជា ឬក៏អំពីការអប់រំនោះទេ។ ប៉ុន្តែគាត់នៅតែបញ្ជាក់មិនច្បាស់លាស់អំពីសក្ខីកម្មដែលនិយាយអំពីតួនាទីរបស់ នួន ជា នៅពេលដែលសាក្សីបានបញ្ជាក់ច្បាស់ថា គាត់មិនដឹង

អំពីសកម្មភាពផ្សេងៗរបស់ នួន ជា នៅក្រសួងនោះឡើយ។ ព្រោះក្រោយមក គាត់ត្រូវបានគេផ្ទេរទៅវិទ្យុកម្ពុជាក្រោម។ ខ្ញុំមិនជំទាស់ដែលថា គាត់សួរសំណួរបែបនេះទៅលើសាក្សីអំពីបញ្ហានោះឡើយ ប៉ុន្តែគាត់នៅតែបញ្ជាក់ដោយខុសទៅលើសក្ខីកម្មរបស់សាក្សីមុន។

**សួរដោយលោក ហ្សាស្តេី ប៉ោ៖**

លោកប្រធាន ដូច្នេះបញ្ហា -- ដោះស្រាយបញ្ហាបានគឺខ្ញុំចង់ធ្វើការដោះស្រាយនូវ -- ដកស្រង់នូវប្រតិចារឹក។ ហើយខ្ញុំសូមធ្វើការដកស្រង់ប្រតិចារឹករបស់លោក គឹម វុន នៅទំព័រ២៩ ភាសាអង់គ្លេសមានលេខ 00841881 និងភាសាខ្មែរគឺមានលេខ 00838786។ ហើយខ្ញុំសូមដកស្រង់។

**ស៖** លោក គឹម វុន -- លោកសាក្សី ក្នុងពេលឥឡូវនេះ ខ្ញុំធ្វើការដកស្រង់ផ្ទាល់ពីចម្លើយរបស់លោកសាក្សី គឹម វុន៖ "ខ្ញុំនិយាយថានៅពេលដែលលោកស្រី យុន យ៉ាត អវត្តមាន គឺលោកនួន ជា មកធ្វើការផ្នែកឃោសនាការអប់រំ គឺគាត់មកទីនេះដើម្បីផ្សព្វផ្សាយព័ត៌មានពាក់ព័ន្ធទៅនឹងផ្នែកកសិកម្ម គឺព័ត៌មានដែលគាត់ដកស្រង់ពីសៀវភៅមួយដ៏ក្រាស់របស់អ្នកជំនាញចិន។ ហើយគាត់ក៏ធ្វើការផ្សព្វផ្សាយនៅខាង ផ្សព្វផ្សាយនៅក្រសួងឃោសនាការផងដែរ។ ដូច្នេះ សំណួររបស់ខ្ញុំដែលចង់សួរលោកគឺថា តើលោកសាក្សី លោក គឹម វុន គាត់ដំបូងគាត់នៅក្រសួងឃោសនាការ ហើយសក្ខីកម្មរបស់លោក គឹម វុន បានបញ្ជាក់ថា "នៅពេលដែលលោកស្រី យុន យ៉ាត អវត្តមាន លោកនួន ជា បានមកកាន់ខាងឃោសនាការ ដែលទាក់ទងកម្មវិធីអប់រំ ដែលធ្វើការផ្សព្វផ្សាយព័ត៌មានអំពីការអប់រំកសិកម្ម"។ តើលោកអាចបញ្ជាក់បានដែរឬទេ ថាតើវាជាការត្រឹមត្រូវ ឬក៏ជាការខុស ដែលលោក គឹម វុន បានផ្តល់ចម្លើយបែបនេះ ដោយផ្អែកទៅលើការយល់ដឹង ដោយផ្អែកទៅលើបទពិសោធន៍របស់លោកដោយមាន។ តើចម្លើយរបស់លោក គឹម វុន ហ្នឹង ត្រឹមត្រូវ ឬមួយក៏ខុស?

[១១:២៦:០៩]

**លោក ខៀវ អេន៖**

**ឆ៖** ខ្ញុំសូមឆ្លើយសំណួរនេះ។ លោកឈ្មោះហ្នឹង ខ្ញុំទទួលស្គាល់ថា ឈ្មោះមុត ខ្ញុំអត់ដឹង។ តែគ្រាន់តែថា គាត់ផ្តល់ជាចម្លើយហ្នឹង ខ្ញុំដូចមិនៗវិនិច្ឆ័យកើតថា គាត់ឲ្យហ្នឹងខុស ឬត្រូវ ខ្ញុំអត់វិនិច្ឆ័យកើតទេ។ បានតែខ្ញុំលើកពាក្យនេះ ដោយសារអី? ដោយសារថា នេះជាជំនាញដោយឡែកពីគ្នា។ ដល់អ៊ីចឹង ជំនាញគេ គេដឹងរឿងគេ។ ខាងលើណែនាំគេយ៉ាងម៉េច អាហ្នឹងរឿងគេ។ ឯដល់ខ្ញុំ ខ្ញុំដឹងតែរឿងខ្ញុំ។ ដល់អ៊ីចឹង គឹម វុន ដែលផ្តល់ចម្លើយហ្នឹង គឺរឿងគាត់ៗ វាអត់ទាក់ទងនឹងរឿងខ្ញុំ។ ហើយខ្ញុំក៏អត់ដឹង

រឿងគាត់យ៉ាងម៉េចៗ ព្រោះៗខាងលើមកគេ គាត់ធ្វើការជាមួយខាងណោះទៅ ឯខ្ញុំរឿងការងាររបស់ខ្ញុំនេះ គឺថា ខ្ញុំគ្រាន់តែបញ្ជាក់ថា ខាងលើអត់ៗសួរជាប់ទេ អត់សួរជាប់លាប់អីទេ។ បើនៅខាងគាត់ហ្នឹងប្រហែល -- ដែលតាមខ្ញុំដឹងគឺថា មកជាប់លាប់នឹងការងារខាងនោះច្រើនជាង។ នេះគ្រាន់តែដឹង។ ហើយដល់អ៊ីចឹង អាចម្លើយរបស់គាត់ដែលផ្តល់មកនេះ ខ្ញុំអត់ៗបដិសេធថា អ្ហែ! ចម្លើយនេះជាត្រឹមត្រូវ អ្ហែ មិនត្រឹមត្រូវ អត់ទេ។ ព្រោះៗជំនាញដោយឡែកពីគ្នា គាត់ផ្តល់ៗគាត់តាមជំនាញរបស់គាត់។ ឯខ្ញុំ ខ្ញុំផ្តល់តាមជំនាញរបស់ខ្ញុំ និងការងាររបស់ខ្ញុំ ដល់អ៊ីចឹងឲ្យខ្ញុំថា ឆ្លើយថា អ្ហែ! អាហ្នឹងដូចមិនអ៊ីចឹងអ៊ីចេះអ៊ីចុះ អត់ទេ។ អាហ្នឹងខ្ញុំឆ្លើយអត់បាន។ សូមអស់មតិបាទ។

**ស៖** សូមអរគុណលោកសាក្សីចំពោះចម្លើយរបស់លោក។

**ប្រធានអង្គជំនុំ៖**

លោកមេធាវីអាចបញ្ជាក់ប្រាប់យើងបានទេ ថាតើលោកត្រូវការពេលវេលាប៉ុន្មានទៀត? ហ្នឹងបញ្ហាទី១។ ទី២ តើលោកបានពិភាក្សាជាមួយនឹងក្រុមមេធាវីក្រុមទៀតដែរឬទេ? ព្រោះពេលវេលាសម្រាប់ក្រុមមេធាវីទាំងបីក្រុមគឺមានរយៈពេល១ថ្ងៃ។ ហើយដំណើរការនៃការស្តាប់សក្ខីកម្មសាក្សីនេះដែលធ្វើឡើងដោយក្រុមមេធាវីហ្នឹង គឺចាប់ផ្តើមតាំងពីម្សិលមិញ រសៀលម្សិលមិញ គឺចំណាយពេលវេលាប្រហែលជា ២០នាទីចុងក្រោយ។ សូមលោកបញ្ជាក់ ចៀសវាងមានការមិនច្បាស់លាស់លើការបែងចែកពេលវេលា ហើយអាចអូសបន្លាយពេលវេលាចំពោះក្រុមផ្សេងទៀត។

[១១:២៨:៣៩]

**លោក ហ្សាស្តេី ប៉ោ៖**

សូមអរគុណដែលលោកប្រធានបានរំឭកខ្ញុំ។ ខ្ញុំបានពិភាក្សាជាមួយក្រុមដទៃទៀត មុនពេលដែលខ្ញុំសួរ ហើយតាមដែលខ្ញុំដឹង គឺថាខាងមេធាវី ខៀវ សំផន មានសំណួរតិចតួចទេ។ ហើយខាងក្រុមលោក អៀង សារី ក៏មិនមានសំណួរច្រើនដែរ។ ដូច្នេះ ហើយខ្ញុំគិតថា ក្រុមយើងគឺអាចបញ្ចប់នៅ -- ទៅលើពេលវេលាដែលបានបែងចែក១ថ្ងៃនោះ គឺចប់តាមពេលវេលាកំណត់។

**សួរដោយលោក ហ្សាស្តេី ប៉ោ៖**

**ស៖** ដូច្នេះលោក ខៀវ អេន ខ្ញុំមិនសួរលោកឲ្យធ្វើការវាយតម្លៃទៅលើសក្ខីកម្មរបស់លោក គឹម វុន។ ការពិតនេះមិនមែនជាគោលដៅរបស់ខ្ញុំទេ។ ខ្ញុំគ្រាន់តែចង់ស្នើសុំឲ្យលោកនិយាយអំពីតួនាទីរបស់លោក នួន ជា។ ហើយសំណួររបស់ខ្ញុំគឺដូចតទៅនេះ៖ ផ្អែកទៅតាមបទពិសោធន៍របស់លោក តើលោក

ដឹងដែរឬទេ ថាតើការងារសំខាន់របស់លោក នួន ជា ហ្នឹងគឺជាអ្វីនៅក្រសួងឃោសនាការ?

**លោក ខៀវ សំផន៖**

**ផ៖** សំណួរនេះខ្ញុំអត់ដឹងទេ។ បានថា ខ្ញុំអត់ដឹងគាត់មក គាត់ដូចមតិឈ្មោះ ឆោម ដែលខ្ញុំថាហ្នឹង ខ្ញុំចាំតែឈ្មោះ ឆោមៗ ឈ្មោះផ្សេងខ្ញុំអត់ដឹង។ ដែលឲ្យមកថា គាត់ជួបជាមួយខាង នួន ជា អាហ្នឹងខាង នួន ជា និយាយម៉េចៗជាមួយគាត់អាហ្នឹងរឿងគាត់។ ដល់អ៊ីចឹងថា នួន ជា ត្រូវមកទទួលអីហ្នឹង អាហ្នឹងរឿងគាត់ តែដល់មកខ្ញុំនេះ ខ្ញុំអត់ដែលទទួលដឹងទេ។ អ៊ីចឹងបានថា សម្រាប់ខាងខ្ញុំ ខ្ញុំអត់ដឹងទេ។ តែគ្រាន់តែការងារសកម្មភាពអីឃើញអ៊ីចឹង ឃើញដូចខ្ញុំបញ្ជាក់ពីដើមមក តែដល់ខាង ឆោម គាត់ជាប់ជាមួយខាង នួន ជា សរសេរឯណាដែលគាត់ផ្តល់ជាសក្ខីកម្មមកខ្ញុំអត់ ជាៗជូនសាច់រឿងហ្នឹងមកសម្រាប់សវនាការហ្នឹង អាហ្នឹងរឿងគាត់។ បាទ គាត់បានប្រឡូកជាមួយ នួន ជា អីយ៉ាងម៉េច គាត់ជួបយ៉ាងម៉េចអីយ៉ាងម៉េច អាហ្នឹងរឿងគាត់។ ដល់ខ្ញុំអត់ អត់ដឹងទេ។ អ៊ីចឹងបានថា ការដែលគ្រប់គ្រងអីយ៉ាងម៉េចខ្ញុំអត់ដឹងទេ បើ ឆោម គាត់ទទួលពី នួន ជា មកថាគាត់មកប្រកាសអ៊ីចេះអ៊ីចុះ អាហ្នឹងរឿងឆោម។ អានេះខ្ញុំសូមបញ្ជាក់អ៊ីចឹងបាទ។

[១១:៣១:៣២]

**ស៖** ខ្ញុំយល់។ លោកទើបតែបានឆ្លើយថា មេខាងលើនោះជារឿយៗគឺមកផ្នែកដែលលោក គឹម វុន ធ្វើការងារ តើលោកអាចពន្យល់បានដែរឬទេ ហេតុអ្វីបានជាថ្នាក់លើនោះជារឿយៗបានមកមើលផ្នែកដែលលោក គឹម វុន ធ្វើការងារនោះ?

**ផ៖** ខ្ញុំសូមឆ្លើយថា កន្លែងហ្នឹងគឺជាការកន្លែងដែលគេច្រើនសរសេរ។ គ្រាន់តែដឹងថា ជាអ្នកសរសេរទេកន្លែងហ្នឹងនោះ។ តែគេសរសេរអីមិនដឹងទេ ព័ត៌មានអីណាៗ ព្រោះកន្លែងហ្នឹងជាកន្លែងដែលសម្រាប់យកទៅផ្សាយវិទ្យុ។ បាទ យកផ្សាយ ហើយដល់ខ្ញុំនេះវាអ្នកដែលគេយកមកឲ្យហើយ ខ្ញុំធ្វើសម្រាប់ការងារខ្ញុំ។ ដល់អ៊ីចឹងខាងលើដែលទៅជួបកន្លែងហ្នឹង ដែលទៅធ្វើការដែលត្រូវជាប់លាប់ខុសពីកន្លែងខ្ញុំហ្នឹង។ ខ្ញុំគ្រាន់តែដឹងថា កន្លែងហ្នឹងជាកន្លែងអ្នកសរសេរបាទ។ នេះសូមមានមតិប៉ុណ្ណឹង។

[១១:៣៣:១១]

**ស៖** ខ្ញុំសូមសួរសំណួរឡើងវិញ ហើយខ្ញុំសូមដកស្រង់សម្តីជាក់លាក់តែម្តងរបស់លោក គឹម វុន ត្រង់ ERN លេខ 00841885, ខ្មែរគឺ 00838789។ ឯកសារ E1/113.1 ប្រតិចារឹកថ្ងៃ១០១ សំណួរគឺសួរអំពីក្រសួង ខ្ញុំសូមដកស្រង់សម្តី "តើលោក គឹម វុន ចាំទេ ឆ្នាំណាដែល យុន យ៉ាត មកកាន់

ក្រសួងនោះ?" លោក គឹម វុន បានឆ្លើយថា "ខ្ញុំមិនចាំច្បាស់នោះទេ ក៏ប៉ុន្តែគាត់ប្រហែលជាមកក្តោបក្តាប់ក្រសួងនេះចន្លោះឆ្នាំ៧៧ ទៅ ៧៨"។ សំណួរសួរទៀតថា "តើលោកដឹងទេ យុន យ៉ាត នៅក្តោបក្តាប់ក្រសួងទាំងពីនេះរហូតវៀតណាមចូលមកដល់នៅក្នុងខែមករា ឆ្នាំ១៩៧៩ ឬក៏យ៉ាងម៉េច?" លោក គឹម វុន បានឆ្លើយថា "បាទ គាត់គ្រប់គ្រងទាំងពីរ។ គាត់នៅតែគ្រប់គ្រងក្រសួងទាំងពីរនោះរហូតដល់ពេលនុ៎ង"។ បញ្ចប់ការដកស្រង់សម្តី។

[១១:៣៤:៣៨]

លោក ខៀវ អេន ដោយយើងពិចារណាស្តាប់ឮចម្លើយដែលបានឆ្លើយដោយលោក គឹម វុន នេះ និងផ្អែកតាមបទពិសោធន៍ដែលលោកបានឆ្លងកាត់ធ្វើការងារនៅក្រសួងឃោសនាការ តើលោកគិតថា យុន យ៉ាត នោះមានលទ្ធភាពនោះគ្រប់គ្រងក្រសួងទាំងពីររហូតទៅដល់វៀតណាមចូលមក ឬក៏យ៉ាងម៉េច? ឬក៏គាត់ យុន យ៉ាត ហ្នឹង គាត់កាន់កាប់ក្រសួងឃោសនាការរហូតដល់ខែមករា ឆ្នាំ១៩៧៩ ដែរឬទេ? ហើយថាតើគាត់នោះ យុន យ៉ាត នោះគាត់អាចបែងចែកម៉ោងរបស់គាត់ ពេលរបស់គាត់ រវាងក្រសួងទាំងពីរ ហើយពេលខ្លះនោះ គាត់មិនអាចមកត្រួតពិនិត្យញឹកញាប់នៅក្រសួងឃោសនាការទេ ដោយសារតែគាត់បែងចែងពេលវេលាគ្រប់គ្រងក្រសួងទាំងពីរ។ តើអ៊ីចឹងដែរឬទេ?

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប!

សូមអញ្ជើញតំណាងសហព្រះរាជអាជ្ញា!

[១១:៣៥:៥២]

**លោក ឌេល លីសាក់៖**

សូមអរគុណលោកប្រធាន។ ខ្ញុំជំទាស់ទៅនឹងការសំណួរ សួរសំណួរបែបនេះ។ ពេលនេះមេធាវីសួរឲ្យសាក្សីទាយស្មាន ដែលឲ្យសាក្សីស្មានថាតើ យុន យ៉ាត ធ្វើការងារអ្វី។ សាក្សីបានបញ្ជាក់រួចមកហើយអង្គជំនុំជម្រះក៏បានបង្គាប់ដែរ ដែលថាសាក្សីមិនត្រូវសួរសំណួរឲ្យគាត់ស្មាននោះឡើយ។

**លោក ហ្សាស្តើ ប៉ៅ៖**

ខ្ញុំរីករាយ ខ្ញុំអាចរៀបចំសំណួរឡើងវិញបានលោកប្រធាន។

**សួរដោយលោក ហ្សាស្តើ ប៉ៅ៖**

**ស៖** តើលោកញឹកញាប់ប៉ុន្មានប៉ុនណាដែរ? ខ្ញុំសូមរៀបចំសំណួរខ្ញុំឡើងវិញ។ ក្រសួងទាំងពីរ

ដែល យុន យ៉ាត កាន់កាប់ក្នុងរយៈកាលមួយចំនួននោះ តើក្រសួងទាំងពីរនេះស្ថិតនៅទីតាំងខុសគ្នាក្នុងទីក្រុងភ្នំពេញដែរឬទេ?

**លោក ខៀវ អេនះ**

**ឆ៖** ខ្ញុំសូមឆ្លើយសំណួរនេះបាទ។ ក្រសួងទាំងពីរនេះ គឺនៅដាច់ដោយឡែកពីគ្នាទេ។ គឺដែលធ្លាប់ពី ហ៊ូ នឹម នៅកន្លែងណា ដល់ពេល យុន យ៉ាត មកគឺនៅកន្លែងហ្នឹងដដែល។ សូមមានមតិប៉ុណ្ណឹងបាទ។

[១១:៣៧:៥៦]

**សៈ** ដើម្បីឱ្យយើងយល់ច្បាស់ទាំងអស់គ្នា ដោយសារតែឈ្មោះពីរខុសគ្នា ដាក់ប្រើប្រាស់ចំពោះក្រសួងទាំងពីរនោះ។ តើឈ្មោះរបស់ក្រសួងទាំងពីរនោះ ដែលខុសគ្នានោះ គឺមានឈ្មោះជាក់លាក់អ្វីដែរនៅពេលដែលគេហៅក្រសួងទាំងពីរនោះ?

**ឆ៖** ខ្ញុំសូមឆ្លើយដែរ។ ក្រសួងទាំងពីរនេះ ខ្ញុំមិនប្រាកដថា១០០ភាគរយទេ ឱ្យឈ្មោះហ្នឹងថាត្រឹមត្រូវប្រាកដអ៊ីចឹងទេ តែគ្រាន់ថា ចាំថាកាលដែលនៅដាច់ដោយឡែក មិនបញ្ចូលដាក់ថា "ក្រសួងឃោសនាការ និងព័ត៌មាន"។ ហើយដល់ម្ខាងទៀតនោះ ដឹងថាក្រសួងសិក្សាអប់រំ។ តែអាហ្នឹងមិនដឹងជាត្រូវ១០០ភាគរយហ្នឹង ខ្ញុំមិនប៉ាននធានា តែពាក្យហ្នឹងអាចមិនឆ្ងាយទេ ក្នុងន័យហ្នឹងបាទ មិនឆ្ងាយពីៗខ្ញុំជូនព័ត៌មានទេ ន័យហ្នឹង។ ក្រែងលោខ្ញុំភ្លេចទៅ មិនទាន់អស់អី តែដល់ដាក់បញ្ចូលទាំងពីរមក គ្រាន់តែបន្ថែមថា "ក្រសួងឃោសនាព័ត៌មាន និងសិក្សាអប់រំ" បន្ថែមប៉ុណ្ណឹងបញ្ចូលប្រឡោះប៉ុណ្ណឹងទៀតទេ។ ដល់អ៊ីចឹងទៅជាក្រសួងមួយហ្នឹង អ៎!ក្រសួងពីរហ្នឹងច្របាច់បញ្ចូលគ្នាទៅ។ នេះមានមតិប៉ុណ្ណឹងទេបាទ។

[១១:៣៩:៤៧]

**សៈ** លោកបាននិយាយថា ក្រសួងទាំងពីរនេះត្រូវបានច្របាច់ចូលគ្នាក្នុងពេលណាមួយ ក្នុងរបបនោះ។ តាមដែលលោកដឹង តើក្រោយពីច្របាច់ចូលហើយនោះ ក្រោយមកនោះ មានការបំបែកគ្នាចេញជាពីរ ក្រសួងពីរវិញទេ?

**ឆ៖** ពេលវេលាបំបែកក៏ខ្ញុំអត់ដឹង ខ្ញុំសូមឆ្លើយ ពេលវេលាបំបែកក៏ខ្ញុំអត់ដឹង ហើយឈ្មោះមកបែងចែកយ៉ាងម៉េចទៀត គឺអត់ដឹងដែរ តែគ្រាន់តែឃើញ យុន យ៉ាត ផ្អាកទៅ ឃើញ នួន ជា មកទទួល។

**សៈ** តើលោកដឹងដែរឬទេ ថាតើ យុន យ៉ាត ធ្វើការងារអ្វីដែរ ក្រោយពេលដែល យុន យ៉ាត ចេញពីក្រសួងឃោសនាការ?

E1/128.1

[១១:៤១:០៣]

**ឆ៖** ហើយនេះ ក៏ខ្ញុំសូមឆ្លើយថា កាលដែលគាត់ទៅទទួលកន្លែងខ្ញុំ ខ្ញុំក៏មិនសូវដឹង ដល់គាត់ឈប់ទទួល ខ្ញុំកាន់តែលែងដឹងនេះ។ នេះសូមអស់មតិប៉ុណ្ណឹងបាទ។ រឿង យុន យ៉ាត ហ្នឹង ខ្ញុំសូមបញ្ជាក់ថា កាលដែលគាត់ទៅទទួលហ្នឹង ដូចខ្ញុំបញ្ជាក់ពីមុនមកហើយថា ការងារបច្ចេកទេសខ្ញុំហ្នឹងដឹងតែពីបច្ចេកទេសខ្ញុំចេះតែធ្វើទៅ។ ដល់អ៊ីចឹង គាត់ហ្នឹងក៏មិនជិតដល់ ហើយខ្ញុំក៏មិនសូវដឹងពីរឿងថាការងារគាត់ទៅធ្វើអ្វីៗដែរ។ ដល់អ៊ីចឹង ក្រសួងអ្នកចែកដែលគាត់ដកទៅវិញ ឈប់មកវិញនេះ ក៏ខ្ញុំកាន់តែលែងមានការពាក់ព័ន្ធជាមួយគាត់ទៀតហើយ អត់ដឹងរឿងអីទាំងអស់។ សូមអស់មតិហើយបាទ។

**ស៖** តាមលោកដឹង តើលោកដឹងនៅពេលដែលគេដកគាត់នោះ គឺលោកស្រី យុន យ៉ាត នោះទៅធ្វើការនៅឯណាវិញ?

**ឆ៖** ខ្ញុំដឹងតែថា គាត់ផ្អាកមកធ្វើការងារនៅកន្លែងនុ៎ង តែដល់ការងារកន្លែងគាត់ គាត់នៅធ្វើយ៉ាងម៉េចៗទៀត ខ្ញុំអត់ដឹងទេ។ គាត់នៅគ្រប់គ្រងហ្នឹងទៀត ក៏ខ្ញុំអត់ដឹង ឬមួយក៏ថាគេមិនឲ្យគ្រប់គ្រងក៏ខ្ញុំអត់ដឹង តែដឹងថាគាត់ផ្អាកមកហើយ គាត់ឈប់មកកន្លែងខ្ញុំ ឃើញខាងលោក នួន ជា គាត់មកទទួលដល់គាត់ឈប់គ្រប់គ្រងហ្នឹងទៅ ដល់គាត់ទៅការងារដែលកន្លែងចាស់របស់គាត់ រឿងធ្វើអី មិនធ្វើអីត្រូវទទួលវិញ ឬអត់ទទួល ខ្ញុំអត់ដឹងទេ ដឹងរឿង ការងាររបស់គាត់ទេ។ សូមមានមតិបាទ ចប់។

**ស៖** ខ្ញុំសូមសួរត្រឡប់ទៅសំណួរដើមរបស់ខ្ញុំវិញ។ សំណួរនោះ គឺថាតើលោកដឹងទេ ក្រសួងទាំងពីរនេះ ទីតាំងផ្ទាល់របស់ក្រសួងទាំងពីរ នៅក្នុងក្រុងភ្នំពេញហ្នឹង គឺនៅម្តុំណាដែរ គឺទីតាំងជាក់ស្តែង?

[១១:៤៣:៥៤]

**ឆ៖** ខ្ញុំសូមឆ្លើយ ទីតាំងក្រសួងដែលខ្ញុំនៅ ហៅថា ក-៣៣ ហ្នឹង មកឥឡូវវាៗបាត់ហើយ តែអង្គាល់ហ្នឹង នៅខាងត្បូងលីសេដេកាត កាលហ្នឹងហៅ លីសេដេកាត នៅខាងត្បូងនោះ សាលាមួយជួរពីអគារពីមួយជួរដែលស្នួន ខាងជើងស្នួនសច្ចមុនីចេតិយទៅកើតហ្នឹង នៅខាងជើងហ្នឹង។ បើតាមមើលឥឡូវដូចវាមានអី ឃើញ ខ្ញុំគ្រាន់តែឃើញ ដែលខ្ញុំចូលមកហ្នឹងឃើញថាធ្លាប់រស់នៅកន្លែងហ្នឹង ឃើញមានខ្សែទូរស័ព្ទ ខ្សែអីមិនដឹងទេ នៅលើដំបូលហ្នឹង អាហ្នឹងខ្ញុំមិនដឹង អារឿងក្រោយទេ។ តែគ្រាន់ថាកន្លែងចាស់របស់ខ្លួន បើអើតទៅឃើញ កាត់តាមហ្នឹង។ ហើយក្រសួងអប់រំ ខាង យុន យ៉ាត នោះខ្ញុំកន្លងមករកៗទីតាំងគេឲ្យច្បាស់លាស់ អត់ៗនេះទេ បានតែថាអ៊ីចឹង ខ្ញុំគ្រាន់តែថា ចំណុចកាលហ្នឹង

នៅពីខាងត្បូងបុរីកីឡា តែមិនដឹងត្រង់ណាឲ្យច្បាស់ ព្រោះអត់ដែលចេញចូល អត់សូវដើរ។ ដូចខ្ញុំថា ខ្ញុំអត់អ្នកដើរ ខ្ញុំនៅតែកន្លែងបាទ។ នេះសូមមានមតិប៉ុណ្ណឹងបាទ។ ជូនមតិប៉ុណ្ណឹងបាទ។

**ស៖** ខ្ញុំប្រហែលជាយល់មិនច្បាស់ទៅលើចំណុចនេះ ក៏ប៉ុន្តែខ្ញុំសូមឲ្យលោកបញ្ជាក់បំភ្លឺឲ្យបានច្បាស់លាស់។ តើក្រសួងឃោសនាការនៅជិតលីសេដេកាត ឬក៏ក្រសួងឃោសនាការនៅជិតបុរីកីឡា សូមឲ្យលោកជួយបញ្ជាក់ ខ្ញុំយល់អត់ច្បាស់?

**ឆ៖** ខ្ញុំសូមបញ្ជាក់ថា ក្រសួងឃោសនាការហ្នឹងនៅខាងត្បូងលីសេដេកាត ហើយក្រសួងខាងសិក្សាអប់រំហ្នឹង ទីតាំងខ្ញុំមិនដឹងថាអគារមួយណាឲ្យច្បាស់ទេ តែគ្រាន់តែដឹងថានៅពីត្បូងបុរីកីឡា។ ព្រោះដល់ពេលច្របាច់បញ្ចូលធ្លាប់ដឹង ដែលគេថា គាត់មកគ្រប់គ្រងក្រសួងពីរធ្លាប់ដឹងទេ។ គេទើបមកពីខាងណោះ មកខាងណេះ អីខាងណោះគេទៅខ្លះទៅ គេសួរ -- ដល់អ៊ីចឹងយើងអ្នកដើរ យើងចេះតែសួរគេនៅត្រង់ណា? ហើយអ៊ីចឹងគេប្រាប់ទៅ ជាៗព័ត៌មានដែលបានដឹង បានឮពីគេ។ ហើយចំណុចទីតាំងថា អគារណាមួយ អត់ ខ្ញុំអត់ដែរដឹងច្បាស់ទេ អត់ដែលឃើញ។ បាទ សូមៗមានមតិប៉ុណ្ណឹង។ បាទ អស់មតិ។

[១១:៤៧:០៥]

**ស៖** ខ្ញុំយល់ច្បាស់ហើយ។ លោក គឹម វុន បានរៀបរាប់ ពិពណ៌នាតាមការងារដែលគាត់ចាំនោះ គឺគាត់បានរៀបរាប់ពិពណ៌នាថា “នួន ជា មកក្រសួងនេះនៅពេលដែល យុន យ៉ាត អវត្តមាន ហើយនិងជំនួសការងាររបស់ យុន យ៉ាត”។ ក៏ប៉ុន្តែលោក គឹម វុន ក៏បានលើកឡើងផងដែរថា “កាលដែលគាត់មកជំនួសនោះ គឺនៅក្នុងចន្លោះពេលមួយចំនួនតែប៉ុណ្ណោះ”។ លោក គឹម វុន បានឆ្លើយថា “លោកស្រី យុន យ៉ាត នោះទៅមក១នៅក្រសួងនុ៎ង ហើយភាគច្រើនទៅគឺ នួន ជា នោះមកជំនួស យុន យ៉ាត នៅពេលដែល យុន យ៉ាត អវត្តមានតែប៉ុណ្ណោះ”។ តើលោកខ្លួនឯងនេះបានឃើញផ្ទាល់ភ្នែកនឹងហេតុការណ៍នេះដែរឬទេ?

**ឆ៖** ខ្ញុំសូមឆ្លើយ។ នេះជាចម្លើយរបស់លោក គឹម វុន។ ឯខ្ញុំ១បញ្ជាក់ពីចម្លើយរបស់ខ្ញុំថា ខាងលោក គឹម វុន ហ្នឹងឃើញ អាហ្នឹងគាត់ដឹងរឿងទាក់ទងនឹងការងាររបស់គាត់ ប៉ុន្តែដល់ខ្ញុំវាការងារអត់សូវជាប់ជំពាក់វាក់វិននឹងការងាររបស់គាត់ ខ្ញុំអត់សូវដឹងថា អូ! គាត់ទៅមក១យ៉ាងម៉េច១ ខ្ញុំអត់សូវដឹងទេ។ ដល់អ៊ីចឹងកន្លែងខ្លះគាត់មក ក៏ខ្ញុំអត់ដឹង បើខ្ញុំនៅកន្លែងខ្ញុំធ្វើការ។ គាត់ទៅវិញក៏អត់ដឹង តែដល់កន្លែងគាត់ គាត់មានទំនាក់ទំនងច្រើនជាងខ្ញុំ ប្រហែលជាគាត់ដឹងរឿងច្រើន សកម្មភាពហ្នឹងច្រើនជាង

ខ្ញុំ។ ដល់អ៊ីចឹង គាត់ថាយ៉ាងហ្នឹងក៏ខ្ញុំថាគាត់ឲ្យមកយ៉ាងម៉េចៗ ខ្ញុំថាអត់កើត ព្រោះវាៗរឿងដោយឡែកពីគ្នា។ បាទ សូមជូនមតិប៉ុណ្ណឹងបាទ។

[១១:៤៩:២៧]

**ស៖** កន្លែងដែលលោកធ្វើការងារនុំង តើលោកអាចពិពណ៌នាឲ្យយើងខ្ញុំបានស្តាប់បន្ថែមទៀតដែរឬទេនៅកន្លែងរបស់លោកនោះគឺមានអគារ ហើយមានបន្ទប់នៅក្នុងអគារហ្នឹង នានាដែរឬទេ? ឬក៏វាជាផ្ទះមួយដោយឡែកតែប៉ុណ្ណោះ?

**ឆ៖** ខ្ញុំសូមឆ្លើយ។ ការពិតកន្លែងដែលខ្ញុំធ្វើវាគ្រាន់ថា ប្រមូលផ្តុំនៅៗកន្លែងមួយដែលគេហៅថាអគារគេតចែកគ្នាដាច់ៗដោយឡែក ហើយកន្លែងរួមធំហ្នឹងគេធ្វើជាអគារមួយធំហ្នឹង តែអែបបន្ទប់តូចៗទៀតនោះ ក៏ដោយឡែកទៅទៀត។ ដល់អ៊ីចឹងខ្ញុំក៏ធ្វើទៅតាមកន្លែងបន្ទប់របស់ខ្ញុំ កន្លែងការងាររបស់ខ្ញុំដែលដាក់សម្ភារៈរបស់ខ្ញុំសម្រាប់ធ្វើការហ្នឹង វាទៅជាបន្ទប់មួយដាច់ពីគេពីឯងមួយទៀត។ ដល់ដូចខាងគឹម វុន ហ្នឹងគាត់ទៅនៅក្នុងអគារមួយ ដែលអគារធំទូលាយ សម្រាប់មានគ្នាទំនាក់ទំនងគ្នាច្រើនសម្រាប់ធ្វើការងារអីហ្នឹង។ ហើយដល់ខ្ញុំវាទៅដាច់តែឯង គេហៅថា អ្នកសរសេរ គេទៅសរសេរមួយក្រុមគេទៅ តែដល់ខ្ញុំបច្ចេកទេសខាងនេះ ខ្ញុំមកនៅតែមួយផ្នែករបស់ខ្ញុំនេះមក។ ដល់អ៊ីចឹងគឺថាការងាររបស់ខ្ញុំគឺថា វាៗរឿងដាច់ដោយឡែកពីគ្នា។ ហើយដល់អ៊ីចឹង អគារនិងបន្ទប់នៅហ្នឹង ក៏គ្រាន់ថាវាតភ្ជាប់គ្នា តែវានៅក្នុងបរិវេណហ្នឹងដែរ។ សូមជូនមតិប៉ុណ្ណឹងបាទ ជូនយោបល់។

[១១:៥១:១៦]

**ស៖** លោករៀបរាប់ថា មានអគារនៅជិតៗគ្នា។ អ៊ីចឹងអគារហ្នឹង គឺនៅចម្ងាយពីគ្នាប្រហែលប៉ុន្មានដែរ ហើយនៅឆ្ងាយ ឬក៏នៅជិតគ្នា?

**ស៖** ខ្ញុំសូមឆ្លើយថា ជំនាន់ហ្នឹងដូចជា ជាអគារគេចាស់ពីដើមមក ពីសង្គមមុនមក ក៏ខ្ញុំមិនដឹង។ តែគ្រាន់តែខ្ញុំដឹងថា កន្លែងដែលខ្ញុំទៅនៅក្រោយនេះ ជាកន្លែងឃោសនាការហ្នឹង ពីមុនមកប្រហែលជាអត់មានស្អីទេ ហើយគេទើបនឹងរៀបចំ គេរៀបចំទៅទុកទៅដាក់របស់ហ្នឹង ពេលដែលមុនខ្ញុំមិនទាន់ទៅពេលដែលខ្ញុំមិនទាន់ទៅ ព្រោះដែលខ្ញុំទៅហើយគឺគេថា អ្ហ៊! របស់សុទ្ធតែទើបនឹងយកមកពីទូតអីណាអីណី ហើយគេដំណើរការហើយ ខ្ញុំ គេយកខ្ញុំទៅបណ្តុះបណ្តាលឲ្យរៀនតាមក្រោយគេ។ ដល់អ៊ីចឹងឲ្យដឹងអីពីមុនមក អត់ទេ គ្រាន់តែថាអគារវាភ្ជាប់ជាប់គ្នា ពីមុនមិនដឹងជាស្អីៗ តែគ្រាន់តែគេយកមកដាក់បន្ទប់មួយសម្រាប់ខ្ញុំធ្វើការ។ អស់មតិបាទ។

**ស៖** សូមអរគុណដែលលោកបានឆ្លើយ ក៏ប៉ុន្តែប្រហែលជាខ្ញុំសួរមិនច្បាស់។ តើលោកអាចជម្រាបយើងខ្ញុំដែរឬទេ អគារដែលលោកធ្វើការហ្នឹងនៅឆ្ងាយពីអគារធំ ដែល គឹម វុន នោះ ធ្វើការនោះ តើចម្ងាយអគារលោក កន្លែងដែលលោកធ្វើការហ្នឹង និងអគាររបស់លោក គឹម វុន នោះឆ្ងាយ ចម្ងាយប្រហែលប៉ុន្មានដែរពីគ្នា?

[១១:៥៣:២៤]

**ឆ៖** ខ្ញុំសូមឆ្លើយ។ បើខ្ញុំគិតទៅថា គ្រាន់តែដូចក្នុងអគារមួយអ៊ីចឹង គ្រាន់តែ គេទៅបន្ទប់នោះទៅ ខ្ញុំទៅបន្ទប់នោះទៅ ហើយគ្រាន់តែបរិវេណដែលខ្ញុំធ្វើកន្លងមក ឥឡូវដឹងនៅអ៊ីចឹងទៀតអត់ តែគ្រាន់ថាពីមុខវាចន្លោះផ្លូវសងខាងអ៊ីចេះ ផ្លូវពីមុខផ្លូវពីក្រោយ។ ពីក្រោយក៏មានផ្លូវ ពីមុខក៏មានផ្លូវ សងខាងអ៊ីចេះក៏មានផ្លូវ។ ដល់អ៊ីចឹងនៅទៅ តែគ្រាន់ថាគេទៅបន្ទប់គេ ខ្ញុំមកបន្ទប់ខ្ញុំមក តែគ្រាន់ថា អគារធំនោះវាសង់មួយធំហើយ តែមានអាគចំហៀងលិចកើតហ្នឹង ខ្ញុំមកនៅអាគាមអគារអាគមកចំហៀងតូចតាចខាងៗហ្នឹង។ នេះខ្ញុំ ខាងលោកសួរ ខ្ញុំឆ្លើយបានតែប៉ុណ្ណឹង បាទរឿងអគាររឿងអីហ្នឹង មានតែប៉ុណ្ណឹង។

**ស៖** អង្កាល់ពីម្សិលមិញលោកបានឆ្លើយថា លោកមិនចាកចេញពីកន្លែងការងាររបស់លោកធ្វើការនេះទេ តើអ៊ីចឹងដែរឬទេ គឺលោកអត់មានដើរទៅណា ក្រៅតែពីកន្លែងការងារហ្នឹងទេ?

**ឆ៖** ខ្ញុំសូមឆ្លើយថា នៅកន្លែងការងារក្នុងបរិវេណមន្ទីរហ្នឹងក្នុង ក-៣៣ យើងដើរ តែគ្រាន់តែថាក្នុងន័យថា ការងាររបស់គេ យើងអត់ទៅជំពាក់វាក់វិនអីនឹងការងារគេទេ។ វាចង់និយាយថា វាមិនមែន ជារឿងរបស់យើង យើងអត់ទៅនេះទេ តែការដើរហើរពីកន្លែងយើង វាមានកន្លែងដេកផ្សេង កន្លែងហូបបាយផ្សឹង។ ដល់អ៊ីចឹងការដើរហើរធ្វើការរៀងខ្លួន ហើយដល់ពេលមក យើងមកកន្លែងយើងសម្រាកវិញទាំងអស់គ្នា។ អាហ្នឹងវាៗការងារវាធម្មតាអ៊ីចឹង តែដល់គេទៅកន្លែងគេ គេធ្វើការគេហើយ យើងអត់មានអីទៅៗជំពាក់វាក់វិនអីនឹងការងារគេទៀតទេ។ យើងគិតតែរឿងការងាររបស់យើង ម៉ោងយើងៗ ទៅធ្វើ ផុតពីម៉ោងយើង យើងមកហូបបាយ ហូបទឹក មករកកន្លែងដេក កន្លែងសម្រាក។ នេះធ្វើការដើរហើរ គឺដើរហើរក្រុបខ័ណ្ឌប៉ុណ្ណឹងគឺថា យើងប្រាស្រ័យទាក់ទងពេលហូបបាយ ជួបគ្នាយើង ហើយដល់កន្លែងដេកវិញ អាហ្នឹងវាៗរឿងប៉ុណ្ណឹងឯង។ សូមអស់។

[១១:៥៥:៥៤]

**ស៖** កាលពីម្សិលមិញ លោកក៏បានឆ្លើយផងដែរថា “នួន ជា គាត់មិនមានបន្ទប់ធ្វើការរបស់គាត់ដោយឡែកនោះទេ ហើយគាត់ធ្វើការនៅកន្លែងមួយ វាលចំហានៅក្នុងក្រសួងឃោសនាការ”។

កន្លែងដែលគាត់ធ្វើការនោះ ថាតើគឺនៅក្នុងអគារធំដែលលោកបានរៀបរាប់ពិពណ៌នានេះ ឬក៏នៅកន្លែងណាដែរ?

**ឆ៖** ខ្ញុំសូមបញ្ជាក់បន្ថែមថា អគារដែលគាត់ធ្វើហ្នឹង គឺថានៅក្នុងអគារធំហ្នឹង។ សូមមានមតិប៉ុណ្ណឹងបាទ។

**ស៖** តើលោកអាចរៀបរាប់បន្ថែមបានទៀតដែរឬទេ តើកន្លែងហ្នឹងគឺយ៉ាងម៉េចចំហ អត់មានបិទជិតទេ ឬក៏មានអគារអីត្រឹមត្រូវសម្រាប់គាត់ ឬក៏មានការិយាល័យត្រឹមត្រូវសម្រាប់គាត់?

**ឆ៖** ខ្ញុំសូមឆ្លើយបន្ថែម។ គាត់ធ្វើការហ្នឹង គឺក្នុងអគារធំហ្នឹង តែបើទៅជារូបភាពមួយថា អ្ហ៎! ទាល់តែគោះទ្វារ គោះអីចូលទៅបានជួបគាត់អី ដូចជាអត់ទេ។ គ្រាន់តែថា គាត់ដាក់តាំង ការិយាល័យតុគាត់មួយកន្លែងអីចឹង តែមានអ្នកផ្សេងគេធ្វើឯណោះ ធ្វើអីអីចឹងក្នុងបន្ទប់ធំទៅ។ នេះក្នុងន័យនេះ ខ្ញុំនឹកឃើញឡើងវិញថា ពេលខ្លះខ្ញុំឡើងទៅគេនៅក្បែរហ្នឹង ខ្ញុំហុចឲ្យគេទៅ គាត់អង្គុយធ្វើការងារគាត់ហ្នឹងក៏អង្គុយទៅ។ ដល់ពេលទៅ អ្នកហ្នឹងមិនដឹងទៅត្រង់ណា ជូនខ្ញុំយកទៅជូនគាត់ទៅ។ នេះក្នុងម្តងម្កាលដែលខ្ញុំលើកបញ្ជាក់ពីខាងដើមនោះ ជាបន្ទប់ឲ្យទៅចាំគោះទ្វារ គោះអីនោះគឺ ដូចយើងឥឡូវនេះ អត់ទេ។ ខ្ញុំបញ្ជាក់ប៉ុណ្ណឹង សូមអស់មតិ។

[១១:៥៨:០២]

**ស៖** តើលោកអាចប្រាប់យើងបន្ថែមទៀត លើកចំណុចហ្នឹងបានដែរឬទេ ដោយសារតែកាលពីម្សិលមិញលោកបាននិយាយថា នួន ជា គាត់មិនមានការិយាល័យត្រឹមត្រូវសម្រាប់គាត់នៅក្នុងក្រសួងឃោសនាការនោះទេ។ ក៏ប៉ុន្តែនៅថ្ងៃនេះ គឺលោកហាក់ដូចជាបានឆ្លើយថា នួន ជា គាត់មានមន្ទីរធ្វើការកន្លែងធ្វើការមួយត្រឹមត្រូវទៅវិញ។ ចម្លើយទាំងពីរនេះ ហាក់ដូចជាមានភាពខុសគ្នា។ សូមឲ្យលោកជួយបញ្ជាក់បន្ថែមបានដែរឬទេ?

**ឆ៖** ខ្ញុំសូមបញ្ជាក់បន្ថែមថា ដែលខ្ញុំថាអីហ្នឹង ខ្ញុំអត់ ចង់បញ្ជាក់ថា គាត់ដូចមិនមានបែងចែកបន្ទប់មួយគេហៅថា សម្រាប់ដោយឡែកគាត់ពីកម្លាំងផ្សេងហ្នឹងវាអត់។ គាត់អង្គុយធ្វើហ្នឹងទៅ តែវាមានអ្នកផ្សេងហ្នឹង គេនៅធ្វើក្បែរហ្នឹងដែរ គាត់ចង់ងើបមកមើល មកសួរនាំអីខ្លះ គាត់អញ្ជើញមកគាត់សួរនាំទៅ។ ហើយអ្នកទៅជួបវិញ គ្រាន់តែថា វាមានអ្នកនៅក្បែរហ្នឹង គឺថាបើអ្នកណាចង់ជួបអី។ ដល់អីចឹងហើយ ដែលខ្ញុំបញ្ជាក់ថា ខ្ញុំមិនបានជាប់លាប់អ្នកដែលផ្តល់សក្ខីកម្មមុន គេៗអ្នកសរសេរហ្នឹងប្រហែលជាគេនៅជាប់ គេដឹងរឿងច្រើនជាងខ្ញុំ។ ដល់ខ្ញុំវាដោយឡែក អត់សូវដឹងរឿងទេ តែគ្រាន់ថា

ដែលខ្ញុំឃើញម្ដងម្កាល ដល់គាត់ធ្វើការងារអ៊ីចឹងរបៀបថា គាត់អង្គុយយូរទៅ គាត់ងើបដើរចុះដើរឡើង បន្តិចទៅយើងមើលទៅឃើញគាត់ដើរធម្មតាវាអ៊ីចឹង។ ដល់អ៊ីចឹង ខ្ញុំទៅឃើញកន្លែងគាត់ ដែលៗខ្ញុំឡើង យកឯកសារអីម្ដងជូនគេ ឃើញគាត់អង្គុយច្រង្វូរ យើងហុចទៅគេហើយ ខ្ញុំចុះមកវិញមក វាអត់មាន ការងារអីពាក់ព័ន្ធថាត្រូវនិយាយអី សួរនាំគាត់អីផង។ ខ្ញុំគ្រាន់តែផ្ដល់ថា ឯកសារនេះជូនអ្នកនៅហ្នឹង ហើយ ខ្ញុំបកមកវិញ។ នេះជាការចង់បញ្ជាក់បន្ថែម ខ្ញុំបញ្ជាក់ថែមប៉ុណ្ណឹងបាទ។

[១២:០០:១១]

**ស៖** សូមអរគុណ។ ខ្ញុំនៅមានសំណួរមួយទៀត ទាក់ទងទៅនឹងបញ្ហានេះដដែល។ ដោយសារ ខ្ញុំនៅមិនច្បាស់ នៅមានភាពសង្ស័យនៅលើអ្វីដែលលោកឆ្លើយ ដូច្នេះ ខ្ញុំគ្រាន់តែចង់ឲ្យយល់ច្បាស់តែ ប៉ុណ្ណោះ។ នៅពេលនេះ គឺលោកបានឆ្លើយថា លោកពេលដែលចូលទៅការិយាល័យរបស់គាត់នោះ មិន ដែលគោះទ្វារចូលទៅនោះទេ គឺអត់មានទ្វារទេ។ ដូច្នេះ បានន័យថា នៅក្នុងការិយាល័យរបស់គាត់ ហ្នឹងគឺគាត់អត់មានទ្វារទេ ការិយាល័យនុំង។ តើលោកអាចជួយពន្យល់បន្ថែម បានដែរឬទេ តាមអ្វីដែល លោកដឹង តើស្ថានភាពការងាររបស់ នួន ជា នោះគឺ នៅក្នុងអគារធំនោះ គឺស្ថានភាពការងាររបស់គាត់ នៅយ៉ាងម៉េចដែរការធ្វើការរបស់គាត់?

**ឆ៖** ខ្ញុំសូមឆ្លើយថា ចម្លើយខ្ញុំបានត្រឹម ដូចបញ្ជាក់ខាងដើមហើយ។ ដូចខ្ញុំ គឹម វ៉ុន អាហ្នឹងគាត់ អ្នកសរសេរហ្នឹង គាត់នៅជាប់លាប់ជាងខ្ញុំ ព្រោះគាត់អ្នកសរសេរត្រូវការណែនាំអីយ៉ាងម៉េចៗ អាហ្នឹង ជារឿងរបស់គាត់។ តែដល់ខ្ញុំនេះ គេហៅថា នៅតែធ្វើនេះ បន្តិចថាចប់ហើយ ហែកអាក្រដាសហ្នឹង យកទៅ។ ទៅគ្រាន់តែទៅ ក្រឡេកមួយភ្លែតទៅឃើញគាត់អង្គុយហ្នឹង បើអត់មានទេ យើងយកទៅដាក់ នៅនឹងតុក្បែរគាត់អ៊ីចឹងទៅ យើងបកមកវិញមក។ តែបើទៅ វាមានអ្នកនៅហ្នឹង យើងជូនអ្នកនៅហ្នឹង ទៅ អ្នកហ្នឹងបានយកទៅដាក់តទៀតទៅ។ នេះខ្ញុំៗដឹងខ្លួនឯង និងនៅចងចាំបានតែប៉ុណ្ណឹងទេ ហើយ ដែលហួសពីហ្នឹងទៀត ដូចអត់មានបានដឹង បានយល់អីហួសហ្នឹងទៀត ព្រោះការងារវាអត់ៗ មានការ ទំនាក់ទំនងស្អិតសម្រាប់គាត់ណែនាំយ៉ាងម៉េចៗ អត់ទេ ខ្ញុំគិតតែរឿងការងាររបស់ខ្ញុំដែលហើយៗ ខ្ញុំ យកទៅជូនៗបាទ។ មានយោបល់ប៉ុណ្ណឹង។

[១២:០២:២៨]

**ប្រធានអង្គជំនុំ៖**

អរគុណច្រើន។ ឥឡូវនេះ ដល់ពេលសម្រាកដើម្បីពិសាថ្ងៃត្រង់ហើយ អង្គជំនុំជម្រះប្រកាស

សម្រាក ដើម្បីពិសាថ្ងៃត្រង់ ចាប់ពីពេលនេះតទៅ រហូតដល់ម៉ោងមួយសាមសិបនាទីរសៀលនេះ សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។ ហើយមន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលផ្តល់កន្លែងសម្រាកនៅបន្ទប់រង់ចាំសម្រាប់សាក្សី និងអ្នកជំនាញដល់សាក្សីរូបនេះ នៅក្នុងអំឡុងពេលសម្រាកពិសាអាហារថ្ងៃត្រង់ ហើយនិងឲ្យអញ្ជើញគាត់មកកាន់កន្លែងផ្តល់សក្ខីកម្ម នៅក្នុងបន្ទប់សវនាការនេះវិញ នៅរសៀលនេះ នៅវេលាម៉ោងបានកំណត់ គឺម៉ោងមួយសាមសិបនាទីរសៀល។

សូមអញ្ជើញលោកមេធាវី!

**លោក ហ្សាស្តើ ប៉ោ៖**

សូមអរគុណលោកប្រធាន។ លោកប្រធាន លោក នួន ជា គឺគាត់ឈឺក្បាល ឈឺចង្កេះ និងមិនអាចផ្អង់ជាទូទៅបាន។ ដូច្នេះហើយគាត់ស្នើសុំបន្តតាមដានសវនាការនេះពីបន្ទប់តាមដាននៅខាងក្រោម យើងខ្ញុំបាននឹងលិខិតបោះបង់សិទ្ធិនេះ ជូនលោកប្រធាន។

[១២:០៣:២៩]

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះបានស្តាប់សំណើសុំរបស់លោក នួន ជា ដែលបានធ្វើឡើងតាមរយៈមេធាវីការពារក្តីរបស់គាត់ សុំទៅតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ សម្រាប់រយៈពេលធ្វើសវនាការពេញមួយរសៀលនេះ ដោយមូលហេតុសុខភាព មិនអាចអង្គុយតាមដានយូរនៅក្នុងបន្ទប់សវនាការនេះបាន ដោយមេធាវីសន្យាថានឹងផ្តល់នូវពាក្យសុំលះបង់សិទ្ធិចូលរួមសវនាការដោយផ្ទាល់របស់លោក នួន ជា មកឲ្យអង្គជំនុំជម្រះ។ អង្គជំនុំជម្រះយល់ព្រម និងអនុញ្ញាតឲ្យលោក នួន ជា ទៅបន្តតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ ពីបន្ទប់ឃុំខ្លួនមួយស្ថិតនៅក្រោមសាលសវនាការនេះ តាមរយៈឧបករណ៍សោតទស្សន៍ សម្រាប់រយៈពេលធ្វើសវនាការពេញមួយរសៀលថ្ងៃនេះ។ ហើយលោក នួន ជា បានលះបង់សិទ្ធិមានវត្តមានដោយផ្ទាល់នៅក្នុងបន្ទប់សវនាការនេះ។

អង្គជំនុំជម្រះតម្រូវឲ្យក្រុមមេធាវីការពារក្តីរបស់លោក នួន ជា ប្រគល់មកឲ្យជំនុំជម្រះភ្លាមនូវពាក្យសុំលះបង់សិទ្ធិចូលរួមសវនាការដោយផ្ទាល់ក្នុងបន្ទប់សវនាការ ដោយមានចុះហត្ថលេខា ឬផ្តិតស្នាមម្រាមដៃជាក់ច្បាស់ពីជនជាប់ចោទ នួន ជា។ ហើយបង្គាប់ឲ្យផ្នែកសោតទស្សន៍ភ្ជាប់ប្រព័ន្ធសោតទស្សន៍ សម្រាប់ជនជាប់ចោទ នួន ជា អាចតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ ពីបន្ទប់ឃុំខ្លួនមួយស្ថិតនៅក្រោមសាលសវនាការនេះសម្រាប់រយៈពេលនៃកិច្ចដំណើរការសវនាការនៅរសៀលនេះ។

[១២:០៤:៤៤]

បង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនលោក នួន ជា និង ខៀវ សំផន ទៅកាន់បន្ទប់ឃុំខ្លួនខាងក្រោម ដោយនៅរសៀលនេះ ទុកឲ្យលោក នួន ជា នៅក្នុងបន្ទប់ដែលរៀបចំជាស្រេចនូវឧបករណ៍សោតទស្សន៍ សម្រាប់គាត់អាចចូលរួម និងតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ។ ដោយឡែកលោក ខៀវ សំផន ឲ្យនាំខ្លួនគាត់មកកាន់បន្ទប់សវនាការនេះវិញ នៅរសៀលនេះឲ្យបានមុនម៉ោងមួយសាមសិបនាទី។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១២:០៥ នាទី ដល់ម៉ោង ១៣:៣១នាទី)*

[១៣:៣១:២០]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ! អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ ហើយនិងផ្តល់វេទិកាជូនទៅក្រុមមេធាវីការពារក្តីលោក នួន ជា ដើម្បីមានឱកាសបន្តការតាំងសំណួរដេញដោលចំពោះសាក្សី។

សូមអញ្ជើញ!

**លោក ហ្សាស្តើ ប៉ោ៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោក ហ្សាស្តើ ប៉ោ៖**

**ស៖** លោក ខៀវ អេន យើងបាននិយាយមុនពេលសម្រាកនេះ យើងនិយាយអំពីៗស្ថានការណ៍នៅក្រសួងឃោសនាការ ហើយខ្ញុំយោងទៅរកស្ថានភាពជាក់ស្តែង អំពីរចនាសម្ព័ន្ធ នៃអគារ នៃបរិវេណអគារនោះ។ ហើយលោកបានឆ្លើយថា លោកធ្វើតែការងាររបស់លោក នៅក្នុងនៅអគារតូចមួយបាទបន្ទប់ ឬក៏អគារតូចមួយឆ្ងាយពីអគារធំ។ បន្ទប់ដែលកន្លែងលោកធ្វើការនោះ តើបន្ទប់នោះមានបង្អួចដែរឬទេ ដែលថាលោកអាចមើលទៅក្រៅឃើញដែរឬទេ?

**លោក ខៀវ អេន៖**

**ឆ៖** ខ្ញុំសូមឆ្លើយនូវសំណួរនេះបន្តពីសំណួរព្រឹកមិញ។ អគារដែលខ្ញុំធ្វើការហ្នឹងគឺមានបង្អួច តែសម្រាប់ផ្លូវចូលទៅគឺជា ហាក់ដូចជារោងទងមួយអ៊ីចឹង តែគ្រាន់ថាមានផ្លូវចូលទៅ ពីអគារធំហ្នឹង ហើយទៅដល់អាកន្លែងដែលត្រូវធ្វើការហ្នឹង គឺថាមានបង្អួចបែរទៅជើងទៅរកផ្លូវ ដែលនៅពីក្រោយអគាររបស់ខ្ញុំហ្នឹង។ ដូច្នេះវាជាអគារមួយដែលចែកពីអគារធំហ្នឹង ចូលទៅក្នុងបន្ទប់មួយដែលផ្លូវចូលពី ៗ ដូចខ្ញុំបញ្ជាក់ថា ពីក្រោមដំបូលដែលមានរបៀបជារោងទងផ្លូវចូលទៅ ហើយទៅដល់កន្លែងខ្ញុំហ្នឹងគឺកន្លែងធ្វើការ ហើយខាងក្រោយខ្ញុំនោះ គឺអត់មានទ្វារចេញទៅខាងក្រោយទេ គឺមានតែបង្អួចទេ។ ហ្នឹងសូមជូនជាចម្លើយប៉ុណ្ណឹងបាទ។

[១៣:៣៤:២៤]

**ស៖** ហើយបង្អួចនេះបែរទៅខាងជើងទៅផ្លូវ តើលោកអាចឃើញអគារធំតាមបង្អួចហ្នឹងដែរឬទេ ឬក៏ត្រូវមើលទៅខាងទិសផ្សេងពីបង្អួចនេះ?

**ឆ៖** ខ្ញុំសូមឆ្លើយបន្ថែម។ បង្អួចដែលខ្ញុំធ្វើការនៅក្នុងអគារខ្ញុំនោះ គឺថាវានៅពីខាងជើងអគារ ឯផ្លូវក៏មាននៅខាងជើង តែឆ្លងពីផ្លូវហ្នឹងទៀត ក៏មានអគារដែលខ្ញុំបញ្ជាក់ថា ជា លីសេ ដេកាត កាលជំនាន់ហ្នឹង ដែលសំណល់ពីមុនមកហ្នឹង វាមានអគារធំៗហ្នឹងនៅពីខាងហ្នឹង។ នេះសូមមានមតិ។

[១៣:៣៥:២៨]

**ស៖** តាមដែលខ្ញុំយល់នោះ តើខ្ញុំយល់ត្រូវដែរឬទេថាលោក ខៀវ អេន លោកមិនអាចឃើញអគារធំរបស់ក្រសួងឃោសនាការទេ តាមរយៈបង្អួចនេះនេះ បើមើលតាមបង្អួចទៅមើលមិនឃើញទេ តើអ៊ីចឹងឬទេ?

**ឆ៖** ខ្ញុំសូមឆ្លើយ។ អគារដែលនៅពីក្រោយខ្ញុំហ្នឹង ជាអគាររបស់ លីសេ ដេកាត ពីជំនាន់មុន តែអគារធំដែលធ្វើសម្រាប់ដែលក្រសួងចំនេះគឺ វានៅពីមុខខ្ញុំវិញទេ ព្រោះផ្លូវចូលមកអគារខ្ញុំ គឺពីត្បូងមកជើង។ ហើយដល់អគារធំនោះ វានៅពីខាងត្បូងខ្ញុំទេ វានៅពីត្បូងខ្ញុំ។ ដល់អ៊ីចឹង ខ្ញុំចូលពីៗចំហៀងអគារពីក្រោយអគារហ្នឹង ព្រោះអគារហ្នឹងបែរមុខទៅត្បូងបាទ។ ហើយដល់ខ្ញុំចូលពីក្រោយអគារមក ខ្ញុំប្រហែលជាមិនដល់ពាក់កណ្ដាលអគារផង ខ្ញុំដើរកាច់ចូលទៅជើង។ ហើយដល់ចូលទៅជើងទៅ មានដំបូលគេអ៊ីចឹង ហើយដល់អ៊ីចឹងមានកន្លែងខ្ញុំធ្វើការ ដោយអគារខ្ញុំនោះវាជាប់នឹងផ្លូវមួយ ដែលនៅខាងជើងក្រសួង ជើងមន្ទីរហ្នឹង។ នេះសូមមានមតិប៉ុណ្ណោះ។ អស់យោបល់ហើយ។

**សៈ** បាទ ច្បាស់ហើយ។ ខ្ញុំសួរលោក អំពីពេលវេលា ដែល ហ៊ូ នឹម ជាអ្នកទទួលខុសត្រូវ នៃក្រសួងឃោសនាការនោះ។ ខ្ញុំសូមសួរឡើងវិញ តើ ហ៊ូ នឹម អាចចូលទៅអគារធំរបស់ក្រសួងឃោសនាការបានដែរឬទេ ដែលថា លោកមិនអាចឃើញគាត់ទេ ពីព្រោះថា លោកនៅក្នុងបន្ទប់របស់លោកនៅធ្វើការនេះ ម្ខាងខាងណោះ?

[១៣:៣៧:៤៣]

**ឆៈ** ខ្ញុំសូមឆ្លើយ ចំពោះកាលដែល ហ៊ូ នឹម នៅ ពេលហ្នឹងបើគិតជាការស្គាល់ ការឃើញកាន់តែតិចជាងអ្នកដឹកនាំក្រោយៗទៀត។ ព្រោះដូចខ្ញុំបញ្ជាក់ខាងដើមថា ខ្ញុំទៅពីឆ្ងាយពីខេត្តពីអីទៅ ទៅចូលហ្នឹងដូចថា វាអត់សូវស្គាល់ទីកដី ស្គាល់កន្លែងហ្នឹងទេ។ ដល់អ៊ីចឹងគេឲ្យធ្វើអី យើងទៅតែតាមគេ ដែលគេនៅចាស់ហើយហ្នឹង យើងត្រូវធ្វើតាមគេ។ ដល់អ៊ីចឹងកន្លែងខ្លះគឺយើងអត់ដឹង ដំបូងអត់ដឹងថា អ្នកណាធ្វើអីៗទេ យើងធ្វើតែតាមដែលមេគេ ជាមេរបស់យើងម្នាក់ហ្នឹង គេឲ្យធ្វើអីយើងធ្វើតាមគេទេ។ ដល់អ៊ីចឹងពីដំបូងហ្នឹង ការដឹង ការស្គាល់កន្លែងជាបន្ទប់អី ហ៊ូ នឹម ធ្វើដូចពេល នួន ជា គាត់មកធ្វើនេះ ខ្ញុំអត់ដឹងទេមុន អត់ដឹងទេបាទ។ សូមមានចម្លើយ ជូនប៉ុណ្ណឹងបាទ។

**សៈ** ខ្ញុំយល់ចម្លើយរបស់លោកហើយ។ ហើយខ្ញុំយល់ហើយថា លោកមិនបានឃើញលោក ហ៊ូ នឹម ជាញឹកញាប់ទេ។ ប៉ុន្តែសំណួររបស់ខ្ញុំសួរជាពិសេស ទាក់ទងទៅនឹងច្រកចូល ឬក៏ការចូលទៅច្រកចូលទៅអគារធំនោះ ចេញ បើគិតពីការិយាល័យរបស់លោកនោះ តើលោកអាចមើលឃើញថា លោក ហ៊ូ នឹម ដើរចូលមកអគារធំ ដែលគាត់មកធ្វើការពេលព្រឹក នោះអាចមើលឃើញ ឬក៏មិនអាចមើលឃើញ ឬក៏មានអ្វីបាំង?

[១៣:៣៩:៣៦]

**ឆៈ** ខ្ញុំសូមឆ្លើយ។ ផ្លូវដែលខ្ញុំចូលគឺ ចូលពីក្រោយអគារទេ តែ ហ៊ូ នឹម ដែលខ្ញុំឃើញភាគច្រើនគាត់ចេញពីកន្លែងការងារ គាត់មកអង្គុយហូបបាយ។ ហើយទទួលពេលខ្លះ ខ្ញុំក៏ចេញពីកន្លែងការងារ ក៏ចេញមកហូបបាយដែរ ក៏ងាកទៅ ឃើញគាត់ហូបបាយ យើងក៏ដើរហួសទៅ។ នេះ ខ្ញុំដែលធ្លាប់ឃើញធ្លាប់ជួបអីអ៊ីចឹងទេបាទ។ សូមជូនប៉ុណ្ណឹងបាទ។

**សៈ** លោកនិយាយថា លោកបានឃើញ ហ៊ូ នឹម នៅពេលដែលគាត់មកហូបបាយ ហើយលោកនិយាយថា ច្រកចូលទៅអគារធំនោះ គឺនៅខាងក្រោយការិយាល័យរបស់លោក។ តើត្រូវដែរទេ ដែលខ្ញុំយល់ចម្លើយរបស់លោក ដែលថាលោកមិនអាចមើលឃើញច្រកទ្វារចូលទៅបរិវេណទេ? ហើយ

ក៏មិនដែលមើលឃើញថា លោក ហ៊ូ នឹម ដើរចូលមកនៅមន្ទីររបស់គាត់ទេ គឺអាចឃើញគាត់តែនៅពេលគាត់ហូបបាយថ្ងៃត្រង់តែប៉ុណ្ណឹង?

[១៣:៤០:៥៥]

**ឆ៖** សំណួរនេះហាក់ដូចជា សួរហើយខុសពីការឆ្លើយរបស់ខ្ញុំ។ ព្រោះការឆ្លើយរបស់ខ្ញុំអគារដែលធំត្រូវធ្វើការហ្នឹងនៅខាងមុខ អគារខ្ញុំនៅពីក្រោយ តែផ្លូវចូលដែលខ្ញុំទៅធ្វើការ ខ្ញុំចូលពីក្រោយអគារ។ ពីក្រោយអគារធំហ្នឹង ខ្ញុំចូលមកបានមានរបៀបជារោងទងហើយ ខ្ញុំមកធ្វើការមកដោយនៅពីក្រោយអគារខ្ញុំហ្នឹងមានបង្អួច ហើយមានផ្លូវ បាទ។ ដល់អ៊ីចឹងការសួរនេះខ្ញុំរកចម្លើយបញ្ជាក់ទៅវិញអត់បានទេ ខ្ញុំគ្រាន់តែ ដល់សួរអ៊ីចឹងខ្ញុំចង់ដឹងថា តើសួរហ្នឹងមានអគារណានៅពីក្រោយខ្ញុំទៀត ព្រោះខ្ញុំប្រាប់ថានៅពីក្រោយខ្ញុំមាន ដែលឥឡូវគេហៅ អំ អង្កាល់ជំនាន់នោះ ដែលគ្រាន់តែដឹងថាវាជា លីសេដេកាត ចាស់មុន។ បាទ សូមមានមតិប៉ុណ្ណឹងបាទ។

**ស៖** ខ្ញុំសូមអភ័យទោស ប្រសិនបើលោកស្តាប់ខ្ញុំមិនច្បាស់ យល់ខ្ញុំមិនច្បាស់។ តើត្រឹមត្រូវដែរឬទេ ដែលថាអ្វីដែលលោកបានប្រាប់មកខ្ញុំថ្ងៃនេះនោះថា បាទ មើលពីបន្ទប់ការងាររបស់លោកទៅលោកមិនអាចមើលឃើញច្រកចូលទៅអគារធំហ្នឹងបានទេ។ តើអ៊ីចឹងឬទេ?

[១៣:៤២:៣៦]

**ឆ៖** ខ្ញុំសូមឆ្លើយ។ កន្លែងអង្គុយធ្វើការនោះវាអត់ឃើញទេ ព្រោះវាទៅក្នុងបន្ទប់អត់ឃើញទេ បើឃើញទៅក្រោយអ៊ីចេះ បង្អួចពីក្រោយខ្ញុំឃើញ។ អាហ្នឹងខ្ញុំទៅ ឃើញអាលីសេដេកាត ដែលខ្ញុំបញ្ជាក់អំមិញ តែដល់ពីមុខមានតែច្រកចូល។ តែគ្រាន់តែថាមុននឹងចូលដល់កន្លែងខ្ញុំធ្វើការហ្នឹង គឺផ្លូវដែលចូលខ្ញុំហ្នឹង គឺចូលពីក្រោយអគារ។ តែអគារវាមានច្រកគេចូលពីមុខមួយទៀត។ នេះខ្ញុំបញ្ជាក់ជូននូវសំណួរហ្នឹងប៉ុណ្ណឹង។

**ស៖** នេះជាចម្លើយច្បាស់ណាស់ ខ្ញុំគិតថាយើងមានការដោះស្រាយការភ័ន្តច្រឡំគ្រប់អស់ហើយ។ តើត្រឹមត្រូវដែរឬទេ ក្នុងការនិយាយថា បុគ្គលិករបស់ក្រសួងឃោសនាការនោះ អាចចូលអគារធំដោយលោកមិនបានមើលឃើញពួកគាត់ដើរចូលមកទេ?

**ឆ៖** ខ្ញុំសូមឆ្លើយ។ ខ្ញុំឆ្លើយថា បើខ្ញុំនៅក្នុងបន្ទប់ខ្ញុំមិនដឹងគាត់ចូលថ្មើរម៉ាន។ អ៊ីចឹងបានថាកន្លែងខ្លះជាការចេញមកដោយការពើប ដោយចៃដន្យ ទទួលគាត់ គាត់ចេញពីកន្លែងគាត់ គាត់ទៅហូបបាយ ហើយយើងក៏ដល់ម៉ោងចេញទៅ ជួនពើបទៅ។ តែពេលខ្លះគាត់ទៅមុនបាត់ទៅ គាត់ទៅហូប

ខ្ញុំចេញទៅជួនដើរទៅឃើញគាត់អង្គុយហូបបាយ យើងគ្រាន់តែងាកឃើញ យើងដើរហួសទៅ។ នេះជាចម្លើយខ្ញុំជូនប៉ុណ្ណឹងបាទ។

[១៣:៤៤:៥០]

**ស៖** បាទ នេះច្បាស់ហើយ។ អ៊ីចឹងយើងចូលឲ្យជ្រៅបន្តិច។ បាទ ខ្ញុំសូមរៀបឃ្លាឡើងវិញ។ លោកបាននិយាយថា “នៅពេលខ្លះ នួន ជា ទទួលបន្ទុកក្រសួងឃោសនាការ” តើលោក អាចដកលទ្ធភាពណាមួយចេញ ដែលថាយុន យ៉ាត ស្ថិតនៅ ឬក៏មកក្រសួងឃោសនាការដែរ នៅពេលដែលថាលោក នួន ជា គាត់ទទួល ខុសត្រូវនោះ?

**ប្រធានអង្គជំនុំ៖**

សាក្សី កុំអាលទាន់ឆ្លើយតប! សូមអញ្ជើញតំណាងសហព្រះរាជអាជ្ញា!

**លោក ឌេល លីសាក់៖**

ខ្ញុំមានចំណុចពីរលោកប្រធាន ដែលថាមេធាវីគាត់បានយោងទៅរកក្រសួងការបរទេសដោយមិនត្រឹមត្រូវ ប៉ុន្តែយើង -- បើសិនជាគាត់សួរបែបនោះ គឺថាធ្វើឲ្យសាក្សី គាត់ឆ្លើយដោយស្មាន ដោយព្រាវ មិនត្រឹមត្រូវទេ។ រីឯថាឲ្យដកចេញនូវឱកាសណាមួយនោះ ក៏អាចធ្វើឲ្យសាក្សីគាត់ឆ្លើយព្រាវដែរ។

[១៣:៤៦:១៩]

**លោក ហ្សាស្តេ ប៉ោ៖**

ខ្ញុំអាចនិយាយខុស គឺថាខ្ញុំសំដៅតែក្រសួងឃោសនាការ ហើយខ្ញុំមិនសួរឲ្យសាក្សីឆ្លើយព្រាវឬក៏សន្និដ្ឋានទេ គឺថាឲ្យគាត់ឆ្លើយអំពីអ្វីដែលគាត់បានឃើញនៅក្រសួងឃោសនាការនៅពេលនោះ។ ហើយខ្ញុំរីករាយនឹងសួរសំណួរឡើងវិញ។

**សួរដោយលោក ហ្សាស្តេ ប៉ោ៖**

**ស៖** សំណួររបស់ខ្ញុំ គឺថាលោកសាក្សី តើលោកដឹង ឬក៏ស្គាល់ថាតើ យុន យ៉ាត ធ្លាប់មកក្រសួងឃោសនាការដែរឬទេនៅពេលដែល នួន ជា ជាអ្នកទទួលបន្ទុកកន្លែងនោះ តាមដែលលោកដឹងលោកឃើញនោះ?

**លោក ខៀវ អេន៖**

**ឆ៖** ខ្ញុំសូមឆ្លើយ។ បាទ រឿង យុន យ៉ាត ដែលថាចេញហើយ ហើយពេល នួន ជា មកតើ

យុន យ៉ាត ហ្នឹងនៅមានទៅមកទៀតដែរឬអត់? ខ្ញុំសូមឆ្លើយថា ដែលខ្ញុំនៅទទួល និងការចងចាំបានខ្លះ គឺថា ជាជំហានដំបូង យុន យ៉ាត ដូចជាមាននៅការទៅមកខ្លះ។ តែដល់ក្រោយមក ក៏ដូចជាសកម្មភាពដែលខ្ញុំឃើញហ្នឹង ឬអ្នកផ្សេងដឹង ខ្ញុំមិនដឹងទេ។ តែឃើញថាដូច យុន យ៉ាត ហ្នឹងស្ងាត់ទៅអ៊ីចេះ។ អ៊ីចឹងហើយបាន ខ្ញុំជូនជាចម្លើយថា រឿងខាងលើៗ ចាត់ចែងយ៉ាងម៉េច ខ្ញុំអត់ដឹងទេ។ តែគ្រាន់តែថា ដែលខ្ញុំរស់នៅ ខ្ញុំឃើញមានសភាពអ៊ីចឹង។

[១៣:៤៨:១៧]

សភាពត្រង់ថា ដែលថា នួន ជា មកហើយ យុន យ៉ាត ឃើញទៅមកមួយរយៈ។ ដល់ក្រោយមកឃើញ យុន យ៉ាត ហ្នឹងដូចៗឈប់ឃើញមក នៅសល់តែ នួន ជា ហ្នឹងអ្នកនៅ។ ហើយសម្រាប់ការងារផ្សេងទៀតដែលគេធ្វើ អាហ្នឹងបច្ចេកទេសរបស់គេ ដែលខាងលើណែនាំមកឲ្យគេធ្វើអាហ្នឹង ខ្ញុំអត់ដឹងដែរ ដូចជាចម្លើយខាងដែលបញ្ជាក់ពីព្រឹកហើយជាសាក្សី ដែលខ្ញុំថាឈ្មោះ ឆោមៗ ខ្ញុំដឹងថាឈ្មោះក្រោយហ្នឹង។ អាហ្នឹងគាត់ ការងាររបស់គាត់យ៉ាងម៉េច អាហ្នឹងការងាររបស់គាត់។ តែដែលខ្ញុំឃើញក្នុងការរស់នៅជាក់ស្តែងខាងខ្ញុំ ខ្ញុំដឹងតែប៉ុណ្ណឹង។ ខ្ញុំបញ្ជាក់ជូនប៉ុណ្ណឹងបាទ។

[១៣:៤៩:០៧]

**ស៖** បាទ ហ្នឹងហើយជាអ្វីដែលខ្ញុំចង់ សង្ឃឹមថា លោកនឹងផ្តល់ចម្លើយផ្អែកលើអ្វីដែលលោកបានដឹង។ តើអាចដែរឬទេ ដែលថា យុន យ៉ាត មកអគារធំនោះ ការិយាល័យធំនៅអគារធំ ដែលលោកមិនអាចមើលឃើញគាត់ទេ ពីព្រោះថាលោកធ្វើការនៅក្នុងបន្ទប់របស់លោក?

**ឆ៖** ខ្ញុំសូមឆ្លើយ។ យុន យ៉ាត មកគាត់មកធ្វើការរបស់គាត់ តែគ្រាន់ថា ខ្ញុំបញ្ជាក់ពីខាង ដើមមកហើយថា ការងាររបស់ខ្ញុំហ្នឹង គឺមិនសូវមានការពាក់ព័ន្ធពីខាងលើណែនាំអីច្រើនទេ បើណែនាំក្រែងមេគេលើខ្ញុំដែលគេគ្រប់គ្រងខ្ញុំហ្នឹង គេទទួលការណែនាំយ៉ាងម៉េចទៀតអាហ្នឹងខ្ញុំអត់ដឹងទេ។ តែដែលខ្ញុំទទួលពីមេរបស់ខ្ញុំ ដែលគេឲ្យមកខ្ញុំធ្វើនេះគឺថា ខ្ញុំចេះតែធ្វើតាមដែលគេរៀបចំឲ្យ ខ្ញុំធ្វើតាមបច្ចេកទេសខ្ញុំដែលៗគេប្រាប់ខ្ញុំ ខ្ញុំធ្វើអ៊ីចឹងទៅ។ ដល់អ៊ីចឹងរឿង យុន យ៉ាត អីដែលគាត់មកអីៗហ្នឹងពេលខ្លះក៏ឃើញយើងចេញមកធ្វើការ ពេលយើងចូលធ្វើការគាត់មក យើងងាកទៅឃើញ តែដល់ពេលឲ្យឃើញរាល់ថ្ងៃថា អ៊ីចេះអ៊ីចុះអត់ទេ។ តែថា មកជួបពេលវេលាមិនកំណត់គ្នាជាមុនទេ តែមកពើបទៅឃើញជួបគាត់ទៅ ហើយដល់ពេលគាត់ទៅវិញក៏យើងអត់ដឹង។ ពេលខ្លះគាត់ចេញទៅ ឃើញគាត់ចេញផុតទៅងាកទៅឃើញ។ នេះជាសភាពដែលខ្ញុំរស់នៅ ហើយខ្ញុំឃើញ។ ខ្ញុំសូមជូនប៉ុណ្ណឹងបាទ។

[១៣:៥១:១២]

**ស៖** នៅពេលដែលលោកនិយាយថា ថ្នាក់លើអាចមានទំនាក់ទំនងជាមួយថ្នាក់អ្នកគ្រង់គ្រងរបស់លោក ដោយលោកមិនបានដឹងទេ។ តើលោកយល់ស្របជាមួយខ្ញុំដែរឬទេថា ថ្នាក់លើអាចៗជា យុន យ៉ាត នោះ?

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប! សូមអញ្ជើញតំណាងសហព្រះរាជអាជ្ញា!

**លោក ឌេល លីសាក់៖**

លោកប្រធាន ខ្ញុំសូមជំទាស់សំណួរនេះ ព្រោះឲ្យសាក្សីគាត់ធ្វើការសន្និដ្ឋានដោយស្មានៗ ដែលថាត្រូវផ្អែកទៅលើតែការចងចាំជាក់ស្តែងរបស់សាក្សីពីអ្វីដែលគាត់បានឃើញ បើសួរឲ្យគាត់សន្និដ្ឋានថាតើ នួន ជា, យុន យ៉ាត ឬ ប៉ុល ពត តើអាចដែរឬទេ? បែបនេះ គឺថាអាចឲ្យសាក្សីគាត់ឆ្លើយសន្និដ្ឋានហើយអាចគាត់ឆ្លើយព្រាវមកមិនត្រឹមត្រូវទៅតាមការពិតទេ។

[១៣:៥២:២០]

**លោក ហ្សាស្តើ ប៉ោ៖**

ខ្ញុំនឹងបន្តទៅទៀតលោកប្រធាន។

**សួរដោយលោក ហ្សាស្តើ ប៉ោ៖**

**ស៖** តាមពិតខ្ញុំនឹងសួរសំណួរខាងដើមរបស់ខ្ញុំឡើងវិញពីព្រោះថា ចម្លើយរបស់សាក្សីមិនទាន់ច្បាស់សម្រាប់ខ្ញុំនៅឡើយទេ។ ទោះបីជានៅពេលដែលលោក នួន ជា អ្នកទទួលបន្ទុកតាមអ្វីដែលលោកឆ្លើយនោះ។ ទោះបីជានៅពេលដែលលោកនិយាយថា យុន យ៉ាត ឈប់មកៗកន្លែងហ្នឹងតទៅទៀតហើយនោះ តើលោកអាចដកឱកាសមួយចំនួនទេដែលថា យុន យ៉ាត នៅតែអាចមកក្រសួងឃោសនាការ ប៉ុន្តែលោកមិនបានឃើញគាត់ទេ ដោយសារថាលោកនៅក្នុងបន្ទប់របស់លោកនោះ?

[១៣:៥៣:៣៣]

**ឆ៖** ខ្ញុំសូមឆ្លើយ ក្នុងន័យថា ការងារខាងលើ ហើយនិងដែលខ្ញុំបញ្ជាក់អំមិញថា ពីលើអីនេះគឺថា ន័យដែលលើហ្នឹងគឺមានគេលើខ្ញុំបន្តៗ តែទម្រាំដល់លើថ្នាក់ក្រសួងហ្នឹងវាមានលើច្រើនណាស់។ តែដល់ខ្ញុំវាថា អត់មានតួនាទីអីទេ បានសេចក្តីថា អ្នកលើពីខ្ញុំនេះទៅទៀតគេទទួលទៅៗបន្តអ្នកលើទៀតខ្ញុំអត់ដឹងទេ។ ខ្ញុំដឹងតែលើដែលគ្រប់គ្រងខ្ញុំផ្ទាល់នេះ ខ្ញុំ -- គេឲ្យខ្ញុំធ្វើអីខ្ញុំធ្វើហ្នឹង តែដល់អ្នកទៅលើទៀត

ខ្ញុំ លើកពីខ្ញុំប៉ុន្មានជាន់ទៀត ខ្ញុំអត់ដឹងរឿង ដឹងតែលើដែលគេទទួលរបស់ខ្ញុំ ការងារខ្ញុំ។ ដល់អ៊ីចឹងលើកក្នុងន័យដែលខ្ញុំបញ្ជាក់នេះ គឺថាអាពីលើខ្ញុំនេះទៀត អាហ្នឹងគេទៅខាងលើទៀត។ តែដល់លើៗសម្រាប់ខ្ញុំដែលនិយាយនេះ គឺថាគេអ្នកគ្រប់គ្រងខ្ញុំផ្ទាល់ខាងបច្ចេកទេសហ្នឹង។ ដល់ខ្ញុំនិយាយពីរឿងថា រឿងទូរពុម្ពគឺលើរបស់ខ្ញុំហ្នឹង មានមេរបស់ខ្ញុំមួយទទួលខាងហ្នឹងគេអ្នកបញ្ជាឲ្យខ្ញុំធ្វើអី គឺខ្ញុំធ្វើហ្នឹង។ តែដល់ទៅលើទៀត ដូចខ្ញុំថា ជួបខ្លះជាថៃដន្យខ្ញុំចេញមកជួបគាត់។ តែដល់គាត់ហៅលើខ្ញុំនុ៎ងទៅណែនាំយ៉ាងម៉េចទៀត អាហ្នឹងខ្ញុំអត់ដឹងរឿង។ នេះសូមជូនប៉ុណ្ណឹងបាទ។

[១៣:៥៤:៥៩]

**ស៖** សូមអរគុណ។ ខ្ញុំគិតថា ខ្ញុំយល់ច្បាស់ជាងមុនហើយឥឡូវនេះ។ លោកបានឆ្លើយអំពីលោក គឹម វុន ហើយលោកក៏បានផ្តល់សក្ខីកម្មអំពីតួនាទីរបស់គាត់នៅក្រសួងឃោសនាការផងដែរ។ លោកបានពន្យល់ថា គាត់ធ្វើការនៅផ្នែកមួយ ដែលៗមេដឹកនាំមកកន្លែងនោះញឹកញាប់ជាងកន្លែងរបស់លោក។ តើលោកមានមូលហេតុអ្វីទេ ដែលថាលោកមិនជឿថា គឹម វុន និយាយបែបនេះនោះពិត ពីព្រោះថានៅពេលដែលគាត់និយាយថា យុន យ៉ាត ទទួលបន្ទុកនៅក្រសួងនោះរហូតដល់ឆ្នាំ -- ដល់ខែមករា ឆ្នាំ១៩៧៩ ខ្ញុំមិនសុំឲ្យលោកធ្វើការនិយាយសន្និដ្ឋានព្រាវ ឬក៏ទាយនោះទេ ទាក់ទងទៅនឹងមូលហេតុដែល គឹម វុន ហៅ ឆោម និយាយរឿងនេះនោះ។ ប៉ុន្តែចង់ឲ្យលោកឆ្លើយអ្វីដែលលោកបានដឹងច្បាស់អំពីក្រសួងឃោសនាការនៅពេលនោះ។ តើលោកដឹងថាហេតុអ្វីដែលលោកមិនជឿថា គឹម វុន និយាយថា ដែលលោកមិនជឿថា គឹម វុន និយាយថា យុន យ៉ាត បន្តធ្វើការងារនៅហ្នឹងរហូតដល់ខែមករា ឆ្នាំ១៩៧៩?

[១៣:៥៦:៤៤]

**លោក ឌេល លីសាក់៖**

លោកប្រធាន មេធាវីហាក់ដូចជាសួរឲ្យសាក្សីរូបនេះផ្តល់ការសន្និដ្ឋានទៅលើសក្ខីកម្មរបស់សាក្សីមួយទៀត ពីព្រោះថាបើមេធាវីសួរបែបនេះហាក់ដូចជានាំឲ្យមានការគ្រោះថ្នាក់មួយក្នុងការសួរឲ្យសាក្សីរូបនេះទៅផ្តល់យោបល់ទៅលើសក្ខីកម្មរបស់ គឹម វុន ដែល គឹម វុន មិនអាចមកតទល់បាននៅពេលនេះ ហើយមេធាវីបានលើកឡើងថា គឹម វុន មានទំនាក់ទំនងញឹកញាប់ជាមួយ នួន ជា ប៉ុន្តែ គឹម វុន មិនបាននិយាយបែបនោះទេ គឺថាសាក្សីនេះបាននិយាយថាគាត់បានឃើញ ឬក៏ជួបទាក់ទងហើយពេលនោះគឺថា ហើយក្រោយមកគឺបុគ្គលរូបនោះគឺត្រូវបានចាត់តាំងឲ្យទៅវិទ្យុមួយផ្សេងទៀត។

ហើយដូច្នេះបើសួរឲ្យសាក្សីរូបនេះបំភ្លឺពីករណីរបស់សក្ខីកម្មរបស់សាក្សីមួយទៀត អាហ្នឹងគឺជាការមិនសមស្រប។

**លោក ហ្សាស្តេ ប៉ោ៖**

ខ្ញុំមិនសួរឲ្យសាក្សីរូបនេះធ្វើការសន្និដ្ឋានព្រាវនោះទេ គឺថាខ្ញុំបានលើកប្រតិចារឹកចម្លើយរបស់ គឹម វុន ហើយសាក្សីបានឆ្លើយថា គាត់ធ្វើការ គឹម វុន។ ហើយគាត់ដឹងថាគាត់មានតំណែងមួយ ហើយគាត់អាចនឹងឆ្លើយបាន ហើយសាក្សីរូបនេះអាចនិយាយបានអំពីព័ត៌មានដែលទាក់ទងទៅនឹង គឹម វុន។ ហើយក៏ខ្ញុំសួរគាត់ថា ថាតើខ្ញុំសួរសាក្សីរូបនេះថាតើចម្លើយរបស់ គឹម វុន ហ្នឹងត្រឹមត្រូវ ឬក៏មិនត្រឹមត្រូវតាមការដឹងរបស់សាក្សីរូបនេះ បើប្រៀបធៀបការដឹងរបស់គាត់ និងការដឹងរបស់សាក្សី គឹម វុន នោះតែប៉ុណ្ណឹងបាទ។

[១៣:៥៨:៣៨]

**ប្រធានអង្គជំនុំ៖**

សេចក្តីជំទាស់ និងសំអាងហេតុនៃសេចក្តីជំទាស់របស់តំណាងសហព្រះរាជអាជ្ញាត្រឹមត្រូវ។ សេចក្តីជំទាស់មានប្រសិទ្ធភាព។ សាក្សីមិនបាច់ ចាំបាច់ឆ្លើយតបទៅនឹងសំណួរបែបនេះទេ!

ម្តងទៀត តើពេលវេលារបស់លោកត្រូវការប្រើប្រាស់ប៉ុន្មាន ចៀសវាងមានការភ័ន្តច្រឡំ ព្រោះនៅមេធាវីពីរក្រុមទៀត។ ព្រឹកមិញមេធាវីពីរក្រុមមិនបានបញ្ជាក់អំពីបញ្ហាពេលវេលានោះទេ។ ចៀសវាងមានការភ័ន្តច្រឡំ លោកប្រើប្រាស់ពេលវេលាអស់ ស្រាប់តែមេធាវីពីរក្រុមទៀតទាមទារពេលវេលាបន្ថែមនោះ គឺយើងមិនអនុញ្ញាតឲ្យធ្វើដូច្នោះទេ។ លោកបញ្ជាក់បញ្ហានេះឡើងវិញ មុននឹងលោកបន្តសំណួរ។

លោក មេធាវី ហ្សាស្តេ ប៉ោ និយាយមុន ពីព្រោះយើងសួរគាត់។ ថាតើគាត់ត្រូវការពេលវេលាប៉ុន្មានទៀតមុននឹងយើងផ្តល់វេទិកាទៅភាគ -- ទៅមេធាវីពីរក្រុមទៀត។

[១៤:00:00]

**លោក ហ្សាស្តេ ប៉ោ៖**

ខ្ញុំនឹងប្រើពេលតិចជាងកន្លះម៉ោងទេ គឺថាដោយថាមេធាវីការពារក្តីលោក អៀង សារី មិនមានសំណួរទេ ហើយពួកគាត់អាចកែខ្ញុំប្រសិនបើគាត់បានប្តូរសម្តីនោះ ហើយឥឡូវនេះគឺមេធាវីការពារក្តីលោក ខៀវ សំផន គាត់បានក្រោកឈរ ដើម្បីស្នើយោបល់ ដូច្នេះ ឲ្យគាត់សម្តែងមតិបាទ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកស្រីមេធាវី!

**កញ្ញា អង់តា ហ្គីសសេ៖**

សូមអរគុណលោកប្រធាន។ ជម្រាបសួរអស់លោក លោកស្រីចៅក្រមជាទីគោរព! ខ្ញុំគ្រាន់តែចង់ជម្រាបដល់ភាគីទាំងអស់ថា ខ្ញុំពុំមានសំណួរចោទសួរទៅសាក្សីនេះទេ។ ដូច្នេះយើងមិនមានការលំបាកទាក់ទងនឹងពេលវេលានេះទេ។

[១៤:០០:៥២]

**ប្រធានអង្គជំនុំ៖**

អរគុណ។ ចុះក្រុមមេធាវីការពារក្ដីលោក អៀង សារី យ៉ាងម៉េចដែរ?

**លោក អាង ឧត្តម៖**

សូមគោរពលោកប្រធាន លោក លោកស្រីចៅក្រម។ សួស្ដីសហព្រះរាជអាជ្ញា សហភាគីទាំងអស់ រីឯក្រុមមេធាវីការពារក្ដីលោក អៀង សារី ក៏មិនមានសំណួរសួរសាក្សីនេះទេ។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

អរគុណ។ សូមអញ្ជើញលោកមេធាវីអាចបន្តការតាំងសំណួរបានហើយ!

**លោក ហ្សាស្តេី ប៉ោ៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោក ហ្សាស្តេី ប៉ោ៖**

**ស៖** ខ្ញុំចង់សួរសំណួរលោកមួយសំណួរ ដោយផ្អែកទៅលើទីតាំងពីរខុសគ្នា ដែលលោកនិងលោក គីម វុន ធ្វើការងារនៅទីតាំងទាំងពីរនោះខុសគ្នា។ លោកបាននិយាយថា "លោកបានធ្វើការនៅក្នុងអគារតូចមួយ នៅក្រៅអគារធំ។ ហើយលោក គីម វុន គាត់ធ្វើការងារនៅក្នុងអគារធំ ដែលនៅក្នុងអគារធំនោះក៏ នួន ជា គាត់ធ្វើការងាររបស់គាត់ផងដែរ"។

[១៤:០២:២៥]

តើក្នុងចំណោមលោកទាំងពីរនាក់នោះខាងណាដែលអាចមានលទ្ធភាពមើលឃើញអ្នក ដែលមកលេងក្រសួងនេះ តើលោក គីម វុន ដែលធ្វើការនៅអគារធំ ឬក៏លោកដែលធ្វើការនៅក្នុងអគារតូចដែលមានលទ្ធភាពមើលភ្ញៀវមកពីខាងក្រៅនោះបានប្រសើរជាង ដែលលោកថាអគារក្រសួងនេះនៅជិត

សាលាលីសេដេកាត?

**លោក ខេល លីសាក់៖**

*(គ្មានការបកប្រែ)*

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប! សូមអញ្ជើញតំណាងសហព្រះរាជអាជ្ញា!

**លោក ខេល លីសាក់៖**

ខ្ញុំអធ្យាស្រ័យដែលខ្ញុំក្រោកឈរឡើង។ ជាថ្មីម្តងទៀត មេធាវីសួរឲ្យសាក្សីទាយ ឬក៏ស្មាន។ មេធាវីគឺគាត់ហាក់ដូចជាមិនៗបានស្វែងយល់ឲ្យបានច្បាស់លាស់ទៅលើចម្លើយរបស់លោក គឹម វុន ដែលថាពេលដែលមានភ្ញៀវមកនោះ គឺគេមានការផ្ទេរទៅកាន់ផ្នែកមួយទៀតដែលនៅទីនោះគឺគេធ្វើការងារ។

[១៤:០៣:៤៧]

**លោក ហ្សាស្តើ ប៉ៅ៖**

ខ្ញុំគិតថា ខ្ញុំសូមឆ្លើយតបទៅនឹងការលើកឡើងថា ខ្ញុំនិយាយខុសទៅនឹងចម្លើយរបស់លោក គឹម វុន។ ខ្ញុំបានអានទៅលើប្រតិចារឹក គឹម វុន។ គឹម វុន គឺផ្អែកសក្ខីកម្មរបស់គាត់ទៅតាមអ្វីដែល គឹម វុន បានឃើញ។ នេះជាអ្វីដែលខ្ញុំបានអានតាមនុ៎ងទេ។ ខ្ញុំគ្រាន់តែប្រាប់សាក្សីនេះថា តើ គឹម វុន នុ៎ងគាត់បានឃើញអ្វីខ្លះ? ហើយ គឹម វុន នោះក៏មកផ្តល់ចម្លើយនៅចំពោះអង្គជំនុំ -- នៅចំពោះមុខអង្គជំនុំជម្រះផងដែរ។ ខ្ញុំសូមជម្រាបអង្គជំនុំជម្រះថា ខ្ញុំមិនបានសួរសាក្សីនេះឲ្យទាយស្មាន នូវអ្វីដែលគេ គឹម វុន ឃើញ និងដឹងនោះទេ។ ខ្ញុំគ្រាន់តែសួរសាក្សីនេះអំពីទីតាំងជាក់ស្តែងពិតប្រាកដរបស់ក្រសួង។ ខ្ញុំអត់មាននៅក្នុង -- នៅកន្លែងនោះទេ កាលពីមុននោះ។ ហើយខ្ញុំដឹងថា សាក្សីរូបនេះមកផ្តល់សក្ខីកម្មនៅទីនេះ ហើយវាអាចមានភាពងាយស្រួលឲ្យយើងអាចកំណត់ និងយល់ឃើញទាំងអស់គ្នា ថាតើមានអ្នកមកមើលក្រសួង មកទស្សនាក្រសួងដែរឬទេ? ហើយខ្ញុំចង់សួរថាតើ គឹម វុន នោះដែលគាត់អាចមើលឃើញច្បាស់ជាង ឬក៏សាក្សីរូបនេះដែលអាចមើលឃើញអ្នកដែលមកក្រសួងនេះច្បាស់ជាង ដែលសាក្សីបានឆ្លើយហើយថា ក្រសួងនេះគឺនៅជិត លីសេដេកាត ហើយសាក្សីនេះគឺគាត់គ្រាន់តែឆ្លើយទៅលើទីតាំងនេះតែប៉ុណ្ណោះ អ្វីដែលគាត់បានដឹង អ្វីដែលគាត់បានឃើញ។

[១៤:០៥:១៨]

**ប្រធានអង្គជំនុំ៖**

សាក្សីឆ្លើយតបទៅនឹងសំណួរចុងក្រោយនេះរបស់មេធាវី បើសិនជាលោកដឹង លោកមិនដឹងក៏មិនអីដែរ។ ឆ្លើយថាមិនដឹងទៅចប់ហើយ ទៅមុខទៀត។

**លោក ខៀវ អេន៖**

**ឆ៖** ខ្ញុំសូមឆ្លើយនូវសំណួរនេះ បើនិយាយពីការមើលឃើញទៅមុខអគារថាមានអ្នកណាចេញចូល ខ្ញុំគ្រាន់បញ្ជាក់ថា កន្លែងខ្ញុំធ្វើការហ្នឹងវាៗមិនមានលទ្ធភាពច្រើនជាងអ្នកធ្វើការនៅអគារធំទេ។ ព្រោះខ្ញុំនៅពីក្រោយអគារហើយ ខាងក្រោយខ្ញុំគឺថា មានតែបង្គួច ហើយមានផ្លូវ តែបញ្ជាក់ថា ពេលនោះគឺថា សុទ្ធតែផ្លូវបិទ បាទបិទ។ មានសងខាងគេមានអ្នកយាមជុំវិញសងខាងហ្នឹង គឺថាផ្លូវហ្នឹងមិនអាចចេញចូលបានទេ។ ដល់អ៊ីចឹងធ្វើការនៅពីក្រោយហ្នឹងគឺថាទិដ្ឋភាព ដែលចេញចូលពីមុខអគារមក ខ្ញុំអត់បានដឹងទេ ដល់អ៊ីចឹងក៏បញ្ជាក់ថា គឹម វុន ហ្នឹងគាត់មានលទ្ធភាពឃើញ និងងាយស្រួលជាងខ្ញុំច្រើន។ នេះសូមបញ្ជាក់ប៉ុណ្ណឹងបាទ។

**សួរដោយលោក ហ្សាស្តើ ប៉ៅ៖**

**ស៖** សូមអរគុណ ដែលលោកបានឆ្លើយបញ្ជាក់។ ខ្ញុំសង្កេតឃើញថា បទពិសោធន៍របស់លោកធ្វើការនៅក្រសួងឃោសនាការ ជាមួយនឹង យុន យ៉ាត គឺនៅពេលនោះ យុន យ៉ាត គាត់ទទួលបន្ទុកការងារក្រសួង ហើយគាត់មកទៅវិញទៅមក នៅពេលថ្ងៃ។ ដូច្នេះហើយ តើនេះគឺជាការសង្ខេបទៅលើអ្វីដែលខ្ញុំបានស្តាប់លើចម្លើយរបស់លោក ត្រឹមត្រូវដែរឬទេ?

**ឆ៖** ចម្លើយនេះ ជាការត្រឹមត្រូវហើយ។ ខ្ញុំយល់ស្រប។

[១៤:០៨:២៨]

**ស៖** លោកក៏បានឆ្លើយផងដែរថា នៅពេលមួយចំនួននោះគាត់ យុន យ៉ាត ហ្នឹងគឺ មកក្រសួងហ្នឹងមិនសូវជាញឹកញយនោះទេ ហើយនៅពេលដែលមកមិនញឹកញយនោះ គឺ នួន ជា មកជំនួសវិញ។ តើអ៊ីចឹងដែរឬទេ?

**ឆ៖** ចម្លើយនេះ វាជាការពិត។ ដោយខ្ញុំរស់នៅគឺថា ដំបូង យុន យ៉ាត ហ្នឹងក៏គាត់នៅមកហើយ នួន ជា មកហើយ យុន យ៉ាត ដូចថានៅបន្តមកបន្តិចទៀត ដល់ក្រោយមកឃើញបាត់លែងឃើញមក។ ដល់អ៊ីចឹង ខ្ញុំគ្រាន់តែឲ្យពេលវេលាវាមានបីដំណាក់អ៊ីចឹង ហើយការផ្ទេរផ្ទួរអីយ៉ាងម៉េចអាហ្នឹងខ្ញុំអត់យល់ដឹងទេ ហើយ យុន យ៉ាត ហ្នឹងនៅបន្តទៅទៀត ឬមិននៅ ខ្ញុំអត់ដឹងដែរ។ តែគ្រាន់ថា

ជាសកម្មភាព ដែលខ្ញុំរស់នៅកន្លែងហ្នឹង ខ្ញុំឃើញវាដំណើរអ៊ីចឹង។ នេះសូមផ្តល់ប៉ុណ្ណឹងបាទ។

[១៤:០៩:៥០]

**ស៖** លោកក៏បាននិយាយផងដែរថា លោកមិនដឹងទេថា គាត់ហ្នឹងស្ថិតនៅក្នុងរចនាសម្ព័ន្ធរបស់ក្រសួង ឬក៏អត់”។ តើលោកអាចដឹងតាមមធ្យោបាយណាផ្សេងថា យុន យ៉ាត នោះគឺជាគេកំណត់នៅក្នុងរចនាសម្ព័ន្ធក្រសួងហ្នឹង ពិតមែនដែរឬទេ? តើលោកអាចដឹងតាមរយៈផ្សេងដែរឬទេ?

**ឆ៖** ខ្ញុំសូមឆ្លើយថា ជាឯកសារ មានជាការឃើញ ការដឹងថា អ្នកនេះឈ្មោះលោកនេះត្រូវទទួលក្រសួងនេះ លោកនោះទទួលក្រសួងនោះ ខ្ញុំអត់ដឹងទេ អត់បានឃើញ។ ហើយការដែលៗបញ្ជាក់មកសេចក្តីថា យុន យ៉ាត ទទួលខាងណោះៗហ្នឹង គឺដោយសារថា ទិដ្ឋភាពទូទៅហ្នឹងវាឮអ៊ីចឹង ដល់ឮអ៊ីចឹងគ្រាន់តែដឹងថា យុន យ៉ាត គាត់ទទួលឯនោះ ហ៊ូ នឹម គាត់ទទួលខាងណោះ។ តែសួរថាមានក្រដាសស្នាមហ្នឹងបានមកខ្ញុំឃើញថា អូ៎ មានការតាំងចាត់រៀបរយអីខាងថ្នាក់លើអីយ៉ាងម៉េច ខ្ញុំអត់ដែលដឹងអត់ដែលឃើញ។ បាទ សូមមានមតិ។

[១៤:១១:២៤]

**ស៖** ដូច្នេះខ្ញុំអាចនិយាយថា គឹម វុន ឆ្លងតាមបទពិសោធន៍របស់គាត់នៅក្រសួងឃោសនាការនោះគឺ គឹម វុន នោះបានលើកឡើងថា យុន យ៉ាត នេះនៅធ្វើការគ្រប់គ្រងក្រសួងឃោសនាការរហូតទៅដល់ពេលវៀតណាមចូលមកក្នុងឆ្នាំ១៩៧៩។ ដូច្នេះនៅពេលដែលយើងពិចារណាទៅលើចម្លើយដែល គឹម វុន បានឆ្លើយនោះ តើវាដូចទៅនឹងអ្វីដែលលោកគិតដែរឬទេ ថាគឺអ៊ីចឹងមែន?

**លោក ខេល លីសាក់៖**

លោកប្រធាន!

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប!

សូមអញ្ជើញតំណាងសហព្រះរាជអាជ្ញា!

**លោក ខេល លីសាក់៖**

ជាថ្មីម្តងទៀត គឺមេធាវីឱ្យសាក្សីនេះផ្តល់យោបល់ ទៅលើចម្លើយរបស់សាក្សីផ្សេង។ សាក្សីបានឆ្លើយរួចមកហើយជាច្រើនលើកច្រើនសា នូវចំណេះដឹង និងការដឹងរបស់គាត់ទៅលើបញ្ហានេះ។

[១៤:១២:៣៣]

**លោក ហ្សាស្តើ ប៉ៅ៖**

លោកប្រធាន ប្រសិនបើអនុញ្ញាតសំណួរនេះ គឺខ្ញុំសួរបន្តទៅលើចម្លើយរបស់សាក្សី ដែលបានឆ្លើយថា គាត់មិនបានដឹងថាមានអ្វីកើតឡើងនៅក្នុងកម្រិតក្រសួងនោះទេ ហើយការរៀបចំនៅក្រសួងក៏គាត់មិនដឹងផងដែរ។ សាក្សីជាអ្នកឆ្លើយទៅលើចំណុចនេះ ដូច្នេះហើយខ្ញុំនេះគួរតែមានសិទ្ធិជជីកសួរទៅលើបញ្ហាហ្នឹងបន្ថែមទៀត។

[១៤:១២:៥៩]

*(ចៅក្រមពិភាក្សាគ្នា)*

[១៤:១៣:២៩]

**ប្រធានអង្គជំនុំ៖**

មេធាវីអាចតាំងសំណួរថ្មីទៀតទៅ ហើយសំណួរនេះគឺសំណួរដដែលៗទេ យើងឃើញស្តាប់ទៅដូចជាវិលវល់ដដែលៗ ទៅមុខទៅក្រោយៗ។ ដូចនេះទំនងជាអាចមិនចប់ទេនៅរសៀលនេះ ឬក៏ស្អែកទៀតទំនងជាមិនចប់ទេ ប្រសិនជាតាំងសំណួរបែបនេះ។

**លោក ហ្សាស្តើ ប៉ៅ៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោក ហ្សាស្តើ ប៉ៅ៖**

**ស៖** តើលោកដឹងដែរឬទេ ថាតើ យុន យ៉ាត នេះគាត់ទៅធ្វើការអ្វីផ្សេងទៀតក្រោយខែមករា ឆ្នាំ១៩៧៩ នោះ?

**លោក ខៀវ អេន៖**

**ឆ៖** សំណួរនេះជាសំណួរមួយ ដែលសួរក្រោយ៧៩--

[១៤:១៤:៣១]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណសាក្សី ហើយសាក្សីមិនបាច់ឆ្លើយតប នេះសំណួរក្រៅអង្គហេតុទេ។

**លោក ហ្សាស្តើ ប៉ៅ៖**

លោកប្រធាន ខ្ញុំសូមស្នើសុំឱ្យលោកប្រធានពិចារណាចំណុចនេះឡើងវិញ ដោយសារតែនេះវាអាចជាករណីដែលថា យុន យ៉ាត នៅតែបន្តទៅលើការផ្សព្វផ្សាយនៅក្នុងវិស័យអប់រំនេះ ដែលនេះ

ជាកាលៈទេសៈមួយវាអាចពាក់ព័ន្ធ។ ដូច្នេះ ខ្ញុំសូមស្នើថា វាពាក់ព័ន្ធទៅលើអង្គហេតុ។

**ប្រធានអង្គជំនុំ៖**

សំណួរនេះ ក្រៅអង្គហេតុ មិនពាក់ព័ន្ធនឹងអង្គហេតុចោទប្រកាន់លើជនជាប់ចោទ។ សាក្សីមិនបាច់ឆ្លើយតបទេ!

**លោក ហ្សាស្តេ ប៉ោ៖**

លោកប្រធាន ដើម្បីឲ្យខ្ញុំយល់ច្បាស់ទៅលើសេចក្តីសម្រេចរបស់លោកប្រធាន គឺខ្ញុំនេះមិនមានសិទ្ធិក្នុងការសួរដើម្បីឲ្យសាក្សីបង្ហាញថា តើ យុន យ៉ាត នោះពិតជានៅបន្តការងាររបស់ខ្លួន គ្រប់គ្រងក្រសួងនេះក្រោយពីឆ្នាំ១៩៧៥ -- ៧៩ តមកទៀត ឬក៏យ៉ាងម៉េចលោកប្រធាន?

[១៤:១៦:២១]

**ប្រធានអង្គជំនុំ៖**

យើងអត់ឲ្យសួរទេ ព្រោះអំមិញយើងប្រាប់ហើយ យើងសម្រេចមិនឲ្យសួរ។ ព្រោះអង្គជំនុំជម្រះមានសិទ្ធិដកចេញនូវកិច្ចដំណើរការនីតិវិធីណាដែល វាឥតប្រយោជន៍ឈានទៅដល់ការស្វែងរកការពិតនៃរឿងក្តី ដើម្បីពន្លឿនកិច្ចដំណើរការនីតិវិធីសវនាការឲ្យមានប្រសិទ្ធភាព ហើយនិងឆាប់រហ័សតាមដែលអាចធ្វើទៅបាន។ នេះជាសមត្ថកិច្ចដែលវិធានផ្ទៃក្នុងកំណត់ឲ្យការដឹកនាំសវនាការប្រព្រឹត្តទៅបានឆាប់រហ័ស និងមានប្រសិទ្ធភាពដោយឲ្យដកចេញនូវកិច្ចសួរដេញដោលណាដែលវាមិននាំឲ្យស្វែងរកការពិត។ នៅក្នុងនោះ គឺមានទាំងសំណួរដែលមិនពាក់ព័ន្ធ សំណួរក្រៅអង្គហេតុ សំណួរផ្សេងទៀតដែលយើងបានយើងប្រាប់ជម្រាបជូនភាគី រួចជាច្រើនរួចមកហើយ។

[១៤:១៧:២៨]

**លោក ហ្សាស្តេ ប៉ោ៖**

លោក ខៀវ អេន ខ្ញុំនឹងមានសំណួរបន្ថែមចង់សួរលោកទៀត ក៏ប៉ុន្តែខ្ញុំមិនអាចសួរបាននោះទេត្រង់ចំណុចទាំងអស់នេះ។ ដូច្នេះ ខ្ញុំសូមលើកឡើងដើម្បីកត់ជាប្រតិចារឹកថា ប្រសិនបើបញ្ហាចម្រូងចម្រាសដែលថា យុន យ៉ាត នៅតែបន្តគ្រប់គ្រងក្រសួងឃោសនាការនេះដដែល។ អង្គហេតុនេះគឺវាពាក់ព័ន្ធ ដោយសារតែ យុន យ៉ាត នេះក៏នៅតែគ្រប់គ្រងការងារនេះដដែលក្នុងក្រសួងក្រោយឆ្នាំ១៩៧៩។

ដូច្នេះខ្ញុំសូមធ្វើការបញ្ចប់ការតាំងសំណួររបស់ខ្ញុំ។ ហើយខ្ញុំ ក៏សូមបញ្ជាក់នៅក្នុងប្រតិចារឹកផង

ដែរថា ខ្ញុំមិនត្រូវបានអនុញ្ញាតឲ្យជជីកទៅលើបញ្ហាមួយចំនួនដែលវាពាក់ព័ន្ធទៅនឹងចម្លើយរបស់លោក គឹម វុន ទៅតាមអ្វីដែលលោកដឹង។ ក៏ប៉ុន្តែយ៉ាងណាក៏ដោយ គឺខ្ញុំសូមថ្លែងអំណរគុណចំពោះកិច្ចសហការរបស់លោក។ វាពិតជាមានប្រយោជន៍ដល់យើងខ្ញុំណាស់។ ហើយយើងខ្ញុំជូនពរលោកឲ្យធ្វើដំណើរត្រឡប់ទៅគេហដ្ឋានវិញ ដោយសុវត្ថិភាព និងសំណាងល្អ។

ក្នុងនាមក្រុមរបស់យើងខ្ញុំនេះ គឺខ្ញុំសូមថ្លែងអំណរគុណលោក។

[១៤:១៩:១២]

*(ចៅក្រមពិភាក្សាគ្នា)*

[១៤:២១:០៩]

**ប្រធានអង្គជំនុំ៖**

លោក ខៀវ អេន ការស្តាប់សក្ខីកម្មរបស់លោករហូតដល់ពេលនេះបានចប់ហើយ ហើយវត្តមានរបស់លោកនៅ អ.វ.ត.ក នេះលេងមានភាពចាំបាច់ទៀតហើយ។ លោកអាចវិលត្រឡប់ទៅលំនៅដ្ឋានរបស់លោក ឬក៏គោលដៅណាដែលលោកមានបំណងចង់ទៅបានហើយ។

អង្គជំនុំជម្រះសូមអរគុណ ដែលលោកបានបញ្ជើញមកផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះរយៈពេល២ថ្ងៃនេះ ហើយប្រកបដោយភាពអត់ធ្មត់ និងខិតខំអស់ពីសមត្ថភាព។ សក្ខីកម្មរបស់លោកនឹងអាចរួមវិភាគទានក្នុងការស្វែងរកការពិតនៃរឿងក្តីនេះ។ ហើយសូមលោក ខៀវ អេន ជួបតែសំណាងល្អ និងធ្វើដំណើរវិលត្រឡប់ទៅវិញប្រកបដោយសុវត្ថិភាព។

[១៤:២២:០៧]

ហើយមន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលជាមួយនឹងមន្ត្រីគាំពារសាក្សី និងអ្នកជំនាញក្នុងការជូនសាក្សីរូបនេះវិលត្រឡប់ទៅកាន់លំនៅដ្ឋានរបស់គាត់ ឬកន្លែងដែលគោលដៅដែលគាត់មានបំណងទៅវិញបានហើយ។ ហើយដូចគ្នាដែរ គឺសាក្សីបម្រុងសម្រាប់ថ្ងៃនេះដែលមានរហស្សនាម TCW-428 ហ្នឹងក៏បញ្ជូនគាត់វិលត្រឡប់ទៅកន្លែងដែលគាត់ស្នាក់នៅវិញ ហើយនិងឲ្យអញ្ជើញគាត់ត្រឡប់មកកាន់កន្លែងរង់ចាំនៅអគារនៃ អ.វ.ត.ក នៅព្រឹកថ្ងៃស្អែកនៅវេលាម៉ោងប្រាំបួន។

ហើយអង្គជំនុំជម្រះសូមជម្រាបថា សវនាការបន្តទៀតនេះ អង្គជំនុំជម្រះនឹងស្តាប់នូវសេចក្តីទាញហេតុផលពីភាគីពាក់ព័ន្ធនឹងបញ្ហាសុខភាពរបស់លោក អៀង សារី ដែលបាននឹងកំពុងទទួលសម្រាកទទួលការព្យាបាលនៅឯផ្នែកសង្គ្រោះបន្ទាន់នៃមន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត ហើយនិងបញ្ហា

ការរៀបចំកិច្ចដំណើរការសវនាការពីនេះទៅមុខ ដើម្បីយើងជជែកពិភាក្សារកដំណោះស្រាយថាតើគួរត្រូវបាន ត្រូវរៀបចំយ៉ាងដូចម្ដេចទៅ ប្រសិនបើស្ថានភាពនេះកំពុងតែប្រឈមរបៀបនេះ ដូចអ្វីដែលលោកស្រីចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍ បានបញ្ជាក់ជូនភាគីរួចហើយកាលពីរសៀលម្សិលមិញ។

អ៊ីចឹងគឺឥឡូវនេះ លោក ខៀវ អេន អាចចេញទៅបានហើយ ហើយអង្គជំនុំជម្រះប្រកាសសម្រាកត្រឹមនេះរហូតដល់ម៉ោងបី សូមអញ្ជើញចូលវិញដើម្បីបន្តកិច្ចដំណើរការ ហើយសវនាការចាប់ពីម៉ោងបីទៅ ដូចយើងបានជម្រាបជូនភាគីអម្បាញ់មិញនេះ។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១៤:២៣នាទី ដល់ម៉ោង១៥:០១ នាទី)*

[១៥:០១:០៧]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ ហើយសវនាការនេះ គឺអង្គជំនុំជម្រះនឹងស្ដាប់នូវមតិយោបល់របស់គូភាគី ពាក់ព័ន្ធទៅនឹងវិធីសាស្ត្រនៃការធ្វើសវនាការទៅថ្ងៃមុខ ដោយហេតុផលពាក់ព័ន្ធទៅនឹងស្ថានភាពបច្ចុប្បន្ននៃបញ្ហាសុខភាពរបស់លោក អៀង សារី ដែលកំពុងតែមានជំងឺ។ ហើយកំពុងតែសម្រាកព្យាបាលនៅឯមន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត ផ្នែកសង្គ្រោះបន្ទាន់ ហើយនេះគឺផ្អែកតាមរបាយការណ៍របស់លោកគ្រូពេទ្យដែលទទួលបន្ទុកពិនិត្យព្យាបាលជំងឺរបស់លោក អៀង សារី កាលពីសវនាការថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០១២ ហើយនិងរបាយការណ៍ថ្មីអំពីការព្យាបាលលោក អៀង សារី ដែលកំពុងសម្រាកព្យាបាលផ្នែកសង្គ្រោះបន្ទាន់នៃមន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត លេខ ៦៥២មមខស ចុះថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០១២។ នេះគឺជាគោលបំណងនៃកិច្ចដំណើរការសវនាការនេះ។ ហើយប្រសិនបើមានពេលវេលាសមស្របនោះ អង្គជំនុំជម្រះនឹងបន្តដោយសវនាការមួយទៀត គឺចាប់ផ្ដើមស្ដាប់នៅការអាននូវបណ្ដាកថាខណ្ឌមួយចំនួនដែលនៅសេសសល់នៅក្នុងសំណុំរឿង០០២/០១ ដែលទៅអនាគតយើងនឹងកំណត់ថា ជាសវនាការវគ្គ៣ នៅក្នុងសំណុំរឿង០០២/០១ ដើម្បីជម្រាបជូន

ដល់ភាគីនិងសាធារណជនបានជ្រាប មុននឹងយើងចាប់ផ្តើមចូលទៅការសួរដេញដោលចំពោះសាក្សីមួយចំនួនដែលពាក់ព័ន្ធនឹងអង្គហេតុនេះ។ ហើយដែលមេធាវី អ៎! ដែលលោក អៀង សារី តាមរយៈមេធាវីរបស់គាត់ហ្នឹងបានបង្ហាញជំហរថា គាត់នឹងលះបង់នូវការចូលរួមដោយផ្ទាល់នៅក្នុងកិច្ចដំណើរការស្តាប់សក្ខីកម្មសាក្សីមួយចំនួន។ បាទ នេះជាគោលបំណងនៃការរៀបចំសវនាការនៅពេលនេះ។ ហើយក៏សូមសួរផងដែរថា លោកមេធាវី ក្រុមមេធាវីការពារក្តី ហើយជាពិសេសលោកក្រុមមេធាវីការពារក្តីលោក អៀង សារី ត្រូវការពេលវេលាប៉ុន្មានដែរ ក្នុងការបង្ហាញនូវគំនិតយោបល់លើបញ្ហានេះ?

[១៥:០៣:៥៥]

**លោក ម៉ៃខល កាណាវ៉ាស៖**

សូមអរគុណលោកប្រធាន។ ខ្ញុំគិតថាយើងនឹងនិយាយអំពីបញ្ហានីតិវិធី កិច្ចដំណើរការនីតិវិធីនៅក្នុងថ្ងៃនេះ។ ដូច្នេះ ខ្ញុំហាក់ដូចជាមិនយល់ឲ្យច្បាស់លាស់សោះទៅលើបញ្ហានេះ។ ខ្ញុំ គឺត្រូវការតែ៥នាទីទេ ហើយប្រហែលជាអាចមិនដល់៥នាទីទេ ដើម្បីលើកឡើងអំពីបញ្ហាហ្នឹង។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ បញ្ហាហ្នឹងគឺលោកស្រី ស៊ីលវៀ ខាតវ៉ាយច៍ ក្នុងនាមអង្គជំនុំជម្រះបានជម្រាបជូនភាគីកាលពីម្សិលមិញរួចហើយ កាលពីរសៀលម្សិលមិញចុងម៉ោងនៃម៉ោងធ្វើការ ហើយយើងបានជម្រាប -- គាត់បានជម្រាបជូនរួចហើយ ដោយមានការប្រគល់ភារកិច្ចពីខ្ញុំ ជាប្រធានអង្គជំនុំជម្រះជូនទៅគាត់ដើម្បីជម្រាបជូនភាគីឲ្យត្រៀមលក្ខណៈក្នុងការផ្តល់នូវមតិយោបល់លើបញ្ហានេះ។ ហើយឥឡូវនេះបញ្ហានេះយើងមានពេល មានឱកាសយើងក៏ចាប់ផ្តើមធ្វើបញ្ហានេះតែម្តង។ ហើយដើម្បីឲ្យកាន់តែច្បាស់លាស់ទៀត គឺអង្គជំនុំជម្រះសូម -- ខ្ញុំសូមផ្តល់វេទិកាជូនទៅលោកស្រី ស៊ីលវៀ ខាតវ៉ាយច៍ ដើម្បីបញ្ជាក់បញ្ហានេះបន្ថែមទៀត។ ដើម្បីមុននឹងលោកលើកឡើងនូវមតិយោបល់របស់លោក ពាក់ព័ន្ធនឹងបញ្ហាដែលខ្ញុំបានលើកឡើងអម្បាញ់មិញនេះ។

សូមអញ្ជើញលោកស្រីចៅក្រម!

[១៥:០៥:១១]

**ចៅក្រម ស៊ីលវៀ ខាតវ៉ាយច៍៖**

សូមអរគុណលោកប្រធាន។ ដើម្បីបញ្ជាក់ឡើងវិញ និងបន្ថែមទៅលើអ្វី ដែលអង្គជំនុំជម្រះតាមរយៈខ្ញុំបានលើកឡើងកាលពីម្សិលមិញ។ អង្គជំនុំជម្រះសាលាដំបូង រំពឹង និងសង្ឃឹមថា នឹងមាន

ការពន្យារកិច្ចដំណើរការនីតិវិធីរបស់យើងយូរ រហូតទៅដល់ស្ថានភាពសុខភាពរបស់លោក អៀង សារី នេះបញ្ជាក់បំភ្លឺឲ្យយើងបានយល់ ឲ្យបានច្បាស់លាស់។

កាលពីម្សិលមិញ អង្គជំនុំជម្រះជម្រះបានស្នើសុំយោបល់ មតិយោបល់របស់លោក ខាំប៊ែល ដែលជាអ្នកវិភាគ និងអ្នកជំនាញឯករាជ្យ ធ្វើការពិនិត្យសុខភាពលោក អៀង សារី មុនពេលដែលគាត់មានស្ថានភាពសុខភាពនេះ។ យើងខ្ញុំបានបញ្ជូនរបាយការណ៍សុខភាព ដែលបានស្នេននេះ ពាក់ព័ន្ធទៅនឹងបញ្ហាសុខភាពនេះ បញ្ជូនទៅលោក ខាំប៊ែល ហើយផ្តល់ព័ត៌មានថ្មីៗទៅដល់អ្នកជំនាញ។ ហើយយើងសង្ឃឹមថា យើងនឹងទទួលបាននូវសញ្ញាបញ្ជាក់ ឬក៏ការបង្ហាញមួយចំនួនពីលោក ខាំប៊ែល ក្នុងពេលឆាប់ៗនេះ អំពីវិធានការដែលយើងត្រូវធ្វើ -- អង្គជំនុំជម្រះត្រូវធ្វើឡើង។

ដូច្នេះ យើងខ្ញុំក៏ចង់បានដឹង អំពីបញ្ហាបុរេវិនិច្ឆ័យរោគ និងបញ្ហាវិនិច្ឆ័យរោគ ទៅលើលោក អៀង សារី។ យើងដឹងហើយថា យើងនឹងមានការពន្យារនីតិវិធីរបស់យើង ប្រសិនបើយើងមិនយល់ច្បាស់ និងមិនមានព័ត៌មានច្បាស់ទៅលើបញ្ហានេះ។ អ្វីដែលយើងចង់បាននៅថ្ងៃនេះ ពីក្រុមមេធាវីការពារក្តី និងភាគី ថាតើយើងគួរដំណើរការដោយរបៀបណា ក្នុងរយៈពេលនេះ ក្នុងពេលដែលយើងចង់ឲ្យមាន -- កំពុងរង់ចាំការធ្វើរោគបុរេវិនិច្ឆ័យរោគនេះ និងការធ្វើវិនិច្ឆ័យរោគពីវេជ្ជបណ្ឌិត។ យើងដឹងហើយថា លោក អៀង សារី បានបោះបង់សិទ្ធិមិនមានវត្តមានចំពោះសាក្សីមួយចំនួន។ ក្រោយពីពិភាក្សាជាមួយនឹងខាងសហព្រះរាជអាជ្ញា និងមេធាវីការពារក្តី ជាពិសេសចំពោះក្រុមសាក្សី ដែលនឹងមកផ្តល់សក្ខីកម្មនាពេលក្រោយនេះ គឺយើងខ្ញុំសូមបញ្ជាក់ថា អង្គជំនុំជម្រះសាលាដំបូង ត្រូវកំណត់ថាតើត្រូវស្តាប់សាក្សីណាមួយ។

[១៥:០៧:៤៨]

ហើយពេលខ្លះទៅវាមិនមានគុណប្រយោជន៍ក្នុងការបញ្ជាក់ថាតើ ផ្នែក អង្គហេតុណាមួយដែលពាក់ព័ន្ធទៅនឹងសាក្សី យើងគួរស្តាប់ និងផ្នែកណាដែលយើងមិនគួរស្តាប់។ ដូច្នេះហើយយើងខ្ញុំសូមចង់ស្តាប់ឮទៅលើមតិយោបល់មួយចំនួនទៅលើបញ្ហានេះ។ ជាពិសេស ពាក់ព័ន្ធទៅនឹងបញ្ហាទាក់ទងនឹងឯកសារដែលនឹងលើកឡើងផងដែរ។ ហើយនិងយើងចង់ដឹងអំពីរបៀបថាតើយើងគួរដំណើរការនីតិវិធីរបស់យើងដោយរបៀបណា។ នេះគឺជាការរៀបចំ ដើម្បីឲ្យយើងអាចរៀបចំកាលវិភាគសវនាការរបស់យើងកុំឲ្យមានការពន្យារពេលតែប៉ុណ្ណោះ។ ក្រោយពីយើងស្តាប់ទៅ គឺយើងនឹងធ្វើការរៀបចំក្រុមសាក្សីឡើងវិញសម្រាប់មកផ្តល់ចម្លើយ។ ដូច្នេះលោក ប្រធានប្រហែលជាចង់ឲ្យខាងភាគីមេធាវីតែម្នាក់ទេ

ក្នុងមួយក្រុម គឺលើកឡើងទៅលើចំណុចនេះ។

**លោក ម៉ៃខល កាណាវាស៖**

សូមអរគុណលោកប្រធាន លោកស្រីចៅក្រម។ ជាការពិត គឺខ្ញុំនឹងលើកឡើងក្នុងនាមក្រុមមេធាវីការពារក្តីតែម្នាក់តែប៉ុណ្ណោះ។ នៅក្នុងថ្ងៃនេះ គឺយើងបានដាក់ឈ្មោះ១៥នាក់ ឈ្មោះសាក្សីដែលក្នុងនោះ ថាតើសាក្សីណាដែលនឹងមកផ្តល់សក្ខីកម្មតាមលំដាប់លំដោយបែបណា គឺយើងបានដាក់ជូនរួចមកហើយ។ សាក្សីមួយចំនួន ដែលយើងបានឯកភាពនោះ គឺលោក អៀង សារី គឺគាត់បានឯកភាព យើងមិនឯកភាពជំនួសគាត់នោះទេ គឺយើងឃើញមានសាក្សី ២០នាក់នៅក្នុងនោះ។

[១៥:០៩:៣៣]

យើងខ្ញុំកត់សម្គាល់ឃើញថា វាអាចមានហេតុការណ៍ខ្លះ ដែលលោក អៀង សារី គាត់បោះបង់សិទ្ធិពេលខ្លះទៅ គឺគាត់មិនបានបោះបង់សិទ្ធិ តាមរយៈលិខិតបោះបង់សិទ្ធិនេះ។ ខ្ញុំក៏បានមានឱកាសនិយាយជាមួយនឹងសហព្រះរាជអាជ្ញាផងដែរ យើងនឹងស្តាប់ឮច្រើនការលើកឡើងរបស់គាត់ផងដែរ នូវវិធីដែលយើងអាចដំណើរការទៅមុខបាន។ ការព្រួយបារម្ភចម្បងរបស់ខ្ញុំនោះគឺ នៅពេលដែលយើងឯកភាពទៅលើសាក្សីណាមួយនោះ គឺយើងត្រូវមើលព័ត៌មានដែលមានស្រាប់លេចចេញពីសាក្សីនេះ។ ឯកសារទាំងឡាយ ដែលនឹងបង្ហាញជូនទៅកាន់សាក្សីនៅក្នុងសំណុំរឿង។ ដូច្នេះនៅពេលដែលបញ្ហាណាមួយលេចឡើងដោយមិនរំពឹងទុកនោះ គឺវាអាចជាករណីសម្រាប់យើង។ គឺខ្ញុំត្រូវផ្តល់ការណែ -- គឺតាមរយៈកូនក្តីរបស់ខ្ញុំនេះ គឺគាត់បានណែនាំយើងខ្ញុំ ហើយតាមរយៈលិខិតបោះបង់សិទ្ធិនោះ គឺយើងខ្ញុំត្រូវធ្វើតំណាងការពារក្តីគាត់ មិនមែនថាមិនពិគ្រោះយោបល់ជាមួយកូនក្តីរបស់យើងខ្ញុំនោះទេ។ ដូច្នេះ វាអាចបញ្ហាទាំងអស់នេះកើតឡើង។

[១៥:១០:៣៦]

ករណីមួយចំនួនទៀតដែលអាចលោក អៀង សារី ឈ្មោះរបស់គាត់អាចពាក់ព័ន្ធ ហើយនិងលើកឡើង។ ដូច្នេះហើយទាំងអស់នេះ ដែលយើងអាចនឹងថាកើតឡើង។ សហព្រះរាជអាជ្ញានឹងលើកឡើងចំណុចនេះឲ្យបានជាក់លាក់ ក្រោយពីយើងពីបានពិភាក្សាជជែកគ្នា។ យើងបានធ្វើការគិតគូរអំពីចំណុចទាំងអស់នេះ ហើយសហព្រះរាជអាជ្ញា គឺបានបញ្ជាក់ហើយថា យើងអាចកោះហៅសាក្សីហ្នឹងមកវិញបាន ប្រសិនបើមានករណីនេះ។ ចំណុចនេះគឺវាមិនអីទេសម្រាប់យើង ប្រសិនបើអ៊ីចឹង។

ពាក់ព័ន្ធទៅនឹងបញ្ហាឯកសារវិញ យើងបានពិគ្រោះយោបល់ជាមួយនឹងលោក អៀង សារី គឺ

គាត់បានសិទ្ធិអំណាច សិទ្ធិឲ្យយើងបន្តធ្វើការទៅលើបញ្ហាឯកសារនេះ។ ចំពោះផែនការរៀបចំរបស់យើង គឺយើងមិនគួរមានការពន្យារពេលនីតិវិធីរបស់យើងទេ ក្នុងរយៈពេលប៉ុន្មានខែនេះ។ យើងដឹងហើយថាលោក អៀង សារី បានចូលសម្រាកនៅក្នុងមន្ទីរពេទ្យ ហើយយើងធ្វើយ៉ាងណាគឺឲ្យគាត់ហ្នឹងមានភាពងាយស្រួលសម្រាប់នីតិវិធី និងការងាររបស់គាត់។ យើងដឹងហើយម្សិលមិញ គឺលោក អាង ឧត្តម បានចាកចេញទៅមុនបន្តិច ដើម្បីទៅយកលិខិតលះបង់សិទ្ធិរបស់កូនក្តីរបស់យើងខ្ញុំ។ យើងខ្ញុំសូមអធ្យាស្រ័យ និងការយោគយល់ទៅលើបញ្ហានេះ។ យើងខ្ញុំព្យាយាមធ្វើយ៉ាងណាកុំឲ្យមានការពន្យារនីតិវិធី។ យើងមានការងារច្រើនណាស់ដែលយើងត្រូវចាត់ចែង និងដោះស្រាយ ហើយនិងមិនចង់ឲ្យមានការពន្យារនោះទេ។ សូមអរគុណ។

[១៥:១២:១៥]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណលោកមេធាវី។ ចុះក្រុមមេធាវីពីរក្រុមទៀត តើមាន -- មេធាវីការពារក្តីពីរក្រុមទៀត តើមានមតិយោបល់អ្វីដែរទេ លើបញ្ហានេះ?

សូមអញ្ជើញបាទ!

**កញ្ញា អង់តា ហ្គីសសេះ**

អរគុណលោកប្រធាន។ ដោយសង្ខេប ចៅក្រម ខាតវ៉ាយថ៍ បានកត់សម្គាល់ថា -- កាលពីម្សិលមិញយើងទាក់ទងជាមួយនឹងក្រុម អៀង សារី នៅពេលដែលគាត់បានជម្រាបថា មានឯកសារដែលបង្ហាញដោយសហព្រះរាជអាជ្ញា ដែលចោទប្រកាន់ទៅលើកូនក្តីរបស់គាត់។ ដូច្នេះ វាជាការធម្មតាទេ ដែល – ខ្ញុំរកពាក្យមិនឃើញជាភាសាបារាំង– មានការ ដូចជាការ-- ដូច្នេះជនជាប់ចោទនីមួយៗនោះត្រូវតែមានសិទ្ធិនៅក្នុងសាលសវនាការដើម្បីការពារខ្លួនរបស់គាត់។ ដូច្នេះដើម្បី ហើយដើម្បីជួយដល់មេធាវីរបស់ខ្លួនក្នុងការត្រៀមលក្ខណៈប្រឈមនឹងការចោទសំណួរ។ ក៏ប៉ុន្តែទន្ទឹមនឹងនោះថាលោក អៀង សារី នោះខ្លួនឯងផ្ទាល់នោះ គាត់នឹងដឹងថាពេលណាគាត់មិនអាចមានវត្តមាននៅទីនេះ ចំពោះសាក្សីណាមួយ ហើយនៅពេលដែលធ្វើយ៉ាងដូច្នេះហើយ ក្នុងលក្ខខណ្ឌនេះខ្ញុំគាំទ្រក្រុមមេធាវីលោក អៀង សារី។

[១៥:១៣:៥៣]

យើងធ្លាប់បាននិយាយអំពីបញ្ហាមួយស្រដៀងគ្នានេះដែរ គឺថាយើងជាមេធាវីរបស់មេធាវីការពារ

ក្តី ហើយក៏យើងថ្ងៃណាមួយនោះ គឺថាយើងនឹងជួបប្រទះនឹងស្ថានភាពដូចក្រុម អៀង សារី នេះដែរ។ ដូច្នេះគឺថាយើងត្រូវគោលការណ៍សំខាន់ៗមួយចំនួន យើងត្រូវអនុវត្តគោលការណ៍ទាំងអស់នេះ។

ចំណុចដែលយើងត្រូវតែលើកឡើងនោះ នៅថ្ងៃនេះ គឺថាខ្ញុំសូមរំឭកថា នៅក្នុងចម្លើយតបទៅនឹងសហព្រះរាជអាជ្ញាទាក់ទងទៅនឹងការសម្ភាសជាមួយនឹងសាក្សី 428 គឺចម្លើយរបស់យើង គឺថា E233/2 គឺយើងជំទាស់ទៅនឹងការបញ្ចូលឯកសារភស្តុតាងនេះ។ ពីព្រោះថាបើធ្វើការបង្ហាញយឺតយ៉ាវរបស់សហព្រះរាជអាជ្ញា។

ក្រុម អៀង សារី ថាក្នុងករណីដែលថា មិនបាន -- មិនប្រើទាក់ទងនឹងកូនរបស់គាត់ទេ គឺថាមិនបញ្ហាអីទេក្នុងការស្តាប់ចម្លើយសាក្សីនេះ។ ក៏ប៉ុន្តែទោះយ៉ាងណាក្តី ចម្លើយរបស់យើងនៅក្នុងឯកសារ 233/2 នេះគឺថានៅដដែលទេ ទាក់ទងនឹងការបង្ហាញឯកសារនេះយឺត គឺថាទាក់ទងសាក្សីនេះ។ អ៊ីចឹងសូមបំភ្លឺត្រង់ចំណុចនេះ ហើយសូមឲ្យមានការកត់ត្រាទុកនៅក្នុងសវនាការយើងនេះ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ចុះក្រុមមេធាវីការពារក្តីលោក នួន ជា?

**លោក ហ្សាស្តេី ប៉ោះ៖**

សូមអរគុណលោកប្រធាន។ យើងខ្ញុំមានចំណុចខ្លីនោះទេ យើងគាំទ្រទឡ្ហីករណ៍របស់ក្រុមមេធាវី អៀង សារី។ ខ្ញុំមិនមានអ្វីត្រូវបន្ថែមនោះទេ ប៉ុន្តែប្រហែលជាអាចលើកឡើងក្រោយពេលដែលសហព្រះរាជអាជ្ញា គាត់បានលើកឡើងនូវជំហររបស់ខ្លួន។ ហើយនៅពេលនេះ គឺខ្ញុំមិនមានទេ លោកប្រធាន។

[១៥:១៥:៥៧]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ជាបន្ត អង្គជំនុំជម្រះសូមផ្តល់វេទិកាជូនទៅតំណាងសហព្រះរាជអាជ្ញា។ តើមានមតិយោបល់អ្វីដែរទេ លើបញ្ហាដែលអង្គជំនុំជម្រះបានកំណត់ក្នុងការពិភាក្សានាពេលនេះ។ សូមអញ្ជើញ!

**លោក វីណ្សៀម ស្មីត៖**

សូមអរគុណលោកប្រធាន លោក លោកស្រីចៅក្រុម មេធាវី ភាគីទាំងអស់នៅចំពោះមុខអង្គជំនុំជម្រះ។ ខ្ញុំគិតថា បញ្ហានៃការពន្យារពេលយូរនេះ គឺជាបញ្ហាមួយព្រួយបារម្ភពីខាងតំណាងសហព្រះ

រាជអាជ្ញា ភាគីទាំងអស់ និងអង្គជំនុំជម្រះ។

ជាការពិត ចៅក្រម ខាតវ៉ាយថ៌ គឺលើកឡើងយ៉ាងត្រឹមត្រូវកាលពីសប្តាហ៍មុន។ ស្ថានភាពនេះ គឺបានបង្ហាញឲ្យយើងឃើញទាំងអស់គ្នា តែយើងឃើញថានៅពេលអនាគតខាងមុខខ្លីនេះ គឺថានឹងអាចមានការពន្យារពេលយូរប្រសិនបើសុខភាពរបស់លោក អៀង សារី មិនធូរស្រាលនោះទេ។ ហើយក្នុងពេលជាមួយគ្នានេះ គឺវាក៏ពាក់ព័ន្ធទៅនឹងថាការយល់ឃើញរបស់លោក អៀង សារី យ៉ាងម៉េចដែរ ទៅលើបញ្ហានៃការស្តាប់ចម្លើយ និងភស្តុតាង។ ជាពិសេស និងការស្តាប់សាក្សីមួយចំនួនបើសិនជាមិនមានការបោះបង់សិទ្ធិពីគាត់។ ស្ថានភាពរវាងសប្តាហ៍មុន និងសប្តាហ៍នេះមានការប្រែប្រួល។

យើងខ្ញុំលើកសំណើដាក់ជូនអង្គជំនុំជម្រះ និងមេធាវីការពារក្តីនូវសាក្សីមួយចំនួន ប្រសិនបើទទួលយកនោះ ពាក់ព័ន្ធទៅនឹងសាក្សីមួយចំនួនស្តីអំពីការជម្លៀសដំណាក់កាលទី១ និងដំណាក់កាលទី២។ ហើយប្រសិនបើមានការបោះបង់សិទ្ធិនោះ គឺយើងអាចដំណើរការទៅមុខបាន។ នៅក្នុងពេលនោះ គឺថាយើងនឹងឲ្យភស្តុតាងហ្នឹងបង្ហាញឲ្យយើងឃើញទាំងអស់គ្នា។ ហើយនៅពេលដែលលោកយើងបានយល់ច្បាស់អំពីការធ្វើរោគវិនិច្ឆ័យជាមុនទៅលើលោក អៀង សារី ហើយវាអាចពាក់ព័ន្ធ។ ដូច្នេះហើយ គឺយើងខ្ញុំគិតថាចំណុចនេះ គឺមាននៅចំពោះមុខអង្គជំនុំជម្រះ។

[១៥:១៨:០៦]

ហេតុផលទាំងឡាយពាក់ព័ន្ធទៅនឹងសុខភាពរបស់លោក អៀង សារី ដូចដែលអង្គជំនុំជម្រះបានបញ្ជាក់ និងណែនាំរួចមកហើយ វាសំខាន់ណាស់ដែលអ្នកដែលមានជំនាញត្រូវតែផ្តល់ជាមតិយោបល់ទៅលើបញ្ហាសុខភាពរបស់លោក អៀង សារី ថាតើយើងត្រូវធ្វើយ៉ាងម៉េច? ធ្វើបុរេរោគវិនិច្ឆ័យ និងធ្វើរោគវិនិច្ឆ័យទៅលើលោក អៀង សារី នេះ។ ដូច្នេះក្នុងពេលនេះ គឺយើងមិនទាន់ដឹងច្បាស់ទាំងអស់គ្នានៅឡើយ។

អង្គជំនុំជម្រះបានកត់សម្គាល់ឃើញហើយថា តើមិនដឹងសុខភាពរបស់លោក អៀង សារី នោះធូរស្រាលក្នុងសប្តាហ៍ខាងមុខ ឬពីរសប្តាហ៍ទៀត ឬក៏វាត្រូវការពេលយូរជាងហ្នឹងទៀត។ ដូច្នេះព័ត៌មានទាំងអស់នេះ យើងត្រូវទទួលបានជាមុនសិន។ យើងខ្ញុំសូមលើកឡើងថា ដូចដែលមេធាវីការពារក្តី ដូចគ្នា គឺឲ្យសវនាការយើងបន្តទៅមុខសិនទៅ ដរាបណាខាងលោក អៀង សារី នោះអនុញ្ញាតឲ្យមេធាវីការពារក្តីនោះតំណាងគាត់ ដោយអវត្តមានរបស់លោក អៀង សារី ដែលនៅពេទ្យ ប៉ុន្តែមេធាវីនៅទីនេះតំណាង។ ដូច្នេះ យើងលើកឡើងហើយថាសិទ្ធិរបស់គាត់ត្រូវបានការពារ ទោះបីជាដំណើរការ

នេះទៅមុខក៏ដោយ បើសិនបើមានមេធាវីតំណាង។

[១៥:១៩:២៣]

ពាក់ព័ន្ធទៅនឹងសាក្សី ក្រុមមេធាវីការពារក្តីបានលើកឡើងឈ្មោះសាក្សីមួយចំនួនរួចមកហើយ ដែលលោក អៀង សារី អាចអនុញ្ញាតឲ្យស្តាប់ចម្លើយសាក្សីនេះដោយមិនមានវត្តមានរបស់ អៀង សារី។ ដូចដែលមេធាវីការពារក្តីលើកឡើង គឺមានសាក្សីប្រហែលជា២០នាក់ ដែលមាននៅក្នុងបញ្ជីរបស់សហព្រះរាជអាជ្ញាលើកឡើងអំពីការផ្លាស់ទីលំនៅប្រជាជនដោយបង្ខំដំណាក់កាលទី១ និងទី២។ ពាក់ព័ន្ធទៅនឹងចំណុចហ្នឹងផងដែរ លោក អៀង សារី គាត់បានបោះបង់សិទ្ធិសាក្សីពីររូបទៀត គឺ389, 126 និងសាក្សីមួយទៀត 186 ដែលគាត់បានបោះបង់សិទ្ធិផងដែរ។ ហើយសាក្សីមួយចំនួន គឺគាត់ថាមិនអាចមកផ្តល់សក្ខីកម្មដោយគាត់មិនមានលទ្ធភាព។ ដូច្នេះហើយប្រសិនបើ អៀង សារី គាត់ពេញចិត្តឲ្យមេធាវីតំណាងការពារក្តីរបស់គាត់នេះ ដំណើរការទៅបាន ដូច្នេះហើយគឺយើងអាចស្តាប់នូវការបង្ហាញភស្តុតាងនៅសប្តាហ៍ក្រោយគឺបញ្ហាលើបញ្ហារចនាសម្ព័ន្ធយោធា និងរចនាសម្ព័ន្ធរដ្ឋបាល។

ហើយយើងគិតថាលោក អៀង សារី នោះក៏បានបោះបង់សិទ្ធិទៅលើការស្តាប់នូវភស្តុតាងមួយចំនួនផងដែរលើបញ្ហាគោលនយោបាយ រចនាសម្ព័ន្ធយោធា និងបញ្ហារចនាសម្ព័ន្ធរដ្ឋបាល និងភស្តុតាងស៊ីសង្វាក់ផ្សេងទៀត។ ដូច្នេះហើយ យើងក៏មិនទាន់ដឹងថាតើចម្លើយ និងភស្តុតាងឯកសារមួយចំនួនដែលនឹងទទួលយកដោយតុលាការនៅចំពោះមុខនេះទេ។

[១៥:២១:០១]

លោក កាណាវាស បានលើកឡើងកាលពីសប្តាហ៍មុន គឺយើងមានការងារច្រើនណាស់ដែលវាមិនអាចឲ្យយើងពន្យារសវនាការរបស់យើងនោះទេ ដោយក្នុងពេលនេះ គឺយើងនៅរង់ចាំស្ថានភាពសុខភាពរបស់លោក អៀង សារី។ ចំណុចនេះ គឺលើកឡើងត្រឹមត្រូវ ហើយមានយើងមានការងារច្រើនដែលយើងត្រូវបំពេញ។ ឯកសារមួយចំនួនដែលខ្ញុំបានទទួលពីអង្គជំនុំជម្រះប៉ុន្មាននាទីមុននេះ គឺយើងត្រូវមើលជាមុនសិន តាមរយៈបញ្ជីដែលបានបញ្ជាក់ជាបឋមដោយអង្គជំនុំជម្រះ ដែលអង្គជំនុំជម្រះចង់ស្តាប់នោះ ពាក់ព័ន្ធទៅនឹងអង្គហេតុនៃការផ្លាស់ទីលំនៅប្រជាជន។ យើងឃើញថាសាក្សីមួយចំនួននោះគឺដូចនឹងសាក្សីដែលតំណាងសហព្រះរាជអាជ្ញាបានស្នើឡើង ហើយនៅពេលនេះអង្គជំនុំជម្រះក៏សម្រេចកោះហៅសាក្សីនេះនោះផងដែរ។

យើងក៏កត់សម្គាល់ឃើញមានសាក្សីមួយចំនួនទៀតដែលសហមេធាវីនាំមុខបានស្នើឡើង ហើយ

អង្គជំនុំក៏ថានឹងកោះហៅសាក្សីទាំងនេះមកផ្ដល់សក្ខីកម្មនាពេលខាងមុខនេះផងដែរ។ ដូច្នេះពេលវេលានឹងបង្ហាញឲ្យយើងឃើញទាំងអស់គ្នា។

[១៥:២២:១៨]

ស្ថានភាពដែលលើកឡើងដោយក្រុមមេធាវីការពារក្ដី អៀង សារី ដែលថាគាត់នឹងសហការជាពិសេសទៅលើសាក្សីដែលគាត់មិនផ្ដល់ភស្ដុតាងពាក់ព័ន្ធដោយ ផ្ទាល់ទៅនឹងទង្វើរសកម្មភាពរបស់លោក អៀង សារី។ ដូច្នេះចំណុចនេះ គឺ អៀង សារី -- គឺយើង ឃើញថា សាក្សីទាំងអស់នេះក៏អាចស្នើពីខាងមេធាវីនាំមុខផងដែរ ហើយវាត្រូវ និងស៊ីសង្វាក់គ្នា។ យើងគិតថា យើងមានសាក្សីគ្រប់គ្រាន់ហើយដែលយើងអាចស្ដាប់ និងឲ្យគាត់មកផ្ដល់សក្ខីកម្មបាន។ ប្រហែលក្នុងអំឡុងពេលនេះរហូតទៅដល់ក្រោយបុណ្យគ្រិស្ដស្មាសឯណោះទៀត។ ដូច្នេះហើយគឺយើងយល់អំពីការព្រួយបារម្ភរបស់អង្គជំនុំជម្រះ និងការព្រួយបារម្ភរបស់យើងទាំងអស់គ្នាក្នុងការរៀបចំផែនការរបស់យើងនេះ។ យើងចង់ឲ្យមានការបោះបង់សិទ្ធិ ហើយក្នុងករណីខ្លះ យើងឃើញមានការលើកឡើងអំពីសិទ្ធិនេះឡើងវិញ។ ដូច្នេះវាជាបញ្ហាព្រួយបារម្ភសម្រាប់យើង។

[១៥:២៣:១៧]

លោក កាណាវាស បានលើកឡើងហើយ ស្ថានភាពមួយចំនួនដែលថាសាក្សីស្អែកនេះដែលមកផ្ដល់សក្ខីកម្មនៅថ្ងៃស្អែកនេះ គឺយើងមិនអាចដឹងទាំងអស់គ្នា ថាតើចម្លើយរបស់គាត់ហ្នឹង គឺនឹងលើកឡើងទៅលើឧទាហរណ៍ថារចនាសម្ព័ន្ធនោះ ពេលដែលលើកឡើងនោះយើងមិនដឹងថាតើវាអាចពាក់ព័ន្ធទៅនឹងបញ្ហាលោក អៀង សារី ក្រោយ ឬអំឡុងឆ្នាំ៧០ហ្នឹង ឬក៏យ៉ាងណា។ ដូច្នេះហើយតាមទស្សនវិស័យរបស់សហព្រះរាជអាជ្ញា ព័ត៌មានដែលឆ្លើយចេញពីសាក្សីនៅថ្ងៃស្អែកនេះ ជាពិសេសក្រោយឆ្នាំ៧៩នោះ យើងយល់ឃើញថា យើងមិនមែនថាឆ្នាំ៧៩នោះមិនពាក់ព័ន្ធទេ ក៏ប៉ុន្តែយើងខ្ញុំយល់ឃើញថាឆ្នាំ៧៩ នេះ គឺវាមិនពាក់ព័ន្ធខ្លាំងនោះទេ ដែលយើងមិនថាមិនអាចសួរសាក្សីនេះបាន។ ដូច្នេះហើយ គឺលោក អៀង សារី គាត់បានបញ្ជាក់អំពីការបោះបង់សិទ្ធិនេះរួចមកហើយ ដែលវាជាសុទ្ធចិត្តមួយពីខាងគាត់។

ការលើកឡើងរបស់លោក កាណាវាស លើកឡើងអំពីការផ្លាស់ទីលំនៅដំណាក់កាលទី១ និងទី២ យើងដឹងហើយថាការបោះបង់សិទ្ធិនោះបានធ្វើឡើង ជាពិសេសទៅលើផ្នែកអង្គហេតុជាច្រើននៅក្នុងហ្នឹង។ ក៏ប៉ុន្តែមានការលើកឡើងបដិសេធសិទ្ធិនេះឡើងវិញ ដូចដែលយើងបានដឹងទាំងអស់គ្នា។

[១៥:២៤:៤៥]

អង្គជំនុំជម្រះបានដឹងហើយថា យើងមានការជ្រើសរើសផ្នែកនៅក្នុងរឿងក្តីរបស់យើងដែលភាគច្រើនវាពាក់ព័ន្ធទៅនឹងឧក្រិដ្ឋកម្ម ដែលយើងបានចោទប្រកាន់ និងដាក់បន្ទុកទៅលើការជម្លៀសប្រជាជន។ ហើយអង្គហេតុទាំងអស់នោះ គឺវាមិនមែនថាពាក់ព័ន្ធទាំងស្រុងទៅនឹងទង្វើ និងសកម្មភាពរបស់ជនជាប់ចោទនៅក្នុងពេលនេះ ដែលថាមិនអាចដំណើរការទៅបាននោះទេ។ ដូច្នេះ ទោះបីពាក់ព័ន្ធក៏ដោយ ក៏អាចពាក់ព័ន្ធមួយចំនួនតែប៉ុណ្ណោះ។ លោក កាណាវាស ក៏បានលើកឡើងអំពីការពិភាក្សាកាលពីថ្ងៃមុនៗ ប្រសិនបើមានស្ថានភាពនេះកើតឡើង បានន័យថា នៅពេលដែលសាក្សីឆ្លើយអំពី អៀង សារី មិនមានកំណត់របស់សាក្សីនោះ អង្គជំនុំជម្រះនៅពេលនោះ គឺមិនអាចទាយស្មានដឹងជាមុនទេ ទៅលើបញ្ហានេះ។ ហើយបើសិនមានករណីហ្នឹងមែន យើងមានជម្រើសមួយចំនួនអាចធ្វើឡើងបាន។ ទី១ គឺថាយើងអាចកោះហៅសាក្សីហ្នឹង ឡើងមកវិញបាន ស្តាប់គាត់ ១០ ទៅ២០នាទី នៅពេលដែលលោក អៀង សារី នោះ ធូរស្រាលឡើងវិញ។ ហើយបើសិនជាកើតដដែលនោះ ទី២ គឺថាបញ្ហាហ្នឹង អាចដកចេញពីប្រតិចារឹក។ ដូច្នេះ បញ្ហានេះមិនមែនរំលោភទៅលើសិទ្ធិរបស់លោក អៀង សារី នោះឡើយ។

[១៥:២៦:០៦]

ពាក់ព័ន្ធទៅនឹងចំណុចនេះ យើងខ្ញុំសូមលើឡើងវិញថា ចំណុចទាំងអស់នេះ អង្គហេតុទាំងអស់នេះ គឺវាពាក់ព័ន្ធទៅនឹងលោក អៀង សារី ទោះបីយ៉ាងក៏ដោយ ក៏វាមិនមែនថា យើងមិនអាចដំណើរការទៅមុខនោះទេ។ ផ្អែកទៅតាមលិខិតបោះបង់សិទ្ធិពីខាងក្រុមមេធាវីការពារក្តី យោងតាមលិខិតនេះ យើងខ្ញុំគិតថា វាមិនអាចឲ្យយើងមានការពន្យារពេលច្រើននោះទេ ក៏ប៉ុន្តែចំណុចខុសគ្នានេះ គឺថាអង្គជំនុំជម្រះនឹងអាចមើលឃើញហើយការជម្លៀសផ្លាសទីលំនៅរបស់ប្រជាជននោះ គឺវាអាចពាក់ព័ន្ធទៅនឹងដំណាក់កាលក្រោយ ហើយដែលយើងអាចយកមកធ្វើការស្តាប់បាន។ ដូច្នេះ យើងខ្ញុំសូមលើកឡើងថា នេះជាស្ថានភាពដែលយើងសូមបង្ហាញជូន ដូចដែលអង្គជំនុំជម្រះបានណែនាំទៅដល់ភាគីរួចមកហើយ ទោះបីយ៉ាងក៏ដោយ យើងនឹងមានភាពបត់បែនទៅលើបញ្ហាអង្គហេតុទាំងអស់នេះ។ នៅពេលដែលលោក អៀង សារី គាត់មានស្ថានភាពធូរស្រាល យើងនឹងកោះហៅសាក្សីទាំងឡាយដែលវាពាក់ព័ន្ធខ្លាំងទៅនឹងលោក អៀង សារី នេះ ជាពិសេស ទៅលើបញ្ហាផ្លាសទីលំនៅ ដំណាក់កាលទី១ និងទី២។ ប្រហែលជាក្រោយរហូតដល់ពេលក្រោយគ្រីសស្មាសឯណោះទៀតណោះ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ សូមអញ្ជើញក្រុមមេធាវីនាំដើមបណ្តឹងរដ្ឋប្បវេណី!

[១៥:២៧:៣៧]

**លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត៖**

សូមអរគុណលោកប្រធាន។

ខ្ញុំមានកត់សម្គាល់មួយចំនួន ដើម្បីជាប្រយោជន៍របស់ដើមបណ្តឹងរដ្ឋប្បវេណី ដូចដែលយើងខ្ញុំបានលើកពីលើកមុនអ៉ីចឹង គឺថាយើងមានការព្រួយបារម្ភក្នុងការធ្វើដំណើរជម្រះក្តីនេះបានទៅមុខ ហើយនិងភាពរលូន។ ដូច្នេះ យើងយល់ស្របទៅលើគំនិតថានឹងបន្តស្តាប់សាក្សី ហើយនិងដើមបណ្តឹងរដ្ឋប្បវេណី ទាក់ទងទៅនឹងការជម្លៀសដោយបង្ខំ។ យើងបានទទួលបញ្ជារបស់ខាងក្រុម អៀង សារី ហើយ។ ហើយខ្ញុំក៏យល់ឃើញហើយថា ក៏បានដឹងផងដែរ ថាអង្គជំនុំជម្រះបានបញ្ចេញបញ្ជីសាក្សី ហើយនិងដើមបណ្តឹងរដ្ឋប្បវេណីមួយទៀត ដែលយើងនឹងស្តាប់នៅពេលខាងមុខ។ ហើយខ្ញុំសន្មតថា ក្រុម អៀង សារី នឹងចេញសេចក្តី -- នឹងធ្វើការសម្រេចលើបញ្ជីរបស់អង្គជំនុំជម្រះ។ ពេលវេលានេះខ្លីណាស់ ហើយយើងក៏មិនដឹងថា អ្នកណានឹងយើងស្តាប់នៅពេលខាងមុខនេះ ប៉ុន្មានសប្តាហ៍ខាងមុខ ឬប៉ុន្មានខែខាងមុខនេះ ហើយយើងក៏ចង់ឱ្យដំណើរការជម្រះសេចក្តីនេះ ទៅមុខបានលឿន ហើយបញ្ជីរបស់អង្គជំនុំជម្រះហ្នឹងមានដើមបណ្តឹងរដ្ឋប្បវេណីមួយចំនួន ហើយយើងចាំស្តាប់ប្រតិកម្មរបស់ក្រុម អៀង សារី ហើយនិងយើងនឹងពិភាក្សានៅខាងមុខទៀត ចំពោះបញ្ហានេះ។

[១៥:២៩:០៧]

ខ្ញុំសូមទាញចំណាប់អារម្មណ៍អង្គជំនុំជម្រះថា ស្ថានភាពនេះ ធ្វើឱ្យយើងមិនពេញចិត្តនោះទេព្រោះថាមានការលំបាកណាស់ យើងនឹងជួបការលំបាក គឺថាអម្បាញ់មិញនេះ យើងលើកពីការលំបាកមួយចំនួនហើយ ក្រុម អៀង សារី ខ្លួនឯង ក៏បានលើកដែរ ហើយនិងសហព្រះរាជអាជ្ញាក៏បានលើកឡើងដែរ។ គឺក្នុងករណីដែលថា សាក្សីមួយនឹងគាត់មកនិយាយ អៀង សារី ហើយនិងធ្វើឱ្យ គឺថា អ៉ីចឹង គឺថាធ្វើឱ្យភាគីផ្សេងៗទៀតហ្នឹង ក៏និយាយពី អៀង សារី ដែរ។ ហើយខ្ញុំសូមរំឭកផងដែរ ថាការព្រួយបារម្ភរបស់យើងចម្បងហ្នឹង គឺថាទាក់ទងទៅនឹងស្ថានភាពសុខភាពរបស់ អៀង សារី គឺថាទាក់ទងនឹងរយៈពេលវេលា ហើយនិងពេលវេលា ហើយនិងស្ថានភាពសុខភាពរបស់គាត់ តើគាត់អាចចូលរួមសវនាការបានឬក៏អត់? ហើយយើងមិនទាន់បានទទួលរបាយការណ៍ចុងក្រោយនៅឡើយទេទាក់ទង

សុខភាពរបស់គាត់។ ហើយរបាយការណ៍ដែលយើងពិភាក្សាពី១០ថ្ងៃមុននោះ ក៏អត់ដែរ។ ដូច្នេះយើងនិយាយក្នុងភាពមួយដែលថាមិនមានភាពច្បាស់លាស់ យើងចាំទទួលព័ត៌មានច្បាស់លាស់ ហើយយើងសុំឲ្យផ្ដល់ព័ត៌មានមកយើងឲ្យបានលឿនបំផុត គឺថាខែក្រោយ ឬក៏អាទិត្យក្រោយ ពីព្រោះថានេះជាបញ្ហាចម្បងបំផុត។ ហើយទាំងអស់នេះនឹងជួយឲ្យអង្គជំនុំជម្រះធ្វើសេចក្ដីសម្រេចដ៏សំខាន់មួយ ចំពោះយើងក្នុងការឲ្យសាក្សី ឬក៏ដើមបណ្ដឹងរដ្ឋប្បវេណីនិយាយអំពីការជម្លៀសដោយបង្ខំនេះ ជារឿងមួយដែលយើងអាចទទួលបាន។ ក៏ប៉ុន្តែទាក់ទងនឹងពេលវេលាពិបាកៗប៉ាន់ស្មានណាស់ ពីព្រោះយើងមិនដឹងថា អៀង សារី នឹងមានអ្វីកើតឡើងចំពោះគាត់នោះទេ នៅថ្ងៃអនាគតនោះ។

[១៥:៣០:៥៤]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកស្រីចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍!

**ចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍៖**

សូមអរគុណលោកប្រធាន។ ហើយខ្ញុំពិនិត្យមើលការឆ្លើយតបទៅនឹងសេចក្ដីសន្និដ្ឋាន របស់សហមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណីនោះ គឺថាយើងបានបញ្ជាក់ច្បាស់ហើយគឺថា សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណីនិយាយពីឯកសារវេជ្ជសាស្ត្រនោះ គឺដាក់នៅក្នុងសំណុំរឿង ហើយភាគីអាចបើកមើលបាន។ ចំណុចទី២ ព័ត៌មានដែលបានផ្ដល់ទៅឲ្យសាស្ត្រាចារ្យ ខាំប៊ែល នោះដូចដែលខ្ញុំបានសង្ខេបពីខាងដើមអ៊ីចឹង គឺលើកលែងតែខ្ញុំបានទទួលដំណឹងថា ការិយាល័យរដ្ឋបាលមិនទាន់បានឯកសារស្ដែនមកពីមន្ទីរមិត្តភាពខ្មែរ-សូវៀត នោះទេ ហើយឲ្យខាងរដ្ឋបាលធានាថា យើងត្រូវការឯកសារហ្នឹងជាបន្ទាន់។ រឿងទី៣ ការវាយតម្លៃខាងវេជ្ជសាស្ត្រនោះគឺថា បានផ្ដល់ជូនឲ្យភាគីដឹងហើយនៅពេល -- បញ្ហាពាក់ព័ន្ធនឹងភាគីនោះ ភាគីនោះអាចទទួលបាន។ ហើយយើងនឹងបន្តធ្វើការងារនេះតទៅទៀត។ ដោយសង្ខេប គឺដើមបណ្ដឹងរដ្ឋប្បវេណីហ្នឹងគឺថាមិនត្រូវបានផ្ដល់ព័ត៌មាន -- មិនបានព័ត៌មានដែលភាគីផ្សេងទៀតបានទេ គឺបានដូចៗគ្នាទាំងអស់។

[១៥:៣២:០១]

**ប្រធានអង្គជំនុំ៖**

អរគុណលោកស្រីចៅក្រម។ សូមអញ្ជើញលោកចៅក្រម ហ្សង់ម៉ាក ឡាវែន៍!

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

បាទ សូមអរគុណលោកប្រធាន។ បាទ ខ្ញុំមានសំណួរចោទសួរទៅនឹងក្រុមការពារក្ដីរបស់លោក អៀង សារី។ បាទ ខ្ញុំសូមអរគុណជាបឋមហ្នឹងគឺថា ទៅលើការសេចក្ដីសម្រេចចិត្តរបស់គាត់ដ៏សំខាន់ ក៏ប៉ុន្តែខ្ញុំគិតថា ជាការសំខាន់ណាស់ចំពោះអង្គជំនុំជម្រះ ក្នុងការវាយតម្លៃដោយផ្ទាល់នូវវិសាលភាពនៃការលះបង់សិទ្ធិរបស់លោក អៀង សារី ហ្នឹង តើវាមានកម្រិតណា? នៅពេលដែលយើងស្ដាប់សាក្សីម្នាក់ យើងត្រូវចោទសំណួរគាត់មួយចំនួន ហើយអង្គជំនុំជម្រះនឹងធ្វើការវាយតម្លៃ ថាតើសំណួរទាំងអស់នេះពាក់ព័ន្ធដែរឬក៏អត់? ហើយនេះគឺជាបទដ្ឋានសំខាន់ណាស់ចំពោះយើង គឺថាភាពពាក់ព័ន្ធនៃសំណួរទាំងអស់នេះ ទាក់ទងទៅនឹងវិសាលភាពនៃការជម្រះក្ដីសំណុំរឿង០០២/០១ នេះ។ ឧទាហរណ៍ ខ្ញុំថា បើយើងស្ដាប់សាក្សីដែលថា យើងនឹងស្ដាប់នៅថ្ងៃស្អែកនេះ សាក្សីនេះគឺថា យើងនឹងសន្មតថា គាត់នឹងផ្ដល់សក្ខីកម្មលើរចនាសម្ព័ន្ធឃោធា ហើយជាការច្បាស់លាស់ណាស់ ដែលថាគាត់អាចមានព័ត៌មានទាក់ទងទៅនឹងចំណុចផ្សេងៗទៀតមួយចំនួន ដែលទាក់ទងទៅនឹងករណីគឺថា សំណុំរឿង០០២/០១ នេះ។ សំណួរខ្ញុំដូចតទៅនេះ តើការលះបង់សិទ្ធិរបស់គាត់នេះស្ថិតនៅក្រោមលក្ខខណ្ឌ គឺថាមានកម្រិតណា? ជាការសំខាន់ណាស់ចំពោះយើងនោះ គឺយើងត្រូវតែមានមូលដ្ឋានមួយចំនួន ដើម្បីធ្វើការកំណត់កាលវិភាគនៃការស្ដាប់សាក្សី។ ខ្ញុំគិតថាសំណួរខ្ញុំនេះច្បាស់លាស់ហើយ ហើយខ្ញុំគិតភាគីទាំងអស់យល់អំពីអ្វីដែលខ្ញុំចង់និយាយ។

[១៥:៣៤:២៣]

**លោក ម៉ៃខល កាណាវាស៖**

សូមអរគុណលោកចៅក្រម។ ខ្ញុំសូមពន្យល់អំពីដំណើរការដែលយើងអនុវត្តទៅនៅក្នុងបញ្ជីនោះ ហើយនិងនៅក្នុងការពិនិត្យបញ្ជីនោះជាមួយកូនក្ដីរបស់ខ្ញុំដែរ ដើម្បីធានាពីការបោះបង់សិទ្ធិរបស់គាត់។ ហើយយើងបានពិនិត្យមើលសាក្សី ហើយមើលចម្លើយសាក្សី ហើយយើងមើលឯកសារមួយចំនួនដែលពាក់ព័ន្ធទៅនឹងៗសាក្សី។ ហើយយើងបានពិនិត្យមើលផ្នែកខ្លះនៃសំណុំរឿងថា តើមានអ្វីខ្លះដែលអាចនឹងយកមកប្រើទាក់ទងទៅនឹងសាក្សីនេះ។ កាលណា ដែលយើងមានការយល់ឃើញថា អាចនឹងមានអ្វីដែលលោក អៀង សារី នឹងត្រូវការជាចាំបាច់នៅក្នុងការវត្តមាន ដើម្បីផ្ដល់ការណែនាំដល់យើងនោះ។ ហើយៗដែលថា ប្រឆាំងនឹងការបោះបង់សិទ្ធិនោះ គឺជាសិទ្ធិរបស់គាត់ ហើយយើងក៏បានទទួលស្គាល់ផងដែរថា គឺសាក្សីទាំងអស់ដែលនឹងមកទីនេះ នឹងនិយាយ -- យើងគិត យើងបានឃើញ យើងបាន

ដឹងថាមេដឹកនាំធ្វើអ៊ីចេះ ធ្លាក់លើធ្វើបែបនោះ។ នេះជាពាក្យមួយចំនួនដែលយើងបានស្តាប់ឮ ជាញឹកញាប់នៅក្នុងតុលាការនេះ ហើយនៅពេលដែលឆ្លើយបែបនោះ គឺថាប៉ះពាល់ដល់លោក អៀង សារី ក្នុងករណីណាមួយ។ ដូច្នេះហើយដែលយើងរក្សាសិទ្ធិ។

[១៥:៣៥:៥២]

យើងបានពិគ្រោះយោបល់ជាមួយលោក អៀង សារី ហើយ យើងបានពិនិត្យមើលឈ្មោះ យើងមើលសេចក្តីសង្ខេប ដែលសហព្រះរាជអាជ្ញាបានរៀបចំនេះ ដែលពួកគាត់បានយល់ថា អាចនឹង -- សាក្សីនឹងឆ្លើយ ឬក៏ដើមបណ្តឹងរដ្ឋប្បវេណីនឹងនិយាយ។ ហើយនឹងការយល់ ការដឹងអំពីបុគ្គលម្នាក់ៗនេះ ថាតើគាត់មានចំណុចអ្វីពិសេស ព័ត៌មានអ្វីគាំទ្រ ឬក៏ប្រឆាំងលោក អៀង សារី។ ផ្អែកលើគំនិតនេះ ហើយយើងនឹងផ្តល់ ហើយគាត់ផ្តល់ការណែនាំមកយើង ហើយនិងការបោះបង់សិទ្ធិ។

តាមអ្វីដែលយើងខ្ញុំយល់ គឺសាក្សីទាំងអស់នេះនឹងមកធ្វើសក្ខីកម្ម ហ្នឹងគឺថា អ្វីទាំងស្រុងដូចដែលអង្គជំនុំជម្រះចង់បាន ស្វែងរកនោះហើយ។ ប្រសិនបើមានអ្វីពាក់ព័ន្ធ ឬក៏មិនពាក់ព័ន្ធ ជាបញ្ហាឆន្ទានុសិទ្ធិ គឺអាស្រ័យទៅលើចៅក្រមទេ។ ប៉ុន្តែយើងខ្ញុំទទួលស្គាល់ផ្អែកទៅលើការពិនិត្យសាក្សីនេះ កាលណាមានភាពពាក់ព័ន្ធនៅក្នុងសក្ខីកម្មរបស់សាក្សីនេះ គឺអាចមានត្រឹមណា។ ប៉ុន្តែប្រសិនបើអ្វីដែលកើតឡើងដោយមិនបានគ្រោងទុកនោះគឺ ជាក់ស្តែងនោះគឺ នៅពេលដែលយើងបានយល់ -- ឈានដល់ការយោគយល់ជាមួយសហព្រះរាជអាជ្ញាហើយ គឺថាអាចនឹងៗ អាចផ្ទុយពីហេតុការណ៍ទាំងស្រុងនោះគឺថា តើយើងត្រូវស្តាប់សាក្សីនោះឡើងវិញដែរឬទេ ដើម្បីឲ្យគាត់ -- លោក អៀង សារី បានពិគ្រោះយោបល់ជាមួយយើងខ្ញុំ និងឆ្លើយតប។

ហើយយើងមិនរំពឹងថា អាចនឹងមានករណីហ្នឹងញឹកញាប់នោះទេ គឺថាវាមិនជាញឹកញាប់ ប៉ុន្តែវាអាចកើតមានឡើងក្នុងពេលណាមួយ។ ហើយខ្ញុំជឿជាក់ -- ខ្ញុំសង្ស័យថា វាអាចកើតក្នុងករណីនោះ។ ការព្រួយបារម្ភរបស់យើងខ្ញុំ អ្វីដែលខ្ញុំយល់ អ្វីដែលខ្ញុំពិគ្រោះយោបល់ជាមួយគាត់នោះ គឺថាការ -- ហើយមានការលើកលែងតែមួយទេ ដើម្បីឲ្យភាគីអាចនឹងពិនិត្យសាក្សី ឲ្យបានទូលំទូលាយនៅពេលដែលសាក្សីត្រូវបានបង្ហាញខ្លួនមកទីនេះនោះ ពេលដែលចាំបាច់។ នេះហើយជាជំហររបស់យើងខ្ញុំ។ នេះជាមូលហេតុដែលយើងខ្ញុំប្រកាន់ជំហរយ៉ាងរឹងមាំចំពោះសាក្សីមួយចំនួន ដែលយើងខ្ញុំមិនបោះបង់សិទ្ធិទេ។ នៅក្នុងករណីនោះគឺ យើងមិនបោះបង់សិទ្ធិ គឺថាតែប៉ុណ្ណឹង យើងមិនពន្យល់អ្វីទៀតទេ។ នៅទីនេះគឺថាយើងដាក់បញ្ចូលនូវលទ្ធភាពមួយចំនួន គឺអនុញ្ញាតសាក្សីដែលអាចកោះអញ្ជើញមកនៅក្នុង ដូចជា

សាក្សីបញ្ជាក់ពីទីតាំងបទល្មើសជាដើម នោះគឺអាចនឹងមានដើមបណ្ដឹងរដ្ឋប្បវេណីផងដែរ ដែលមកបំភ្លឺនោះ។

[១៥:៣៨:៣៥]

លោក អៀង សារី គាត់ស្ម័គ្រចិត្ត ហើយគាត់បានបោះបង់សិទ្ធិ ដោយគាត់មានការស្ម័គ្រចិត្តនៅក្នុងករណីមួយចំនួន ដើម្បីឲ្យគាត់យល់ច្បាស់ថាតើខ្លឹមសារទាំងអស់នោះវាយ៉ាងដូចម្ដេច។ តើខ្ញុំបានឆ្លើយទៅនឹងសំណួរលោកចៅក្រម ហើយឬនៅ ពីព្រោះខ្ញុំបានព្យាយាមអស់ប៉ុណ្ណឹងបាទ។

**ចៅក្រម ហ្សង់ម៉ាក ឡាវែរ៉ន៖**

បាទ ខ្ញុំសូមការបំភ្លឺមួយ គឺថានឹងមានសំណួរដែលភាគីនឹងចោទសួរ ហើយនិងចៅក្រមផងដែរ ពីព្រោះថា ជាប្រព័ន្ធកូនកាត់ អ៊ីចឹងលោកក៏ដឹងផងដែរ។ ខ្ញុំយល់ហើយថា លោកយល់ព្រម ហើយនិងកូនក្ដីរបស់លោកក៏យល់ព្រម ថាឲ្យស្ដាប់សាក្សីបានច្រើនបំផុត ក្នុងករណីដែលថា មានភាពពាក់ព័ន្ធ ហើយនិង លោកក៏សូមឲ្យសាក្សីនោះអាចត្រឡប់មកវិញបាន បើសិនជាឃើញថា ជាការចាំបាច់ក្នុងការធានាសិទ្ធិរបស់ជនជាប់ចោទ ហើយនិងសិទ្ធិខាងការពារក្ដី។ តើអ៊ីចឹងឬទេ ដែលអ្វីដែលលោកនិយាយអម្បាញ់មិញនេះ?

**លោក ម៉ៃខល កាណាវាស៖**

តាមពិតហើយ ខ្ញុំគាំទ្រ ដែលថាចៅក្រមអាចសួរសំណួរនៅក្នុងប្រព័ន្ធតុលាការរបស់យើងនេះដូចជាសាលាក្ដីផ្សេងទៀត ហើយយើងបានពិចារណាចំណុចហ្នឹង។ កាលណាចៅក្រមអាចសំណួរក្រៅពីអ្វីដែលនៅក្នុងវិសាលដែលពាក់ព័ន្ធទាក់ទងទៅនឹងផ្នែកផ្សេងហ្នឹង គឺថាយើងយល់ហើយ គឺថាចៅក្រមមិនអាចសួរអ្វីក្រៅពីវិសាលភាពនេះទេ។ ប៉ុន្តែបើមានស្ថានភាពនេះវាកើតឡើង ខ្ញុំពិនិត្យមើលនៅពេលដែលយើងខ្ញុំ ដែលរាប់ទាំងលោក អាង ឧត្ដម ផងហ្នឹង គឺថាយើងចាប់អារម្មណ៍ថា កូនក្ដី ពេលខ្លះកូនក្ដីរបស់ខ្ញុំអាចនឹងយល់ថា វាប៉ះពាល់ដល់ផលប្រយោជន៍របស់គាត់។ ហើយជាញឹកញាប់ គឺថាពេលដែលមានការប៉ះពាល់ ឬក៏នេះ ខ្ញុំជាអ្នកក្រោកឈរឡើង ដើម្បីបង្ហាញគំនិតថាជំទាស់ ឬក៏នឹងស្នើពីវិធានអ្វីនោះ។ សូមអរគុណ។

[១៥:៤០:៥៧]

**ចៅក្រម ហ្សង់ម៉ាក ឡាវែរ៉ន៖**

ខ្ញុំសូមធ្វើការបំភ្លឺមួយទៀត។ ថ្ងៃនេះស្អែកនេះគឺយើងត្រៀមទុកស្ដាប់សាក្សី 428 តើគោលជំហរ

របស់ក្រុម អៀង សារី ពិតប្រាកដនេះ ទាក់ទងនឹងសាក្សីនេះយ៉ាងម៉េចដែរ? តើមេធាវី អៀង សារី យល់ព្រមឲ្យយើងស្ដាប់គាត់គ្រប់ផ្នែកទាំងអស់ នៅក្នុងសំណុំរឿង០០២/០១ នេះទាំងមូលតែម្ដង ឬក៏ថាចង់ឲ្យយើងស្ដាប់គាត់តែ ទាក់ទងទៅនឹងរចនាសម្ព័ន្ធយោធាតែប៉ុណ្ណោះទេ?

**លោក ម៉ៃខល កាណាវាស៖**

អត់ទេ គឺថាសាក្សីដែលលើកឡើងនៅក្នុងរឿងក្ដី០០២/០០១ នេះគឺដែលលោក អៀង សារី បានបោះបង់សិទ្ធិ គឺថាអាចបន្ដនីតិវិធីបាន។ ខ្ញុំសូមបញ្ជាក់ឡើងវិញ តាមអ្វីដែលខ្ញុំយល់ សាក្សីទាំងអស់នេះដែលយើងបានបោះបង់សិទ្ធិនោះ គឺសម្រាប់គោលបំណងក្នុងរឿងក្ដី០០២/០០១។ នេះហើយជាគំនិតដែលយើងពិនិត្យឃើញ ហើយយើងបានបោះបង់សិទ្ធិនោះ។

ខ្ញុំសង្ឃឹមថា ខ្ញុំឆ្លើយច្បាស់ទៅលោកចៅក្រមពីចំណុចនេះបាទ។ បាទ បើមិនមានសំណួរអ្វីទៀតទេ ខ្ញុំសូមអនុញ្ញាតអង្គុយបាទ។

[១៥:៤២:៣៣]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។

បាទ អង្គជំនុំជម្រះសូមអរគុណចំពោះមតិយោបល់របស់អស់លោក លោកស្រីជាភាគី ដែលបានចូលរួមផ្ដល់មតិយោបល់ ពាក់ព័ន្ធនឹងបញ្ហាលទ្ធភាពក្នុងការរៀបចំសវនាការនាពេលខាងមុខ របស់អង្គជំនុំជម្រះ ពាក់ព័ន្ធទៅនឹងបញ្ហាកំពុងប្រឈមនូវបញ្ហាសុខភាពរបស់លោក អៀង សារី ដែលបាននិងកំពុងសម្រាកព្យាបាលនៅមន្ទីរពេទ្យ ដែលប្រមើលមើលទៅថាអាចមានរយៈពេលយូរនេះ។ ហើយជាពិសេសគឺ អរគុណចំពោះការបញ្ជាក់បន្ថែមរបស់លោកមេធាវី ម៉ៃខល កាណាវាស ដែលជាមេធាវីការពារក្ដីលោក អៀង សារី ដែលបញ្ជាក់ឆ្លើយតបទៅនឹងសំណួរពាក់ព័ន្ធជាមួយនឹងការសួរបន្ថែមរបស់ចៅក្រម។

[១៥:៤៣:៥៩]

បាទជាកិច្ចបន្ត អង្គជំនុំជម្រះ -- ដូចអង្គជំនុំជម្រះបានជម្រាបជូនអ៊ីចឹង ដើម្បីជាការសម្រួលដល់ការរៀបចំនូវកាលវិភាគសម្រាប់ដំណើរការសវនាការនាពេលខាងមុខ ក៏ដូចជាដើម្បីបញ្ជាក់បន្ថែមឲ្យកាន់តែច្បាស់អំពីអង្គហេតុ ដែលបានចោទប្រកាន់លើជនជាប់ចោទទាំងបីរូប ដែលស្ថិតនៅក្នុងវិសាលភាពនៃកិច្ចដំណើរការសវនាការពិភាក្សាដេញដោល សម្រាប់អង្គហេតុនៅក្នុងសំណុំរឿង០០២/០១ ហើយ

និងវគ្គទី៣។ អង្គជំនុំជម្រះកំណត់សម្រាប់ការធ្វើសវនាការ និងអនុវត្ត អនុលោមតាមវិធាន៨៩ ស្ទួន កថាខណ្ឌ១ នៃវិធានផ្ទៃ នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា អង្គជំនុំជម្រះសាលាដំបូង គឺចាត់តាំងក្រឡាបញ្ជីនៃអង្គជំនុំជម្រះ ដើម្បីឡើងអាននូវបណ្ដានៃអង្គហេតុដែលចោទប្រកាន់ទៅលើជនជាប់ចោទ ដូចមាននៅក្នុងដីកាដំណោះស្រាយ និងឯកសារ E121/7.2 ហើយគឺជាអង្គហេតុដែលនៅសេសសល់។

ហើយអង្គជំនុំជម្រះក៏សូមជម្រាបជូនផងដែរថា នៅពេលដែលក្រឡាបញ្ជីអាននូវកថាខណ្ឌដែលមាននៅក្នុងដីកាដំណោះស្រាយត្រង់ចំណុចដែលអានថា "លុប" គឺមានន័យថាចំណុចនោះ អាចមានឈ្មោះសាក្សី ដើមបណ្ដឹងរដ្ឋប្បវេណី អ្នកជំនាញ ឬបុគ្គលផ្សេងទៀត ដែលត្រូវបានកោសលុប ដោយសហចៅក្រមស៊ើបអង្កេត។
ហើយក្រឡាបញ្ជីម្នាក់ៗអាននូវកថាខណ្ឌដែលយើងកំណត់ថាចែកជូនរួចហើយ។ ហើយជាបន្តនេះ អង្គជំនុំជម្រះសូមអញ្ជើញលោកស្រី សែ កុលវុឌ្ឍី ឡើងអាននូវផ្នែកមួយចំនួននៃកថាខណ្ឌដែលយើងបានបែងចែកជូនលោកស្រី។ នៅក្នុង គឺអានអាននូវកថាខណ្ឌពី១១៨ ទៅ១៤៩, ១៥៦ ទៅ ១៦៥ ហើយ និងពី ២២១ ទៅ២៦៧។

សូមអញ្ជើញលោកស្រី សែ កុលវុឌ្ឍី!

[១៥:៤៦:២៦]

**ក្រឡាបញ្ជី៖**

ផ្នែកទី៥៖ រចនាសម្ព័ន្ធយោធា

ក) ការបង្កើតកងទ័ពបដិវត្តន៍កម្ពុជា

កថាខណ្ឌ១១៣៖ កងទ័ពបដិវត្តន៍កម្ពុជាគឺជាស្ថាប័នសំខាន់របស់កម្ពុជាប្រជាធិបតេយ្យ។ គោលនយោបាយបក្សកុម្មុយនីស្ដកម្ពុជា ពឹងផ្អែកជាសំខាន់ទៅលើកងកម្លាំងដើម្បីសម្រេចឲ្យបាននូវគោលដៅរបស់ខ្លួន ដោយធ្វើឲ្យកងទ័ពមួយជាផ្នែកមួយសំខាន់នៃឧបករណ៍រដ្ឋបាលរបស់ខ្លួន។ តាំងពីដើមដំបូងមក បក្សកុម្មុយនីស្ដកម្ពុជាបានគិតថា "ដើម្បីការពារខ្លួន និងដើម្បីរំដោះខ្លួន គឺត្រូវប្រើហិង្សាដាច់ខាត ទោះជាហិង្សានយោយបាយបាយ ឬជាហិង្សាប្រដាប់អាវុធក្ដី។ វាចាំបាច់ដាច់ខាត ដែលប្រជាជនត្រូវបំពាក់អាវុធ គឺមានន័យថា ត្រូវតែមានកងទ័ព ដើម្បីការពារប្រជាជន ដើម្បីការពារបដិវត្តន៍ និងដើម្បីបន្តវាយសម្រុកតបតខ្មាំងវិញ"។

[១៥:៤៧:២៤]

កថាខណ្ឌ១១៤៖ ប្រវត្តិផ្លូវការនៃបក្សកុម្មុយនីស្តកម្ពុជាបង្ហាញថា កម្លាំងប្រដាប់អាវុធរបស់ខ្លួនមានដើមកំណើតចេញពីកងការពារសម្ងាត់។ នៅឆ្នាំ១៩៦៨ កងកម្លាំងទាំងនេះត្រូវបានប្រែក្លាយទៅជាកងឈ្លបប្រដាប់អាវុធ។ នៅថ្ងៃ១៧ ខែមករា ឆ្នាំ១៩៦៨ ជាថ្ងៃនៃការចាប់ផ្តើមធ្វើតស៊ូជាផ្លូវការដោយអាវុធ និងជាថ្ងៃកំណើតកងទ័ពបដិវត្តន៍របស់បក្សកុម្មុយនីស្តកម្ពុជា។ ក្រោយមក បក្សកុម្មុយនីស្តកម្ពុជាចាត់ទុកថា ចាប់ពីឆ្នាំ១៩៦៩ មក "ការបង្កើតលក្ខខណ្ឌដែលអនុគ្រោះសម្រាប់កងទ័ពមានរួចជាស្រេចហើយនៅទីនោះ នៅកន្លែងខ្លះ នៅភូមិភាគសំខាន់ៗនានា មានកងអនុសេនាធំ មានកងជាច្រើនរួចទៅហើយ។ នៅកន្លែងផ្សេងទៀតមានត្រឹមតែអនុសេនាតូច ក្រុម និងពួក។ ប៉ុន្តែកម្លាំងទាំងនោះនៅក្នុងជួរកងទ័ពបដិវត្តន៍"។ នៅក្នុងខែមីនា ឆ្នាំ១៩៧០ កងកម្លាំងទាំងនោះ ត្រូវបានកំណត់ឈ្មោះជាផ្លូវការថា "កងកម្លាំងប្រដាប់អាវុធប្រជាជនរំដោះជាតិកម្ពុជា"។

កថាខណ្ឌ១១៥៖ ការរៀបចំចាត់តាំងជាផ្លូវការឡើងវិញនៃកងកម្លាំងប្រដាប់អាវុធនេះ ត្រូវបានប្រកាសជាសាធារណៈនៅក្នុងខែកក្កដា ឆ្នាំ១៩៧៥ នៅឯការជួបជុំគ្នាមួយដែលត្រូវបានគេហៅការជួបជុំនោះជាផ្លូវការថា សន្និសីទនយោបាយដ៏សំខាន់នៃមជ្ឈិមបក្សកុម្មុយនីស្តកម្ពុជាដែលមានតំណាងមកពីអង្គភាពនានានៃកងទ័ពបដិវត្តន៍ចូលរួមប្រហែល៣.០០០នាក់ និងដែលនៅពេលនោះ សមមិត្តប្រធានគណៈយោធាកំពូលរបស់បក្ស បានថ្លែងទៅកាន់អ្នកចូលរួម។ កងទ័ពបដិវត្តន៍កម្ពុជាបានទទួលជំនួយពីអ្នកជំនាញការ និងទទួលជំនួយជាសម្ភារៈយោធាមកពីប្រទេសនានា ជាពិសេសប្រទេសចិន។

[១៥:៤៩:៣១]

ខ) តួនាទីរបស់កងទ័ពបដិវត្តន៍កម្ពុជា

កថាខណ្ឌ១១៦៖ តួនាទីរបស់កងទ័ពដិវត្តន៍កម្ពុជា ត្រូវបានកំណត់នៅក្នុងឯកសារមូលដ្ឋានចំនួនពីរ ស្តីពីអង្គការចាត់តាំងរបស់អង្គការចាត់តាំងរបស់កម្ពុជាប្រជាធិបតេយ្យ។ មាត្រា១៩ នៃរដ្ឋធម្មនុញ្ញប្រគល់ភារកិច្ចចម្បងពីរដល់កងទ័ពបដិវត្តន៍កម្ពុជា៖ "ការពាររដ្ឋអំណាចរបស់ប្រជាជនកម្ពុជា ហើយនៅជាមួយគ្នានេះដែរ ជួយកសាងប្រទេស"។ យោងតាមមាត្រា២៧ នៃលក្ខន្តិកបក្សកុម្មុយនីស្តកម្ពុជាកងទ័ពបដិវត្តន៍កម្ពុជាទទួលខុសត្រូវសន្តិសុខទាំងក្នុង និងក្រៅប្រទេស។ កងទ័ពបដិវត្តន៍មានកាតព្វកិច្ចចូលរួមជាទូទៅក្នុងការ "កសាងប្រទេស"។ តួនាទីរបស់កងទ័ពបដិវត្តន៍កម្ពុជា ត្រូវបានលើកយកមកនិយាយដដែលៗ និងអះអាងជាថ្មីនៅក្នុងឯកសារបោះពុម្ពផ្សាយនានារបស់បក្សកុម្មុយនីស្តកម្ពុជា និង

នៅក្នុងការប្រជានានាជាច្រើនរាប់មិនអស់ដែលរៀបចំដោយបក្ស។

កថាខណ្ឌ១១៧៖ ការធានា“សន្តិសុខខាងក្រៅ” ឬការពារជាតិ គឺជាភារកិច្ចដ៏សំខាន់របស់កងទ័ពបដិវត្តន៍កម្ពុជា ជាពិសេសនៅក្នុងបរិបទនៃជម្លោះប្រដាប់អាវុធជាមួយសាធារណរដ្ឋសង្គមនិយមវៀតណាម និងនៅក្នុងបញ្ហាជម្លោះព្រំដែន។ “សន្តិសុខខាងក្នុង” រួមមានការការពាររបបនេះប្រឆាំងនឹងខ្មាំងសត្រូវ និងបុគ្គលដែលត្រូវបានសន្មតថាជាគិញ ដែលមាននៅក្នុងកងកម្លាំងប្រដាប់អាវុធ នៅក្នុងបក្ស និងនៅក្នុងប្រទេសទាំងមូល។

[១៥:៥១:១៣]

កថាខណ្ឌ១១៨៖ ជាមួយនឹងភារកិច្ច “កសាងប្រទេស” បក្សបានដាក់ការទទួលខុសត្រូវទៅលើកងទ័ពបដិវត្តន៍កម្ពុជាក្នុងការធានាឲ្យមានភាពថ្កុំថ្កើងរុងរឿង និងជួយលើកស្ទួយជីវភាពរស់នៅរបស់ប្រជាជន និងជួយជំរុញការសម្រេចភារកិច្ចផែនការ៤ឆ្នាំក្នុងការធ្វើស្រែឲ្យបានបីតោនក្នុងមួយហិកតា។ លើសពីនេះទៀត អង្គភាពកងទ័ពនីមួយៗត្រូវមានភារកិច្ចឧបត្ថម្ភគាំទ្រខ្លួន លើកលែងកងទ័ពនៅឯព្រំដែន។

គ)ស្ថាប័នទ័ពរបស់មជ្ឈិមបក្សកុម្មុនីស្តកម្ពុជា

<u>គណៈកម្មាធិការយោធា នៃគណៈកម្មាធិការមជ្ឈិម</u>

កថាខណ្ឌ១១៩៖ គណៈកម្មាធិការយោធា ឬគណៈកម្មាធិការយោធាជាន់ខ្ពស់ គឺជាស្ថាប័នរបស់គណៈមជ្ឈិមដែលដែលត្រូវបង្កើតឡើងយ៉ាងហោចណាស់ចាប់តាំងពីនៅឆ្នាំ១៩៧០ ហើយអត្ថិភាពនៃគណៈកម្មាធិការនេះត្រូវបានបញ្ជាក់អះអាងជាថ្មីនៅមហាសន្និបាតបក្សលើកទី៤។ ដោយសារតែតួនាទីដើមរបស់កងទ័ពបក្សកុម្មុយនីស្តកម្ពុជា រួមមាន បញ្ហាសន្តិសុខ និងតួនាទីយោធាសុទ្ធសាធ គណៈកម្មាធិការយោធាត្រូវបានគេហៅថា “គណៈកម្មាធិការសន្តិសុខ” ឬ “គណៈកម្មាធិការយោធា និងសន្តិសុខ”។ នៅអមគណៈមជ្ឈិមមានក្រុមជំនួយការទទួលបន្ទុកខាងផ្នែកយោធាផងដែរ។

[១៥:៥២:៤៧]

កថាខណ្ឌ១២០៖ គណៈកម្មាធិការយោធាដើរតួនាទីជាអង្គការមជ្ឈិមបក្ស ហើយដូច្នេះគណៈកម្មាធិការយោធាធានាលើការគ្រប់គ្រងកងទ័ពបដិវត្តន៍កម្ពុជាតាមរយៈមជ្ឈិម។ គណៈកម្មាធិការមជ្ឈិម និងគណៈកម្មាធិការយោធាជួនកាលប្រជុំរួមគ្នា ដើម្បីសម្រេចលើបញ្ហាយោធានានា ដែលត្រូវអនុវត្តបទបញ្ជាយុទ្ធសាស្ត្រជារួមទៅលើកងកម្លាំងប្រដាប់អាវុធ។

កថាខណ្ឌ១២១៖ នៅក្នុងបទសម្ភាសន៍មួយ អៀង សារី អះអាងថា គណៈកម្មាធិការសន្តិសុខ និងយោធារួមមាន ប៉ុល ពត, នួន ជា, និង សុន សេន។ សមាជិកដទៃទៀតនៃគណៈកម្មាធិការយោធារួមមាន សោ ភឹម និង តាម៉ុក។ បើទោះបីជាការទទួលខុសត្រូវជាផ្លូវការរបស់ពួកគេអាចមានលក្ខណៈតូចជាងនេះក៏ដោយ។ សាក្សីជាច្រើនបានប្រាប់ពីឈ្មោះ វន វ៉េត និង កែ ពក ដែរថាជាសមាជិកនៃគណៈកម្មាធិការយោធា។ ក្រោយថ្ងៃ១៧ មេសា ឆ្នាំ១៩៧៥ ប៉ុល ពត បន្តធ្វើជាប្រធានគណៈកម្មាធិការយោធា។ ទោះបី នួន ជា បានទទួលស្គាល់អំពីអត្ថិភាពនៃអង្គការបែបនេះ និងអំពីតួនាទីរបស់គាត់ក្នុងវិស័យការពារជាតិ និងក្នុងការកម្ទេចខ្មាំងខាងក្នុងក៏ដោយ ក៏គាត់បដិសេធថា គាត់មិនមែនជាសមាជិកនៃគណៈកម្មាធិការនេះទេ។ ប៉ុន្តែសាក្សីជាច្រើនបាននិយាយថា គាត់ជាសមាជិកនៃគណៈកម្មាធិការនេះ។

[១៥:៥៤:២៤]

កថាខណ្ឌ១២២៖ គណៈកម្មាធិការសន្តិសុខ និងយោធា បានសម្រេចលើបញ្ហាសន្តិសុខ និងយោធានានា ជាពិសេសលើ "ការសម្លាប់" "ការប្រតិបត្តិការរបស់ ស-២១" "កន្លែងសម្លាប់ផ្សេងទៀត" "ភ្នាក់ងារសម្ងាត់" និង "បញ្ហាទូទៅ"។ អៀង សារី ក៏និយាយផងដែរថា គណៈកម្មាធិការនេះរាយការណ៍ទៅគណៈកម្មាធិការអចិន្ត្រៃយ៍បន្ទាប់ពីបានទទួលរបាយការណ៍ពីភូមិភាគនានា និងនិយាយថា គាត់ខ្លួនឯងផ្ទាល់ក៏បានឮសេចក្តីរាយការណ៍ពីសន្តិសុខដែរ។

កថាខណ្ឌ១២៣៖ ដោយពិនិត្យមើលតួនាទីរបស់ពួកគេ នៅក្នុងគណៈកម្មាធិការយោធា ប៉ុល ពត, នួន ជា និង សុន សេន ទំនងជាទទួលជាខុសត្រូវរួមលើមន្ទីរស-២១ និងនយោបាយសន្តិសុខជាទូទៅ។ សុន សុន បានជួប និងសម្របសម្រួលការងាររបស់គាត់ជាប្រចាំជាមួយនឹងសមាជិកគណៈអចិន្ត្រៃយ៍ផ្សេងទៀត ដោយធានាថា មេដឹកនាំបក្សកុម្មុយនីស្តកម្ពុជាអាចគ្រប់គ្រង និងដឹងជាប្រចាំ អំពីសកម្មភាពរបស់កងទ័ពបដិវត្តកម្ពុជា។

<u>សេនាធិការ</u>

កថាខណ្ឌ១២៤៖ អង្គការកណ្តាលរបស់កងទ័ពបដិវត្តកម្ពុជា គឺសេនាធិការ។ នៅក្នុងអំឡុងប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍បក្សកុម្មុយនីស្តកម្ពុជា កាលពីថ្ងៃទី០៩ តុលា ឆ្នាំ១៩៧៥ សុន សេន ជា "អ្នកទទួលខុសត្រូវលើសេនាធិការ និងសន្តិសុខ" ខណៈដែល ប៉ុល ពត ទទួលខុសត្រូវទូទៅទៅលើយោធា។ ក្នុងឋានៈជានាសេនាធិការ សុន សេន ជាអ្នកទទួលសេចក្តីរាយការណ៍ ហើយគឺគាត់ក៏ជាអ្នកចេញបញ្ជា។

[១៥:៥៦:១៧]

កថាខណ្ឌ១២៥៖ សេនាធិការត្រូវទទួលខុសត្រូវលើបញ្ហាការ និងការគ្រប់គ្រងរដ្ឋបាលរបស់កងកម្លាំងរបស់ប្រដាប់អាវុធ។ ជារួម សេនាធិការធានាសម្របសម្រួលភារកិច្ចផ្សេងៗ នៅថ្នាក់មជ្ឈិម ដូចជា ការរៀបចំកងពល បញ្ហាការងារចាត់តាំង ភ្នាក់ងារស៊ើបការណ៍ ការរៀបចំទីតាំងកងទ័ព ការរៀបចំផែនការ និងការដឹកនាំប្រតិបត្តិការយោធា ភស្តុភារ អាវុធ គ្រាប់រំសេវ ការផ្គត់ផ្គង់ស្បៀងអាហារ សម្លៀកបំពាក់ ការដឹកជញ្ជូន និងថ្នាំពេទ្យ ហើយចេញបញ្ជាចល័តកងទ័ពទៅកាន់កងពលនានា។ សេនាធិការក៏មានអំណាចផងដែរ ក្នុងការដកមុខតំណែងពីលេខា និងកម្មាភិបាលផ្សេង នៅកងពលមជ្ឈិម នៅខណៈដែលការតែងតាំងមុខតំណែងដឹកនាំនៅក្នុងកងពលមជ្ឈិមនានា ត្រូវបានធ្វើឡើងក្នុងនាមគណៈមជ្ឈិម ដោយ ប៉ុល ពត, នួន ជា, អៀង សារី និង សុន សេន។ ដើម្បីអនុវត្តគោលនយោបាយ និងមាគ៌ាបក្ស សេនាធិការបានរៀបចំនូវវគ្គសិក្សាសម្រាប់កម្មាភិបាលដែលត្រូវបានជ្រើសរើសមក។ ព្រមទាំងការប្រជុំជាទៀងទាត់ សម្រាប់មេដឹកនាំកងពលមជ្ឈិមនានា និងវរសេនាធំឯករាជ្យសម្រាប់ការធ្វើសេចក្តីរាយការណ៍ដល់សេនាធិការ ដែលនឹងចេញបទបញ្ជាទៅវិញ លើបញ្ហានានា។

[១៥:៥៧:៤៨]

ឃ) សមាសភាពកងទ័ពបដិវត្តន៍កម្ពុជា

កថខណ្ឌ១២៦៖ តាមខ្លឹមសារមាត្រា១៩ នៃរដ្ឋធម្មនុញ្ញកម្ពុជាប្រជាធិបតេយ្យ កងទ័ពបដិវត្តកម្ពុជាមានបីប្រភេទគឺ កងទ័ពស្រួច កងទ័ពតំបន់ និងកងឈ្លប។ កងកម្លាំងទាំងបីប្រភេទនេះ ស្ថិតនៅក្រោមការដឹកនាំផ្តាច់មុខ និងផ្តាច់ការរបស់បក្សកុម្មុយនីស្តកម្ពុជា។ កម្លាំងបដិវត្តរួមមាន កងទ័ពស្រួចរបស់មជ្ឈិម និងអង្គភាពយោធាមូលដ្ឋានទាំងអស់ ដែលចុងក្រោយស្ថិតនៅក្រោមការបញ្ជារបស់គណៈកម្មាធិការមជ្ឈិម និងការគណៈកម្មាធិការយោធារបស់មជ្ឈិម។ ដូចគ្នាទៅនឹងអង្គការរដ្ឋដែរ កងទ័ពបដិវត្ត ត្រូវបានគេនិយាយថា "ជាឧបករណ៍ផ្តាច់ការរបស់បក្ស"។

<u>កងទ័ពស្រួច</u>

កថាខណ្ឌ១២៧៖ កងទ័ពស្រួចរួមមាន កងពលនានា និងវរសេនាធំឯករាជ្យ។ កងពលនានាត្រូវបានបែងចែកជាកងពល ដែលរាយការណ៍ផ្ទាល់ទៅមជ្ឈិម និងកងពលតំបន់នានា។ ក្នុងករណីភាគច្រើន កងពលរួមមានបីវរសេនាធំ ដែលវរសេនាធំនីមួយៗមានបីវរសេនាតូច ហើយវរសេនាតូចនីមួយៗមានបីអនុសេនាធំ។

[១៥:៥៩:១៣]

<u>កងពលនានារបស់មជ្ឈិម</u>

កថាខណ្ឌ១២៨៖ កងពលនានារបស់មជ្ឈិម ត្រូវបានបញ្ជាផ្ទាល់ដោយមជ្ឈិម ហើយវរសេនាធំឯករាជ្យ ក៏ទទួលបញ្ជាតាមរបៀបដូចគ្នាដែរ។ កងពលមជ្ឈិម គឺជាកងកម្លាំងយោធាដ៏ចម្បងរបស់កងទ័ពបដិវត្តកម្ពុជា។ ដូចនេះ ហើយកងពលមជ្ឈិមបានធ្វើប្រតិបត្តិការយោធាជាចម្បងប្រឆាំងទៅនឹងខ្មាំងខាងក្រៅ។

កថាខណ្ឌ១២៩៖ កងពលមជ្ឈិមនានា ជារឿយៗ ត្រូវបានគេរៀបចំចាត់តាំងឡើងវិញ ត្រូវបានរំលាយ ឬត្រូវបានបញ្ចូលគ្នាទៅវិញទៅមក នៅក្នុងអំឡុងនៃរបបកម្ពុជាប្រជាធិបតេយ្យ។ ចាប់តាំងពីខែមីនា ឆ្នាំ១៩៧៧ កងកម្លាំងមជ្ឈិមរួមមាន៖ កងពល៨០១ កងពល៧០៣ កងពល៣១០ កងពល៤៥០ កងពល១៧០ កងពល២៩០ កងពល៥០២ កងពល៦២០ និងកងពល១៦៤ និងកងវរសេនាធំឯករាជ្យ ១៥២, ៣៧៧ និង៤៨៨។

កថាខណ្ឌ១៣០៖ កងទ័ពបដិវត្តន៍កម្ពុជាបានបង្កើតផងដែរ នូវបញ្ជាការដ្ឋានសមរភូមិពីរ ដែលបញ្ជាការដ្ឋានសមរភូមិនីមួយៗ ត្រួតពិនិត្យដោយផ្ទាល់លើប្រតិបត្តិការនានា របស់កងពលជាច្រើន។ បញ្ជាការសមរភូមិទាំងពីរនេះ ត្រូវបានបង្កើតឡើងនៅភូមិភាគបូព៌ា។ បញ្ជាការសមរភូមិទី១ មានទីតាំងនៅតាមផ្លូវជាតិលេខ១ ក្នុងតំបន់២៣។ បញ្ជាការដ្ឋាននេះត្រូវបានបញ្ជាដោយ សុន សេន ហើយរួមមានកងពល៧០៣ កងពល៣៤០, ២២១, ៤៦០ និង៨០៥, ២១០, ២៣០, ២៥០ និង២៧០។ បញ្ជាការដ្ឋានសមរភូមិទាំងពីរ-- ទី២ មានទីតាំងនៅតាមបណ្តោយផ្លូវជាតិលេខ៧ ហើយស្ថិតនៅក្នុងភូមិភាគបូព៌ាផងដែរ។ បញ្ជាការដ្ឋាននេះរួមមានកងពល២០៧ (អតីតកងពល៣១០) កងពល៦០៣ (អតីតកងពល៤៥០) កងពល២៨០ និងកងពល១៧៥ រួមបញ្ចូលសមាសភាពមកពីកងពល៥០២ និងកងកម្លាំងនៃភូមិភាគកណ្តាលភូមិភាគឧត្តរចាស់។ ពីដើមឡើយបញ្ជាការសមរភូមិផ្លូវជាតិលេខ៧ ស្ថិតនៅក្រោមបញ្ជារបស់ សោ ភឹម ជាមួយនឹង កែ ពក ដែលជាអនុប្រធាន។ សោ ភឹម ត្រូវបានជំនួសដោយ សុន សេន បន្ទាប់ពីការបោសសម្អាត និងការធ្វើអត្តឃាតរបស់គាត់។

[១៦:០២:០៦]

កថាខណ្ឌ១៣១៖ កងពលមជ្ឈិមត្រូវបានបោសសម្អាតយ៉ាងធ្ងន់ធ្ងរ ដែលនាំទៅដល់ការរៀបចំចាត់តាំងឡើងវិញជាបន្តបន្ទាប់ និងបញ្ចូលគ្នាទៅជាមួយនឹងកងពលផ្សេងៗ។ ករណីនេះមានជាពិសេស

ចំពោះកងពល៣១០, ៤៥០ និងកងពល៩២០ នៅក្នុងក្របខ័ណ្ឌនៃការបោសសម្អាតក្នុងភូមិភាគឧត្តរ ដែលអង្គភាពទាំងនេះ មានដើមកំណើតចេញមកពីភូមិភាគឧត្តរ។ បន្ទាប់ពីដំណើរការបោសសម្អាតនេះ កងពល៣១០ និងកងពល៤៥០ ត្រូវបានរៀបចំចាត់តាំងឡើងវិញ ជាកងពល២០៧ និងកងពល៦០៣។

កថាខណ្ឌ១៣២៖ ការរៀបចំឡើងវិញនូវកងពលនានា បានកើតឡើងផងដែរក្រោយពីមានភាពតានតឹងនៃជម្លោះប្រដាប់អាវុធ ជាមួយវៀតណាមពីចុងឆ្នាំ១៩៧៧មក។ ការណ៍នេះកើតឡើងរួមជាមួយនឹងការបង្កើតកងពលមជ្ឈិមថ្មីមួយចំនួន ដែលកើតចេញមកពីការពង្រីក និងរៀបចំឡើងវិញនូវអង្គភាពនានារបស់ភូមិភាគនិរតី កងពលទាំងនេះរួមមាន៖ កងពល៣៤០ កងពល២២១ កងពល៤៤០ កងពល៤៦០ កងពល២១០ កងពល២៣០ កងពល២៥០ និងកងពល២៧០។

<u>កងទ័ពរបស់ភូមិភាគ</u>

កថាខណ្ឌ១៣៣៖ នៅក្នុងកងទ័ពបដិវត្តន៍កម្ពុ--

**ប្រធានអង្គជំនុំ៖**

បាន១ហើយ។ បាទ អរគុណលោកស្រី សែ កុលវុឌ្ឍី។

[១៦:០៣:៥៥]

*(ចៅក្រមពិភាក្សាគ្នា)*

[១៦:០៥:៤៩]

**ប្រធានអង្គជំនុំ៖**

បាទ កិច្ចដំណើរការសវនាការនៅថ្ងៃនេះដល់ពេលត្រូវសម្រាកហើយ អង្គជំនុំជម្រះប្រកាសផ្អាកកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះត្រឹមនេះ។ សវនាការលើកទៅបន្តធ្វើនៅថ្ងៃស្អែក ថ្ងៃពុធ ទី០៣ ខែតុលា ឆ្នាំ២០១២ ដែលចាប់ផ្តើមពីម៉ោងប្រាំបួនព្រឹក។ សវនាការនៅព្រឹក នៅថ្ងៃស្អែកនេះ អង្គជំនុំជម្រះនឹងបន្តស្តាប់នូវការអានបណ្តាកថាខណ្ឌ នៃដីកាដំណោះស្រាយ ដែលអង្គជំនុំជម្រះបានកំណត់ធ្វើសវនាការសម្រាប់ដំណាក់កាលដំបូង គឺសំណុំរឿង០០២/០១ ដែលនៅសេសសល់ ដែលអង្គជំនុំជម្រះកំណត់ថា ជាអង្គហេតុសម្រាប់ធ្វើសវនាការវគ្គ៣ ក្នុងសំណុំរឿង០០២/០១។ ហើយនឹងអាចបន្តស្តាប់សក្ខីកម្មសាក្សី ដែលមានរហស្សនាម TCW-428 ដូចអង្គជំនុំជម្រះ បានជម្រាបជូនកាលពីមុននេះបន្តិចថា សាក្សីនេះបានបម្រុងទុកនៅថ្ងៃនេះ ហើយដោយសារលទ្ធភាពក្នុងការធ្វើសវនាការមិនទាន់ យើងបានបង្គាប់ឲ្យគាត់ ស្អែកហ្នឹង គឺគាត់ចូលខ្លួនមកបម្រុងទុកនៅក្នុងកិច្ចដំណើរការសវនាការរបស់យើង

ទៀត។

មន្ត្រីអនុរក្សមន្ទីរឃុំឃាំង ឲ្យនាំខ្លួនជនជាប់ចោទ នួន ជា និង ខៀវ សំផន ត្រឡប់ទៅកាន់មន្ទីរឃុំឃាំងនៃ អ.វ.ត.ក វិញចុះ ហើយនិងឲ្យនាំពួកគាត់ទាំងពីររូបមកកាន់បន្ទប់សវនាការនេះវិញ នៅព្រឹកថ្ងៃស្អែកឲ្យបានមុនម៉ោងប្រាំបួន។

សម្រាកចុះ៕

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការផ្អាកនៅម៉ោង ១៦:០៧ នាទី)*